# ក្បួនអាពាហ៍ពិពាហ៍

អ្នកឧកញ៉ាមហាវិនិច្ឆ័យ ឆៅ

និងកូន

អ្នកឧកញ៉ាមហាមន្ត្រី ញ៉ឹក នូច

ព.ស ២៥០៨ គ.ស ១៩៦៥

៦១៤.
៤២

ភ្នំពេញ

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសី-កៃ វិទ្យាស្ថានបើកទូលាយ**
**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY
BUDDHIST INSTITUTE

# ស្មរណពាហ៍ពិពាហ៍



ព.ស. ២៥០៨ គ.ស. ១៩៦៥

រក្សាសិទ្ធិ

## និវេទនកថា

សៀវភៅ **ក្បួនអាពាហ៍ពិពាហ៍** នេះត្រូវបានបោះពុម្ពឡើងវិញ ដោយមូលនិធិ នៃអង្គការហៃនរិះបឺល ( អាល្លឺម៉ង់ ) ។

យើងសង្ឃឹមថា សៀវភៅនេះនឹងបានជាវិភាគទានដល់ការពង្រឹងមិត្តភាពរវាងប្រជាជន អាល្លឺម៉ង់-កម្ពុជា និងចំពោះការថែរក្សាសម្បត្តិ វប្បធម៌ សិល្បៈ របស់ប្រជាជន កម្ពុជា ។

## Acknowledgment

The reprint of *Marriage Ceremonies* is made possible with the financial support from the Heinrich-Böll-Foundation, Germany.

We hope that this book would contribute to the consolidation of the friendship between German and Cambodian people and to the preservation of Cambodian arts and culture.

# ភាគទី ១

ព្រះរាជប្បវេណី

# ក្បួនអាពាហ៍ពិពាហ៍

នេះ

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នោ

និងកូន

អ្នកឧកញ៉ាមហាមន្ត្រី ញិក-នូថ

រៀបរៀង

តាមបុរាណប្រវេណីខ្មែរ

( បោះពុម្ពលើកទី ១ )

ក្នុង

ព. ស. ២៥០៨ – គ. ស. ១៩៦៥

រក្សាសិទ្ធិទាំងអស់

LIBRARY
BUDDHIST INSTITUTE

លោក នួន. ប៊ុត ជាអ្នកជួយត្រួតពាក្យ អក្ខរៈ-ព្យញ្ជនៈ

# អារម្ភកថា

ខ្ញុំបានទទួលក្បួនអាពាហ៍ពិពាហ៍ នេះ ពីលោកឪពុកខ្ញុំ តាំងពី គ. ស. ១៩២៥ កាលខ្ញុំបានអាយុ ២៥ ឆ្នាំ តែខ្ញុំពុំទឹកខ្វល់ខ្វាយនឹងរៀបចំបោះពុម្ពផ្សាយជូនញាតិមិត្រទេ ព្រោះយល់ថា ពិធីរៀបមង្គលការអាពាហ៍ពិពាហ៍ កូនប្រុស - ស្រី មិនអាចនឹងឃ្លាតចាកទម្លាប់ទំនៀមបុរាណបានឡើយ ព្រោះពិធីនេះក្នុងមួយឆ្នាំ ៗ មានធ្វើគ្រប់ស្រុកគ្រប់តំបន់ដនបទក្នុងកម្ពុជរដ្ឋយើង ម្យ៉ាះហើយទម្លាប់ទំនៀមនោះត្រូវតែចំរើនរុងរឿងឡើងជាលំដាប់ ៗ

ឥឡូវពុំដូច្នោះឡើយ ត្រឡប់ទៅជានុនថយគ្មានសណ្ដាប់ធ្នាប់រៀប-រយឲ្យត្រូវតាមប្រវេណីសោះ ចេះតែកាត់មុខកាត់ក្រោយ បណ្ដោយតែតាមគ្នា ។ លោក - អ្នកមេបា ខ្លះប្រកែកនឹងអ្នកថ្មី - អ្នកមហាក៏មាន ។ ជួនកាល អ្នកថ្មី- អ្នកមហា ខ្លះប្រកែកនឹងលោកមេបាក៏មាន ។ ម្យ៉ាះហើយត្រូវខ្សឹបគ្នាថា " កាន់ ៗ ទៅ កុំវែងពេក! កុំសាញពេក! " យ៉ាងនេះជាហេតុនាំឲ្យបាត់ទម្លាប់ទំនៀមពីដូនតាអស់ ។

ហេតុនេះ បានជាមានមិត្រសំឡាញ់របស់ខ្ញុំខ្លះ ចេះតែទទួចសុំឲ្យខ្ញុំសរសេរក្បួននេះឡើង កុំបណ្ដោយឲ្យរលាយរលត់ផុតបាត់ទៅ ទោះជា

លោក-អ្នកសម័យទំនើបមិនតាមក៏ហើយចុះ ព្រោះដំណើរការណ៍ទាំងឡាយ រមែងតែងតែដើរតាមកាលៈទេសៈនិយម ។

ខ្ញុំរៀបរៀងឡើងនេះ គ្រាន់តែជាដំណឹងជូនលោក-អ្នកខាងក្រោយជ្រាបទេ ព្រោះខ្ញុំមានអាយុចូលកាន់មជ្ឈិមវ័យហើយ ។

# ពិធីមង្គលដោយថ្វាយបង្គំព្រះករុណា

ដល់មក គ.ស. ១៩៤៥ ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុវរ្ម័ន ព្រះចៅព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រះមេត្តាដល់រូបខ្ញុំ ដែលជាខ្ញុំក្រោមល្អងធូលីព្រះបាទយុគល តាំងពីសម្ដេចព្រះរាជអយ្យកោ សុធារស មក ព្រះអង្គទ្រង់ព្រះតម្រិះព្រះរាជទាន ព្រះរាជឧត្ដារតម្កល់លើត្បូង យកខ្ញុំពីគ្រូបង្រៀនមកធ្វើជាតាងហ្វាងក្រុមព្រះរាជមន្ទីរ ខ្ញុំក៏បានឃើញច្បាប់ចាស់ចែងពីព្រះរាជពិធីផ្សេង ៗ គ្រប់ទ្វាទសមាស ។

ពិធីវិវាហមង្គលការរបស់ប្រជារាស្ត្រខ្មែរមាន ៣ ប្រភេទ គឺៈ វិវាហមង្គលដោយថ្វាយបង្គំព្រះករុណា ១ ប្រភេទ, វិវាហមង្គល តាមទម្លាប់ទំនៀមប្រពៃណីពីបុរាណ ១ ប្រភេទ, វិវាហមង្គល ដោយវេរកត្ដថ្វាយព្រះសង្ឃ ១ ប្រភេទ ។

ក្នុងទីនេះ ខ្ញុំនឹងបរិយាយរៀបរាប់អំពី ពិធីវិវាហមង្គល ដោយថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ចំពោះព្រះរាជវង្សានុវង្ស ពួកព្រះញាតិ និង បុត្រមន្ត្រីជាដើម តាមច្បាប់ចាស់ ។

ក៏ឯពិធីវិវាហមង្គល ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះមេត្តាប្រោសរាប់រាន មិនមែនសុទ្ធតែធ្វើទាំងអស់គ្នាទេ មានខ្លះធ្វើ

ខ្លះមិនធ្វើ ខ្លះគេរៀបចំទៅតាមទម្លាប់ទំនៀមបុរាណ នៅទីលំនៅរបស់គេក៏មានជាច្រើន ។

មង្គលការបែបនេះ មានគ្រឿងកដបណ្ណាការ " តង្វាយ " តាមបែបដែលគេធ្លាប់ធ្វើមកហើយ ដូចមានតទៅគឺ:

ខាងកូនប្រុស

១– ស្លាព្រះពរ

២– ផ្កាស្រស់ ១ ពានតូច ( ផ្កាម្លិះ ឬ ផ្ការក ឬ ផ្កាម្លិះលាយនិងផ្ការក-ផ្កាស្លា )

៣– ស្លាបព្រាមាស ១ ( ទម្ងន់ ១ ជី ឡើងទៅ ដាក់តម្កល់លើពានមាសតូច ១ )

ខាងកូនស្រី

១– សង់ណា(១) ១ ( គឺប្រអប់គ្រឿងមាសមួយគ្រឿង ) មានគ្រឿងស្លាគ្រប់ និង មានគ្រឿងទេស, ក្រវាញ, ដក្កោ , តុំសែន , ទៀន , សម្បុរល្វីង, ដាក់ក្នុងសង់ណានោះ ។

២– ដន្ទាប់មាស ១ " ទម្ងន់ ១ជី ដាក់ក្នុងសង់ណានោះដែរ ។

---

១ សង់ណា = ធ្វើអំពីស្លឹកបេក រាងមូនជ្រុង កម្ពស់លើពោក – បើគិតតាមរបៀបសាមញ្ញ គឺប្រអប់ស្លា ឬចង់រង ព្រោះមានកូនប្រអប់តូចៗ ដាក់នៅខាងក្នុង ទើបមានរាប់ឈ្មោះខាងលើនេះស្រាប់ ។

## ភជបណ្ណាការរួមគ្នា

១ – សំពត់ព្រែ ១ កី

២ – ទឹកអប់ ៤ ដប ( ញែកដាក់ជា ២ ពាន )

៣ – ផ្លែឈើស្រស់ ( ច្រើនមុខ )

៤ – ផ្លែឈើក្រៀម ( ច្រើនមុខ )

៥ – នំស្រស់ ( ច្រើនមុខ )

៦ – នំក្រៀម ( ច្រើនមុខ )

. . . ។ល។ តាមគេបាន - តាមចូលចិត្ត ។

របស់ទាំងនេះ គេរៀបដាក់តុប្រាក់ ឬ តោក ក្នុង ១ មុខ ១ គូ ៗ គ្រប់មុខទាំងអស់ ។

របស់ណាដាក់ដប – ដាក់បំពង់ គេរៀបឲ្យមានគូ ២ ដប ឬ ៤ ដប ក្នុង ១ តុ ឬ ១ តោក ។

អ្នកកាន់តង្វាយចូលក្រាបបង្គំគាល់ មានប្រុស - មានស្រី រៀបចំខ្លួនប្រាណឲ្យស្អាតល្អសមរម្យ ។

## របៀបតែងកាយ បុត្រា-បុត្រី

សាម័ខ្មនបុត្រា វេលាដែលទៅថ្វាយបង្គំព្រះករុណាតាមទម្លាប់រៀងមក ឲ្យស្លៀកសំពត់សារបាប់ចងក្បិន ពាក់អាវសារបាប់ និងពាក់អាវផាយក្រហមពីក្រៅ ។

បុត្រី ឲ្យស្លៀកសំពត់សារបាប់សំឡុយ ក្រវាត់ខឹមខាត់ ពានា ស្បៃប៉ាក់ឌិន (បែបយ៉ាំងល្ហោន) និងប្រដាប់ដោយគ្រឿងមាសពេជ្រ តាមសមគួរ ។

មុនពេលនឹងទៅថ្វាយបង្គំព្រះករុណា ត្រូវប្រណិប័តន៍ ប៉ូងសេនាបតីក្រសួងព្រះបរមរាជវាំង និងចាងហ្វាងក្រុមព្រះរាជមន្ទីរ ដែលជាចៅក្រសួង ជ្រាបតាមការណ៍ ។ ចាងហ្វាងព្រះរាជមន្ទីរ គប្បីធ្វើចុតហ្មាយក្រាបបង្គំទូលស្នើព្រះករុណា ទ្រង់ជ្រាបជាមុនថា :

សូមព្រះតេជៈគម្កល់លើត្បូង

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ដ្បិតនៅថ្ងៃ......នេះ ជាថ្ងៃជ័យជោគ ឧត្តមឫក្សដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានវរោកាស នាំ...... ចូលមកក្រាបថ្វាយបង្គំល្អងធូលីព្រះបាទ ទទួលព្រះតេជៈព្រះពរ ។.

លុះដល់ឱកាសនោះហើយ មាតាបិតា ឬ អាណាព្យាបាលទាំង-សងខាង ត្រូវនាំបុត្រា-បុត្រី ទៅថ្វាយបង្គំព្រះករុណា ក្នុងព្រះបរមរាជវាំងដោយរថសេះ និងចាត់មនុស្សឲ្យនាំយកនូវគ្រឿងរាជបណ្ណាការ នៅក្នុងវេលាជាមួយគ្នានោះ ។ កាលទៅដល់ព្រះបរមរាជវាំងហើយ នឹងមានចៅហ្វាក់ង៉ារក្រុមរៀនហ្លួង "ព្រះរាជមន្ទីរ" នាំតង្ហែទៅកាន់ក្រឡាព្រះតំនាល់ តាមដែលចៅហ្វាក់ង៉ាររៀបបំរុងទុក ។

ក្នុងកិច្ចនេះ ចាងហ្វាងរឿនហ្លួងនិងភរិយា ជាភ្នាក់ង៉ារ នាំចូលថ្វាយបង្គំ និងក្រាបទូលជូន ។ ចាងហ្វាងរឿនហ្លួង ត្រូវតែងកាយស្លៀកសំពត់សារបាប់ ពាក់អាវសារបាប់ ហើយពាក់អាវផាយក្រហមពីក្រៅ ១ ជាន់ទៀត នាំតង្ហែបុត្រាចូលកាន់ទីក្រឡាព្រះតំនាល់ ។

ភរិយាចាងហ្វាងរឿនហ្លួង តែងកាយ ស្លៀកសំពត់ផាមួងព័ណ៌ពានាផាហ៊ុមវែង នាំតង្ហែបុត្រីទៅកាន់ទីក្រឡាព្រះតំនាល់ ដែលចៅហ្វាក់ង៉ាររៀបបម្រុងខាងក្នុង ១ ទី ដោយឡែកផ្សេង ។

របៀបរៀបចំទីក្រឡាព្រះតំនាល់នោះ ចៅហ្វាក់ង៉ាររៀបក្រាលព្រំ ហើយរៀបដាក់ព្រះទីនាំងកោច្ឆខាងម្ខាង ទុកឱកាសមុខព្រះទីនាំងកោច្ឆ ជាទីថ្វាយបង្គំ ។

ពេលតាមព្រះរាជនិយមក្នុងរជ្ជកាលមុនៗ   កាលព្រះករុណាស្តេចយាងមកប្រថាប់ នៅព្រះទីនាំងកោច្ឋំហើយ   ចាងហ្វាងវៀនហ្លួងនាំសាមីខ្លួនកូនប្រុស ចូលទៅក្រាបថ្វាយបង្គំ ៣ ដង ហើយឲ្យហូបនៅទីនោះ ។ លំដាប់នោះ   ចាងហ្វាងវៀនហ្លួងក្រាបបង្គំទូលធ្វង តាមដំណើរសព្វគ្រប់ទៅតាមដែលគួរនិងក្រាបទូលទ្រង់ជ្រាប ឬ តាមដែលត្រាស់សួរ   ស្រេចហើយយកពានផ្កា បង្អោនចូលទៅថ្វាយព្រះករុណា ។   ទ្រង់ចាប់ផ្កាព្រះរាជទានព្រះពរ រួចហើយក្រាបថ្វាយបង្គំលាថយចេញទៅ   ។

" ឯគ្រឿងបណ្ណាការ   ទៅភ្នាក់ងារ ទទួលយកទៅទុកថ្វាយព្រះករុណាជាខាងក្រោយ "   ។

លំដាប់នោះ ព្រះករុណាស្តេចយាងទៅឯកូនស្រី ដែលរង់ចាំខាងក្នុង ។ ភរិយាចាងហ្វាងវៀនហ្លួង   នាំបុត្រីចូលទៅក្រាបថ្វាយបង្គំ ៣ ដង ហើយក្រាបទូលធ្វងសព្វគ្រប់តាមការណ៍   រួចបើកសងណា   យកដម្លាប់មាសចូលទៅថ្វាយព្រះករុណា ។ ទ្រង់ទទួលហើយព្រះរាជទានព្រះពរ ។ ចប់ហើយថ្វាយបង្គំ ៣ ដង   លាថយចេញទៅ ។

ក្នុងរជ្ជកាល ព្រះករុណាព្រះបាទសម្តេច ព្រះ ស៊ីសុវត្ថិ (ព្រះបរមរាជានុកោដ្ឋ) ទ្រង់ព្រះមេត្តាប្រោស ឲ្យកូនប្រុសកូនស្រីអង្គុយកៅអី ។

វេលាដែលព្រះករុណាស្ដេចយាងចេញមក ឲ្យក្រោកឡើងឈរថ្វាយបង្គំ តែត្រូវឲ្យនៅទីផ្សេងពីគ្នាដូចពីដើម ។

លុះដល់មកវេលាកាលបច្ចុប្បន្ននេះ គឺព្រះករុណា " ព្រះបាទសម្ដេច " ព្រះស៊ីសុវត្ថិមុនីវង្ស " ទ្រង់ព្រះមេត្តាប្រោស ឲ្យកូនប្រុស-ស្រី រួមមកថ្វាយបង្គំក្នុងទីជាមួយគ្នា គឺឲ្យអង្គុយកៅអី ។ វេលាព្រះករុណាស្ដេចយាងចេញមក កូនប្រុស-ស្រី ក្រោកឈរទទួលគ្នាថ្វាយបង្គំព្រះករុណាទ្រង់បាចផ្កាព្រះកេវតានពរដូចមុន ។

ចប់ពិធីថ្វាយបង្គំព្រះករុណាតែប៉ុណ្ណេះ ។

ពោលតាមលក្ខណមង្គលការថ្វាយបង្គំព្រះករុណានេះ ទុកជាបានការហើយ តែពួកអ្នកថ្វាយបង្គំនោះ ច្រើនត្រឡប់ទៅរៀបមង្គលការតាមទំនៀមបុរាណនៅទីលំនៅរបស់ខ្លួនម្ដងទៀត ដើម្បីនឹងបានលៀងភ្ញៀវយកចំណងដៃ តាមសណ្ដាប់ស្រុករៀង ៗ ខ្លួន ។

## គំរូសេចក្តីទូលជូនពិធីភ្ជាប់ពាក្យ (លើកស្លា)

សូមព្រះតេជៈតម្កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណា ជាអម្ចាស់ជីវិត

សម្តេចព្រះមហាក្សត្រិយានី និង សម្តេចព្រះឧបយុវរាជ

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ដ្បិតសម្តេច . . . . . . . មានព្រះហឫទ័យ ត្រេកអរសោមនស្ស យ៉ាងក្រៃពេកជាទីបំផុត ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទាំងពីរព្រះអង្គ ព្រមទាំង សម្តេចព្រះឧបយុវរាជ ដែលមានព្រះរាជហឫទ័យប្រោសប្រណី ព្រះរាជទាន ព្រះអង្គម្ចាស់ក្សត្រី . . . ជាព្រះរាជនត្តា ជាព្រះរាជបុត្រី សម្តេចព្រះឧបយុវរាជ ជាគូនិង . . . . ជាព្រះរាជបុត្រព្រះអង្គម្ចាស់ . . . និង . . . . . ។

ថ្ងៃនេះ ជាសុភមង្គល ប្រកបដោយបុណ្យ មានជោគជ័យ សិរីមហាប្រសើរ សម្តេច . . . . សូមព្រះរាជទាន នាំទូលថ្វាយ ជាភ័ស្តុការបណ្ណាការ មកក្រាបបង្គំទូលថ្វាយ ជា ( ពិធីភ្ជាប់ពាក្យ ) រវាងគូដណ្តឹងទាំងពីរអង្គនេះ តាមព្រះរាជប្រវេណី ។

សូមល្អងធូលីព្រះបាទ ទ្រង់ព្រះមេត្តាប្រោស ទទួលនូវតង្វាយ

• តាមតម្រាប់បុរាណកាលនេះ ដោយព្រះមហាករុណា !

សូមព្រះតេជះតម្កល់លើត្បូង

| ឧកញ៉ាមហាមន្ត្រីឌុលជុង |
|---|

លំដាប់តទៅនេះ, សូមជូនរបៀបពិធីវិវាហមង្គល ក្នុងរជ្ជកាល ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម-សុរាម្រិត និង សម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ-កុសុមៈនារីរត្ន សិរីវឌ្ឍនា ជាអម្ចាស់ជីវិតលើត្បូង ។

ក្នុងរជ្ជកាលនេះ ក៏ពុំមានប្លែកអ្វីពីរជ្ជកាល ព្រះករុណា ព្រះបាទ សម្ដេច ព្រះស៊ីសុវត្ថិ-មុនីវង្ស ដែរ គ្រាន់តែសូមបញ្ជាក់នូវរបៀប ចាត់ពិធី កាលពីក្នុងឱកាសពិធីកំជាប់ពាក្យ និង ពិធីវិវាហមង្គលព្រះរាជ-បុត្រាព្រះករុណា ព្រះបរមខត្តិយកោដ្ឋ និងព្រះរាជបុត្រីព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម-សីហនុវរ្ម័ន ដូចតទៅនេះ ៖

## របៀបព្រះរាជពិធីកំជាប់ពាក្យ

ឧកញ៉ាមហាទេព ហែព្រះរាជបុត្រា និង រាជបណ្ណាការ ចេញពីតំណាក់ ដោយក្បួនហែទៅក្រាបបង្គំទូលថ្វាយ សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ នៅព្រះមហាប្រាសាទខេមរិន្ទ ។ អ្នកឧកញ៉ាមហាមន្ត្រី ចាងហ្វាងក្រុមព្រះរាជមន្ទីរ សូត្រសេចក្ដីទូលដណ្ដឹង ថ្វាយរាជបណ្ណាការ ។

(រូបពិធីកំជាប់ពាក្យ មានលៀនទំកេសដ្ឋៈ នៅទីសួន ក្នុងព្រះបរមរាជវាំង )

" គំរូសេចក្ដីទូលដណ្ដឹងមានពោលនៅខាងក្រោយ "

## ព្រះរាជពិធីវិវាហមង្គល

មានកៀរតិយស ស្ដេចយាង និងអញ្ជើញមកជួបជុំ នៅព្រះមហាមន្ទីរ គឺមានព្រះរាជវង្សានុវង្ស ក្សត្រ-ក្សត្រា ចៅជិត ចៅចម ដំណាវ ខុនណាង ក្រុមឧត្ដមប្រឹក្សាព្រះរាជបល្ល័ង្ក ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ មន្ត្រីជាន់ខ្ពស់ « ទាហាន-ស៊ីវិល » នាយកការិយាល័យ និងនាយកខុទ្ទកាល័យ តាមសេចក្ដីអញ្ជើញពីក្រុមព្រះរាជមន្ទីរៗ

ព្រះអង្គម្ចាស់ក្សត្រី-ក្សត្រា ទាំងពីរព្រះអង្គ ស្ដេចយាងមកដល់ ដោយមានអ្នកឧកញ៉ាមហាមន្ត្រី ស្លៀកសំពត់ពណ៌តាមថ្ងៃ អាវកុតស កគ្រង់ ពាក់អាវផាយ ចាំទទួលនៅកើយខាងមុខ នាព្រះទីនាំងទេពវិនិច្ឆ័យ រួចហែចូលទៅកាន់ទីវិវាហមង្គល នៅព្រះមហាមន្ទីរ ។

សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះឧបយុវរាជ ស្ដេចយាងជាព្រះរាជាធិបតី ។

ក្រោយដែលព្រះអង្គទ្រង់ប្រថាប់សំរួលព្រះឥរិយាបថរួចហើយ ។

មុខក្រសួងត្រូវចាត់ការដូចតទៅ ៖

សង្ឃការី និមន្តព្រះសង្ឃ ១៩ អង្គ ចំរើនព្រះបរិត្ត ។ ចំរើនព្រះបរិត្តរួច អ្នកឧកញ៉ាមហាមន្ត្រី ចាត់ចែងរៀបកន្លងថ្វាយព្រះបិតរ ។ រួចអ្នកឧកញ៉ាមហាមន្ត្រី សូត្រសេចក្តីទូលថ្វាយ ថ្វាយព្រះបិតរ, បារគូថ្វាយពិធីបង្វិលពពិលតទៅទៀត ។ ( មើលគំរូ សេចក្តីទូលថ្វាយ និងផែនទីខាងក្រោម ) ។

ពិធីថ្ងៃ ទី ១ នេះ មានលៀងភោជនាហារ ជាកិត្តិយស ចំពោះភ្ញៀវនៅក្នុងទីសួនមុខព្រះទីនាំងទេវាវិនិច្ឆ័យ តាមសេចក្តីអញ្ជើញ ។

ព្រះអង្គម្ចាស់ក្សត្រី - ក្សត្រា ស្តេចយាងចេញទទួលភ្ញៀវ នៅកើយព្រះទីនាំងទេវាវិនិច្ឆ័យ ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ ។

– មានតំណាងនាម៉ឺនសព្វមុខមន្ត្រី “ ទាហាន - ស៊ីវិល ” ម្នាក់ចូលថ្វាយព្រះពរជ័យមង្គល ។

ព្រះអង្គម្ចាស់ក្សត្រី – ក្សត្រា ទ្រង់ថ្លែងតបវិញ ។

## ព្រះរាជពិធីថ្វាយបង្គំទទួលព្រះតេជៈព្រះពរ

ពិធីថ្ងៃទីពីរ មានគ្រឿងកិត្តិយសដូចពិធីថ្ងៃទី ១ ដែរ , តែពិធីនេះ ធ្វើនៅព្រះទីនាំងទេវាវិនិច្ឆ័យ នៅក្រោមព្រះរាជាធិបតីភាព នៃសម្ដេចទាំងពីរព្រះអង្គ ។ ឯអ្នកឧកញ៉ាមហាមន្ត្រី ក៏ចាំទទួលព្រះអង្គម្ចាស់ក្សត្រី-ក្សត្រា នៅកើយ ព្រះទីនាំងទេវាវិនិច្ឆ័យ ដូចពិធីថ្ងៃទី ១ ។

ក្រោយដែលអ្នកឧកញ៉ាមហាមន្ត្រី ដង្ហែព្រះអង្គម្ចាស់ក្សត្រី - ក្សត្រា ថ្វាយបង្គំ ៣ ដងរួចហើយ, អ្នកឧកញ៉ាមហាមន្ត្រី សូត្រសេចក្ដីទូលថ្វាយរួច សម្ដេចព្រះមហាក្សត្រិយានី និង សម្ដេចព្រះប្រមុខរដ្ឋ ព្រះរាជទានព្រះតេជៈព្រះពរ និង ទឹកក្លស់ ទឹកសង្ខ ( ហារគូថ្វាប្រស័ទ្ធ ) ។

រួចមានលៀងនំ - ភេសជ្ជៈ នៅព្រះទីនាំងភោជនីយ៍ ចំពោះភ្ញៀវ ដែលបានមកក្រាបបង្គំគាល់ ក្នុងឱកាសព្រះរាជពិធីនេះ ។

ក្នុងរាត្រីទីពីរនេះ មានមហោស្រព នៅព្រះមហាប្រាសាទខេមរិន្ទ ព្រះរាជទានដល់ភ្ញៀវជាន់ខ្ពស់ និង អង្គទូតនានាផង ។

## គំរូសេចក្ដីទូលថ្វាយសូមព្រះរាជទានព្រះតេជៈព្រះពរ

សូមព្រះតេជៈតម្កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ដ្បិតព្រះអង្គម្ចាស់ក្សត្រី នរោត្ដម–បទុមបុប្ផា ជាព្រះរាជបុត្រី សម្ដេចព្រះឧបយុវរាជ បានផ្សំផ្គុំជាព្រះ ជាយា-ស្វាមី ជាមួយនិងព្រះអង្គម្ចាស់ក្សត្រា ស៊ីសុវត្ថិ–ជីវ័ន្តមុនីរក្ស ជាព្រះរាជបុត្រា ព្រះករុណា ព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ-មុនីវង្ស (ព្រះបរមរត្តិយកោដ្ឋ) និងឃុនព្រះម្នាង បុប្ផានរលក្ខណ៍ (តាត) ។

ថ្ងៃនេះ ជាថ្ងៃអាទិត្យ សោភា ជាសុភមង្គល ប្រកបដោយឫក្ស ជោគជ័យ មហាប្រសើរ,

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទាន ព្រះបរមរាជវរោកាស នាំគូអាពាហ៍ពិពាហ៍ទាំងពីរព្រះអង្គ ចូលមកក្រាបថ្វាយបង្គំ សូមព្រះរាជទាន ព្រះតេជៈព្រះពរ ។

សូមព្រះតេជៈតម្កល់លើត្បូង

| ឧកញ៉ាមហាមន្ត្រីទូលថ្វាយ |
|---|




វិធនទីថ្វាយព្រះបិតរ
ឈមមុខទៅទិសដង្ហែបរស

## សេចក្តីគោរពជូនថ្វាយព្រះបិតរ

សូមព្រះតេជៈតម្កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល

ព្រះករុណា ព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរា-
ធិបតី

ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម បរមទេវាវតារ

ព្រះករុណា ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ

ព្រះករុណា ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ-មុនីវង្ស

ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម-សុរាម្រិត

សម្តេចព្រះរាជអយ្យកោ សុធារស

សម្តេចព្រះរាជអយ្យកា ជង៉ាង៉ាម

សម្តេច ព្រះវររាជជនីណាថ បរមបពិត្រ

ដែលជា សម្តេច ព្រះអយ្យកោ-ព្រះអយ្យកា-ទួត-លួត-លា នូវព្រះបរមរាជវង្សានុវង្ស ក្សត្រី-ក្សត្រា ដែលទ្រង់សោយព្រះទីវង្គតទៅទាំងអម្បាលម៉ាន,

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ដ្បិត សម្តេចព្រះមហាក្សត្រិយានី កុសុមៈ នារីរត្ន

និង សម្តេចព្រះឧបយុវរាជ ព្រះអង្គទ្រង់មានព្រះរាជបញ្ជា ឲ្យរៀបព្រះរាជពិធីវិវាហមង្គលព្រះអង្គម្ចាស់ក្សត្រីជាព្រះរាជនត្តា និងជាព្រះរាជបុត្រីជាជាយា-ស្វាមីនិងព្រះអង្គម្ចាស់ក្សត្រា ស៊ីសុវត្ថិ-ជីវ័នមុនីរក្ស ជាព្រះរាជបុត្រា ព្រះករុណា ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ - មុនីវង្ស (ព្រះបរមខត្តិយកោដ្ឋ) និងយុទព្រះម្នាង បុប្ផាចរលក្ខណ៍ ( តាត)។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទាន ព្រះបរមរាជវរោកាស នាំតួអាពាហ៍ពិពាហ៍ ទាំងពីរព្រះអង្គនេះ មកសូមព្រះរាជទាន ព្រះបរមរាជា-នុញ្ញាត រៀបវិវាហមង្គល តាមព្រះរាជប្រវេណី និង សូមព្រះរាជទាន អញ្ជើញស្តេចយាង ព្រះករុណាថ្លៃវិសេសគ្រប់ៗព្រះអង្គ មកគង់ប្រថាប់ក្នុងទីនេះ ជាព្រះរាជាធិបតី សោយគ្រឿងតង្វាយ ដែលបានរៀបតាក់-តែងថ្វាយ យ៉ាងប្រណិតផ្ចិតផ្ចង់នេះ តាមព្រះរាជហឫទ័យ កំសាន្ត ។

ហើយសូមព្រះរាជទានព្រះពរសព្ទសាធុការ ដល់ព្រះអង្គម្ចាស់ក្សត្រី - ក្សត្រា ទាំងពីរព្រះអង្គ សូមឲ្យបានជាគូគាប់ ប្រកបដោយ អាយុ: វណ្ណ: សុខ: ពល: ,

កុំបីមានឧបសគ្គអ្វី មករាំងរា លុះអវសានកាល !

សូមព្រះតេជ:តម្កល់លើត្បូង

ឧកញ៉ាមហាមន្ត្រីធ្លូលជួង

# ព្រះសន្ទរកថា

នៃ

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ - ជីវ៍ន់មុនីរក្ស ថ្លែងទៅកាន់ភ្ញៀវក្នុងឱកាសពិធីលៀងសាយភត្ត នៅក្នុងរាត្រីថ្ងៃសៅរ៍ទី ២៧ កក្កដា ១៩៦៣ ។

---

ទ្រង់

ឯកឧត្តម

លោកជំទាវ

លោកស្រី

អស់លោក

ខ្ញុំសូមថ្លែងសេចក្ដីគោរពដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះទ្រង់ - ឯកឧត្តម - លោកជំទាវ - លោកស្រី និង អស់លោក ដែលបានស្ដេចយាង និងអញ្ជើញ យ៉ាងណែនណាន់តាន់តាប់ មកកាន់ពិធីលៀងសាយភត្ត ក្នុងឱកាសវិវាហមង្គលរបស់ខ្ញុំ ជាហេតុនាំឲ្យពិធីនេះ បានរុងរឿងយ៉ាងអធិកអធមក្រៃលែង ។ ខ្ញុំមានហឫទ័យរំភើបញាប់ញ័រជាទីបំផុត ចំពោះកាយវិការ និង សេចក្ដីចំណានដ៏ថ្លៃថ្លានេះ ។

នៅទីបំផុត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះសព្វសាធុការពរ ដែលអស់លោកជាតំណាងទ្រង់ - ឯកឧត្តម - លោកជំទាវ -

លោកស្រី និងអស់លោក បានថ្លែងថ្វាយមកខ្ញុំក្នុងខណៈនេះ ៗ ខ្ញុំសូមទទួលពរទាំងនោះ ដោយសេចក្ដីរីករាយយ៉ាងក្រៃលែង ហើយខ្ញុំសូមបួងសួងដល់ទេពនិករអមរមេឃ សូមឲ្យលោកត្រេកត្រអាលជួយបីបាច់រក្សាទ្រង់ - ឯកឧត្តម - លោកជំទាវ លោកស្រី និង អស់លោក ឲ្យបានសេចក្ដីសុខក្សេមក្សាន្តជានិរន្តរតរៀងទៅ ។

# ព្រះសន្ទរកថា

នៃ

ព្រះអង្គម្ចាស់ក្សត្រី នរោត្តម - បទុមបុប្ផា ទ្រង់ថ្លែងទៅកាន់ភ្ញៀវ ក្នុងឱកាសពិធីលៀងសាយភត្ត នៅក្នុងរាត្រី ថ្ងៃសៅរ៍ទី ២៧ កក្កដា ១៩៦៣ ។

---

ទ្រង់

ឯកឧត្តម

លោកជំទាវ

លោកស្រី

អស់លោក

ខ្ញុំសូមទ្រង់ – ឯកឧត្តម – លោកជំទាវ – លោក និង អស់លោក អនុញ្ញាតឲ្យខ្ញុំ ថ្លែងនូវសេចក្ដីរំជួលហឫទ័យរបស់ខ្ញុំ យ៉ាងខ្លាំងមហិមា ដោយបានឃើញ ទ្រង់ – ឯកឧត្តម – លោកជំទាវ – លោកស្រី និង អស់លោក បានស្ដេចយាង និង អញ្ជើញមកកាន់ពិធីវិវាហមង្គលនេះយ៉ាងកុះករ ដើម្បីសំដែងសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រដល់រូបខ្ញុំ ។

ខ្ញុំសូមថ្លែងសេចក្ដីកតញ្ញូយ៉ាងជ្រាលជ្រៅ ចំពោះសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រនេះ ។

សព្ទសាធុការពរដែលអស់លោកជាតំណាង ទ្រង់-ឯកឧត្តម-លោកជំទាវ-លោកស្រី និង អស់លោក បានប្រសិទ្ធិថ្វាយមកខ្ញុំក្នុងឱកាសនេះ នាំឲ្យខ្ញុំមានហឫទ័យរំភើបយ៉ាងក្រៃលែង ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះសព្ទសាធុការពរមហាប្រសើរទាំងនោះ ។

នៅទីបំផុតនេះ ខ្ញុំសូមគុណបុណ្យព្រះរតនត្រ័យ និង បុព្វានុភាពនៃវត្ថុសក្តិសិទ្ធិក្នុងពិភពលោក មេត្តាជួយព្យាបាល ទ្រង់-ឯកឧត្តម-លោកជំទាវ-លោកស្រី និង អស់លោក ឲ្យបានជួបប្រទះតែនឹងសេចក្ដីសុខ សេចក្ដីចំរើន ប្រាសចាកភយន្តរាយផ្សេងៗ កុំបីឃ្លៀងឃ្លាតឡើយ ។

# ព្រះរាជប្រកាស

(លេខ ៣៣ ស្ទួន ចុះថ្ងៃ ១៤ មីនា ១៩០៩)

ប្រការ ១ – តាំងពីថ្ងៃចេញព្រះរាជប្រកាសនេះ ព្រះរាជបុត្រា ព្រះរាជបុត្រី ព្រះករុណាព្រះចៅក្រុងកម្ពុជាធិបតីមុន ៗ និង ព្រះរាជបុត្រា ព្រះរាជបុត្រីព្រះករុណាគ្រងរាជ្យសព្វថ្ងៃ បើមានសេចក្ដីមេត្រីចង់បានគូ ជាស្វាមី-ភរិយា ឬ ស្តេចក្សត្រាណា ក្រៅពីព្រះរាជបុត្រា ចង់បានព្រះរាជបុត្រីព្រះករុណាធ្វើជាភរិយា នោះត្រូវឲ្យស្តេចក្សត្រានោះធ្វើជាចុតហ្មាយក្រាបបង្គំទូលថ្វាយសុំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, បើព្រះរាជបុត្រាព្រះករុណា ឬ ស្តេចណាចង់បានស្តេចក្សត្រីឯទៀត ក្រៅពីព្រះរាជបុត្រីព្រះករុណា នោះត្រូវឲ្យព្រះរាជបុត្រា ឬ ស្តេចនោះ ធ្វើចុតហ្មាយសុំដណ្តឹងដល់មាតាបិតាស្តេចក្សត្រីនោះ, បើស្តេចក្សត្រីនោះគ្មានបិតាមាតា ឲ្យព្រះរាជបុត្រាព្រះករុណា ឬ ស្តេចនោះ ធ្វើចុតហ្មាយសុំដណ្តឹងដល់អាណាព្យាបាល ដែលចិញ្ចឹមរក្សាស្តេចក្សត្រីនោះ ឲ្យបិតាមាតា ឬ អាណាព្យាបាលនោះ គិតយល់ដូចម្តេចឲ្យធ្វើចុតហ្មាយ ក្រាបបង្គំទូលថ្វាយចុតហ្មាយសុំដណ្តឹងនោះ ដល់ព្រះករុណា ស្រេចនូវទ្រង់ព្រះមេត្តាប្រោសដូចម្តេច តាមសព្វព្រះរាជហឫទ័យ ។

ប្រការ ២– បើព្រះករុណាទ្រង់ព្រះមេត្តាប្រោស ព្រះរាជទាន តាមសេចក្តីសុំដូចមានខាងលើនេះ និង មានបុតហ្មាយឡាយព្រះហស្ត-លេខាព្រះរាជទានដំណឹង ដល់ស្តេចក្សត្រា – ក្សត្រី ដែលសព្វព្រះទ័យនិងគ្នានោះ ហើយព្រះរាជវង្ស ឬ ព្រះញាតិទាំងសងខាង ត្រូវគិតគូរកថ្ងៃឫក្សល្អជាកំណត់ រៀបវិវាហមង្គលនោះ ឲ្យស្តេចក្សត្រាធ្វើបុតហ្មាយក្រាបបង្គំទូលថ្វាយកំណត់នោះ សូមទ្រង់ជ្រាប ព្រះករុណានិងទ្រង់ព្រះរាជានុញ្ញាតឲ្យប្រជុំ ព្រះរាជវង្ស និង ព្រះញាតិទាំងសងខាង និង ស្តេចក្សត្រា - ក្សត្រី ដែលផ្សំផ្គុំ និង គ្នានោះ មកជួបគ្នាម្តង នៅចំពោះព្រះភក្ត្រជាមុន ឲ្យស្គាល់គ្នា ឲ្យច្បាស់ជាស្ទួន ក្នុងវេលាជួបជុំនេះ ហៅថា " ពិធីកាំជាប់សត្តសញ្ញា " ដែលរាស្ត្រ ហៅថា " កាំជាប់ពាក្យ " ត្រូវឲ្យខាងក្សត្រា យករបស់ដ៏សមគួរមកទុកឲ្យខាងក្សត្រី ជាទីសំគាល់សេចក្តីប្រមូលសនានិងគ្នាតទៅមុខ ហើយឲ្យមានចិញ្ចៀនក្សត្រា ១ វង់ថ្វាយទៅខាងក្សត្រី ។ ថ្វាយចិញ្ចៀន ១ វង់ ទៅខាងក្សត្រា ឲ្យពាក់ជាប់និងព្រះហស្ត ជារបស់រំឭកជានិច្ចរៀងតទៅ ។ ក្នុងវង់ចិញ្ចៀននោះ ឲ្យឆ្លាក់អក្សរនាមរបស់ក្សត្រា - ក្សត្រីភ្ជាប់គ្នា ។ ក្នុងពិធីកាំជាប់សត្តសញ្ញា នេះ ស្តេចក្សត្រាមានអ្នកដ៏សមគួរ ២ នាក់ ប្តីប្រពន្ធ ហៅថា " អ្នកាមបរា " និង ខាងក្សត្រី មានអ្នកដ៏សមគួរ ២ នាក់ ប្តីប្រពន្ធ-

ហៅថា " អ្នកមេបា " មកជួបជុំជួយកំដរ ហើយនិងឲ្យធ្វើជាបន្ទាល់ខាងក្សត្រា – ក្សត្រីទាំងសងខាងក្នុងវិវាហមង្គលផង ទើបព្រះករុណាទ្រង់សម្រេចកំណត់ថ្ងៃរៀបវិវាហមង្គលការនោះ ។

ប្រការ ៣– ដល់កំណត់រៀបវិវាហមង្គល ថ្ងៃគំរប់១ វេលារសៀល ក្រុមរឿនហ្លួងត្រូវអញ្ជើញស្ដេចក្សត្រា និង មេបាខាងស្ដេចក្សត្រី ទៅថ្វាយបង្គំព្រះបិតរក្នុងហោព្រះអដ្ឋិ ក្រាបបង្គំទូលសូមព្រះរាជានុញ្ញាត រៀបវិវាហមង្គលនេះ ហើយត្រូវក្រុមហោរា រៀបប្រកាសទេវតាឥន្ទព្រហ្ម និង អ្នកតាសូមជ្រាប និង សូមព្រះតេជៈព្រះពរក្នុងពិធីនេះហៅ " ក្រុងពាលី " ហើយនិមន្តព្រះសង្ឃ ១៩ អង្គ តាមគ្រលឹង សូត្រព្រះទិព្វមន្ត ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ត្រូវឲ្យស្ដេចក្សត្រា - ក្សត្រី ទាំង ២ អង្គនោះ តែងអង្គតាមទំនៀម, ឲ្យមហាប្រុសនាំមុខស្ដេចក្សត្រា មានមហាតលិក ១២ នាក់ អញ្ជើញគ្រឿង និង មហាស្រីនាំមុខស្ដេចក្សត្រី មានសាវឡិក ១២ នាក់ អញ្ជើញគ្រឿងហែពីតំណាក់ចេញមកនមស្សការព្រះពុទ្ធរូប និង ស្ដាប់សូត្រព្រះទិព្វមន្តគ្រប់ ៣ រាត្រី ជួបជុំព្រះរាជវង្សានុវង្សនិងភ្ញៀវដែលអញ្ជើញមកក្នុងវិវាហមង្គលការនេះ, បើស្ដេចនោះនៅក្រៅព្រះបរមរាជវាំង ត្រូវរៀបក្បួនហែ ដូចបានសម្រេចក្នុងប្រការ ៤ ក្នុងព្រះរាជប្រកាសនេះផង ។

ប្រការ ៤ – នៅថ្ងៃគំរប់ ៤ វេលាព្រឹករៀបពិធីផ្ទឹម ស្តេចក្សត្រា-ក្សត្រី ទាំង២ អង្គ ចេញមកក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ តាមក្បួនហែដែលមកផ្ទឹមក្រាបថ្វាយបង្គំព្រះករុណាជាសម្តេចព្រះវររាជបិតា និង អ្នកមាតា ៣ ជន (ភ្លេងខ្មែរត្រូវលេងភ្លេងព្រះថោង) ។

ទើបមានព្រះរាជឱង្ការ ត្រាស់ឲ្យឧកញ៉ាវាំងវរៈវៀងជ័យ ជាសេនាបតីមុខក្រសួងរបៀបវិវាហមង្គលនោះ ទូលព្រះរាជឱង្ការ សូត្រសេចក្តីសញ្ញាវិវាហមង្គល ដូចមានគំរូទ្រង់ព្រះរាជានុញ្ញាត ជាប់ក្នុងព្រះរាជប្រកាសនេះ ឲ្យស្តេចទាំង ២ អង្គ ស្តាប់ ហើយបើទទួលព្រម នឹងត្រូវឲ្យស្តេចទាំង២ អង្គ ឡាយព្រះនាមក្នុងសញ្ញានោះ ជាមួយនិងសម្តេចព្រះវររាជបិតា និង អ្នកមាតា និង បន្ទាល់ទាំងសងខាង និង សេនាបតី មុខក្រសួងខាងព្រះបរមរាជវាំង ១ ត្រូវថ្លែងសេចក្តីថា "ស្តេចទាំង ២ អង្គនោះ បានរៀបវិវាហមង្គលត្រឹមត្រូវតាមច្បាប់ហើយ" រួចត្រូវរៀបបន្ទិលពពិល ១៩ ជុំ ត្រូវលេងភ្លេង ជាតពន្ធ ក្រុមបារគូត្រូវផ្លុំស័ង្ខថ្វាយព្រះករុណាទ្រង់ព្រះរាជតានព្រះសិត្តរសព្រះរាជស័ង្ខ ឲ្យស្តេចទាំង ២ អង្គនឹងសៀតស្លឹកខ្ចី ព្រះរាជតានឲ្យសៀតទៅព្រះកាណ៌(១) ខាងស្តាំ

– ព្រះកាណ៌ = ត្រចៀក (ព. វ. ស.) ។

ហើយទ្រង់ចឹម(១) គ្រឿងមង្គលាភិសេក ស្តេចទាំង ២ អង្គ " ជាមង្គល ជោគជ័យ ជួសអំបោះចងដៃ និងជួសផ្កាស្លា ដែលរៀប មង្គលការរាស្ត្រ " ហើយទ្រង់ព្រះរាជទានសាធុការពរ ជាសិរីសុខ មហាប្រសើរតរៀងទៅ ស្តេចទាំង ២ អង្គ ក្រាបថ្វាយបង្គំព្រះករុណា និង ព្រះមាតា ៣ ជង រួចព្រះករុណាព្រះរាជទានសញ្ញានោះ ឲ្យ ១ ច្បាប់ ១ អង្គ " ជាជំនួសខាន់ស្លា ក្នុងមង្គលការរាស្ត្រតាំងពីបូរាណ " រួចលេងភ្លេងជាងជាត ។ ស្តេចក្សត្រាកាន់ស្បៃ ស្តេចក្សត្រចូលទៅ កាន់ឋានក្នុងជាមួយគ្នា ដោយក្បួនហែដូចដែល ទើបស្តេចក្សត្រាចេញ មកវិញ ទទួលតំណាប់អស់ព្រះរាជវង្សានុវង្ស និងភ្ញៀវ ដែលមកជួបជុំនោះ សូមអញ្ជើញសៀងគោជនាហារជាសោមនស្ស តាមចុតហ្មាយអញ្ជើញ ពីព្រះនាមសម្តេចព្រះវររាជបិតា ក្នុងឱកាសនេះនិងគួបព្រះហស្តព្រះស្វាមី ព្រះរាជកិរិយាបាន តាមទំនៀម ។

---

១ – ទ្រង់ចឹមគ្រឿងមង្គលាភិសេក= លាបគ្រឿងក្រអូប ដូចមានអធិប្បាយតទៅ

គេយកៈ ម្សៅលាបមុខ , ប្រេងម្សះ, ប្រេងរំចេក , ប្រេងច័ន្ទ, ល្មៀត មកលាយឲ្យចូល គ្នា ហើយយកចង្អុលនៃផ្តិត រួចលាបនៅប្រជុំចិញ្ចើម - នៅស្មៀតថ្ពាល់ទាំងសងខាង - នៅបាត ដៃទាំងពីរ ឲ្យមនុស្សណាដែលគេត្រូវធ្វើពិធីចំរើនឲ្យនូវជ័យមង្គល ដូចពិធីខាន់ស្លា និងពិធី រៀបមង្គលអាពាហ៍ពិពាហ៍ ( នេះតាមពិធីព្រាហ្មណ៍ ) ។

ប្រការ ៥– វេលាល្ងាចនោះ ត្រូវរៀបក្បួនហែស្តេច ព្រះស្វាមី គង់លើព្រះសសៀង ព្រះរាជករិយាគង់សិវិកា(១) ឬរាជរថ ស្រេចនៅព្រះករុណា ទ្រង់ព្រះមេត្តាប្រោស ឲ្យហែទៅកាន់តំណាក់ព្រះស្វាមី ក្បួនហែដូចថ្ងៃរៀបវិវាហមង្គល តែបើស្តេចក្សត្រា គង់ព្រះសសៀង(២) ត្រូវមានក្រុមតំរួតហែមុខ កាន់រំពាត់ប្បាច់ ១ នាក់ និងដើរអមដៃប្រណាម្យ ៨នាក់, បើគង់រាជរថ មានក្រុមយុទ្ធនាសេះ ១ នាក់ ហែខាងមុខ, និង៨នាក់ហែក្រោយ ទៅឯតំណាក់ជាមុន ចាំទទួលព្រះរាជករិយាជាមួយនិងព្រះមាតា ឯព្រះរាជករិយា ត្រូវឲ្យព្រះមាតាជូនទៅជាមួយនិងក្បួនហែ ទៅដល់តំណាក់នោះព្រះស្វាមី ត្រូវទទួលកៀកព្រះហស្តព្រះរាជករិយាចូលទៅក្នុងតំណាក់ រៀបគ្រឿងសង្វេយសែនថ្វាយព្រះបិតរ សូមសិរីសួស្តីជ័យមង្គល ហើយរៀបផ្ទំព្រះបន្ទំជាបរមសុខក្សេមក្សាន្ត បំរើនគ្រប់ប្រការតរៀងទៅ ។

ប្រការ ៦– បើស្តេចគ្រប់អង្គឯទៀត ក្រៅពីព្រះរាជបុត្រា-បុត្រី ព្រះករុណា តាំងសង់ខាង និងរៀបវិវាហមង្គលនោះ ក៏ត្រូវធ្វើតាមព្រះរាជបញ្ញត្តិនេះ, ប៉ុន្តែត្រូវសូត្រមន្តតែ ១ ថ្ងៃ ហើយព្រះសង្ឃតែ ៨ អង្គ និងមហាតលិក និង សាវឡឹកហែតែ ៦ នាក់ ។

---

១– សីវិកា – គ្រែស្នែង (គឺសសៀងនិងរ) ។

២– សសៀង – គ្រែស្នែងលាត ។ –៣– គ្រែស្នែងមានដំបូល ។

ប្រការ ៧– របៀបដូចមានខាងលើនេះ សម្រាប់រៀបវិវាហ-
មង្គល តែព្រះរាជកិរិយាធំក្នុងព្រះរាជវង្សានុវង្ស , ឯកិរិយាតូចចុះទៅនោះ
បើព្រះរាជបុត្រ ព្រះករុណាតាំងសងខាង ឬ តែម្ខាង ត្រូវធ្វើតាមរបៀប
វិវាហមង្គលស្តេចក្រៅពីព្រះរាជបុត្រតាំងសងខាង ដូចមានក្នុងប្រការ ៦
ខាងលើនេះ របៀបតូចនេះ បើស្តេចគ្រប់អង្គយកកូននាហ្មឺនសព្វមុខមន្ត្រី
ឬ កូនរាស្ត្រ ធ្វើជាកិរិយាធំនោះ ត្រូវរៀបនៅតំណាក់ នៅផ្ទះសាមីខ្លួន
ព្រះករុណាទ្រង់ស្តេចយាងទៅជាអធិបតី ទ្រង់ ចុកញ្ញាក់ងវះវៀនជ័យ ឬ ឲ្យ
តែរាជបំរើ ឬ បំរើទៅជួសក៏បាន បើស្តេចនោះយកកូននាហ្មឺន កូនមន្ត្រី ឬ
កូនរាស្ត្រ ធ្វើជាកិរិយាតូចចុះមកនោះ ត្រូវរៀបតាមសុខចិត្តតាំងសងខាង
នៅតំណាក់-នៅផ្ទះ តាមច្បាប់ក្រមទសកិរិយា ព្រះករុណាមិនទ្រង់ស្តេច
យាងទៅជាអធិបតីទេ តែឲ្យមានសំបុត្រ សូមឲ្យព្រះហស្តលេខា
ទ្រង់ព្រះរាជានុញ្ញាត ហើយកត់ទុកក្នុងក្រមព្រះរាជាយុត្តកៈផង ។

## ក្បួនរាជសព្ទ

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ព្រះចិន្ដាយល់ថា រាជសព្ទបុរាណដែលធ្វើទុកមក ថាបើក្សត្រជាស្ដេចទ្រង់រាជ្យហើយយកស្ដេចស្រីឯណាជាមហេសី បើមាតាបិតាបានរៀបអាពាហ៍ពិពាហ៍ ត្រូវហៅដូច្នេះ, បើយកខ្លួនឯងត្រូវហៅដូច្នោះ, បើយកស្រីដែលមិនមែនជាស្ដេច ក៏សឹងឲ្យហៅថាដូច្នេះដូច្នោះ, សេចក្ដីតាំងអម្បាលនេះ ទ្រង់ព្រះតំរិះយល់ថា ទិន សន្មតហៅពុំបាន លុះតែម្ចាស់ផែនដីទ្រង់តាំងនាមហើយមានព្រះរាជពិធីឲ្យធ្វើដូច្នេះដូច្នោះ ទើបហៅបាន ទើបទ្រង់មានព្រះរាជបញ្ញត្តិ ទុកបែបបទ, បើ ទិន តាំងជាទីអ្វីក្ដី ត្រូវឲ្យមានសុវណ្ណបត្រ ហើយឲ្យមានពិធីព្រាហ្មណ៍ធ្វើផ្សេង ៗ ដើម្បីជាច្បាប់សណ្ដាប់ព្រះរាជប្រវេណីតទៅឲ្យដឹងដូច្នេះ ។

ប្រការ ១– បើម្ចាស់ផែនដីយកខត្តិយកញ្ញាឯណាជាបាទបរិចារិកា មានវិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខ លើព្រះរាជអាសនៈបុស្បករួមជាមួយនឹងម្ចាស់ផែនដី រីខត្តិយកញ្ញានោះហៅថា សម្ដេចព្រះអគ្គមហេសី ឬ សម្ដេចព្រះអា[១]អគ្គមហេសី តាមសុវណ្ណបត្រ បើ

---

១– ព្រះអាអគ្គមហេសី = ពាក្យ អា មួយម៉ាត់នេះ ជាពាក្យគេបន្ថែម ដើម្បីឲ្យងាយប្រើក្នុងការតែងពាក្យកាព្យឃ្លោង ។

មានពិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខតែពុំបានរួមអាសន៍ និងម្ចាស់ផែនដី ទេ ហើយបានទ្រង់ព្រះរាជតានទឹកស័ង្ខ ដោយព្រះហស្តឯង អង្គុយកន្ទង តាបជានិម្ចាស់ផែនដី ហៅថា "សម្តេចព្រះអគ្គរាជទេពី" ឯខត្តិយកញ្ញាដូចមានព្រះនាមមកនេះ បើមានព្រះរាជបុត្រនិងម្ចាស់ផែនដី បើជាក្សត្រា ហៅថា "សម្តេចព្រះរាជឱរស, សម្តេចបរមរាជឱរស ឬសម្តេចព្រះបរមរាជបុត្រា ឬ សម្តេចព្រះអយ្យ-បុត្រ" ក៏បាន, បើជាក្សត្រី ហៅថា "សម្តេចព្រះរាជធីតា" ព្រះនាមទាំងអម្បាលនេះ ស្រេចហើយតែទ្រង់តាំង ។

ប្រការ ២– ខត្តិយកញ្ញាឯណាដែលម្ចាស់ផែនដី យកជាបាទ-បរិចារិកា តែពុំបានទ្រង់ព្រះរាជតានព្រះបរមរាជានុញ្ញាត ឲ្យមានពិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខ គ្រាន់តែទ្រង់ទទួលយកស័ង្ខអំពីដៃព្រាហ្មណ៍មកព្រះរាជតាន រីខត្តិយកញ្ញានោះ ហៅថា "ព្រះអគ្គ-ជាយា" បើមានព្រះរាជបុត្រ និង ម្ចាស់ផែនដី ទោះបីជាក្សត្រាក្តី ក្សត្រីក្តី ហៅថា "សម្តេចព្រះរាជបុត្រា – បុត្រី" តែយស-ថយជាងក្សត្រ ទីសម្តេចក្នុងប្រការ ១, បើជាពុំមានសុវណ្ណប័ត្រ តាំងជា ព្រះអគ្គជាយា ទេ ត្រូវហៅតាមនាមដើម, បើមានព្រះរាជបុត្រ ហៅថា "ព្រះរាជបុត្រា - បុត្រី ព្រះអង្គម្ចាស់ នេះ - នោះ". ។

ប្រការ ៣– បើម្ចាស់ផែនដីទ្រង់យកស្រ្តីពាំងឆ្នួង ក្រៅពាក់អំពីក្សត្រខត្តិយកញ្ញា មកជាបាទបរិចារិកា ហើយបានទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទឹកស័ង្ខដោយព្រះហស្តឯង ស្រ្តីនោះ ហៅថា "ចៅចម" ឯចៅចមមាន ៦ ជាន់ ដូចមាននាមដូច្នេះ៖

ទី ១ – ព្រះបិយា ងារជាព្រះបរម ; ទី ២ – ព្រះស្នំ ងារជាព្រះម្នាង ; ទី ៣ – ព្រះស្រិង្គារ ងារជាព្រះម៉ែនាង ; ទី ៤ – ព្រះក្រមការ ងារជាព្រះនាង ; ទី ៥ – ព្រះស្រីការ ងារជាអ្នកម្នាង ; ទី ៦ – ព្រះកំណាន់ ងារជាអ្នកនាង ។

រួមទាំងអស់ ហៅថា "ចៅចម" សុទ្ធសឹងមានព្រះរាជឱង្ការតាំងនាម, ឯស្រ្តីក្រៅអំពីនេះ ហៅថា "អស់នាំងអ្នក" ស្រ្តីទាំងអម្បាលនេះ បើមានព្រះរាជបុត្រនិងម្ចាស់ផែនដី ហៅថា "ព្រះអង្គម្ចាស់នាំងអស់ដូចគ្នា" បើចេញចុតហ្មាយឡាយព្រះហស្ត ឲ្យថាព្រះរាជបុត្រា-បុត្រី ព្រះអង្គម្ចាស់នេះ – នោះ តាមព្រះនាម តែមានយសថយជាងក្សត្រទីសម្ដេចក្នុងប្រការ ២ ត្រូវអង្គុយក្រោយ, ឯក្សត្រក្នុងប្រការ ៣ បើ

និងស្រដីនឹងក្សត្រជាទីសម្ដេចព្រះរាជ { ឱរស / ធីតា } ត្រូវនិយាយថា ទូលបង្គំ

ជាខ្ញុំៗម្ចាស់, ឆ្លើយថា ព្រះការុណាពិសេស, មែម្ចាស់ ។

ប្រការ ៤– ក្សត្រឯណា ជាសម្តេចឧភយោរាជក្តី ព្រះមហាឧបរាជក្តី យកខត្តិយកញ្ញាឯណាជាបាទបរិចារិកា ហើយមានពិធីព្រាហ្មណ៍ ថ្វាយទឹកក្លស់ ទឹកស័ង្ខ លើករាជអាសន៍រួមជាមួយនិងស្វាមី រីខត្តិយកញ្ញានោះ មានព្រះនាមហៅថា "សម្តេចព្រះមហេសី" បើពុំបានរួមរាជអាសន៍ និងព្រះស្វាមីទេ គឺអង្គុយទីដទៃ ហើយទទួលទឹកស័ង្ខ ហៅថា "ព្រះរាជទេពី" បើមានព្រះបិយបុត្រក្សត្រាក្តី-ក្សត្រីក្តី និង ថ្វាយព្រះនាមជា "សម្តេច" ក៏បាន តែត្រូវយកសេចក្តីក្រាបបង្គំទូលអម្ចាស់ផែនដី សូមព្រះរាជទានព្រះសុវណ្ណបត្រ បើទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានព្រះបរមរាជានុញ្ញាតទើបតាំងបាន និង តាំងដោយអំពើព្រះរាជហឫទ័យឯងពុំបាន, បើក្សត្រទី ឧភយោរាជ ឬមហាឧបរាជ យកស្ត្រីពុំមែនជាក្សត្រមកធ្វើជាបាទបរិចារិកា ទ្រង់ព្រះរាជទានបរមរាជានុញ្ញាត ឲ្យតាំងដោយព្រះអង្គឯងបាន តាំងអំពីទីព្រះ, ទីក្រមការ ចុះមក, បើមានព្រះ { ឱរស / ធីតា } ហៅថា ព្រះអង្គម្ចាស់តាំងអស់ ដូចព្រះរាជបុត្រម្ចាស់ផែនដី តែយសថយជាងព្រះរាជបុត្រម្ចាស់ផែនដី ត្រូវអង្គុយក្រោយព្រះរាជបុត្រម្ចាស់ផែនដី ឯព្រះ

រាជបុត្រក្សត្រ ទីព្រះមហាឧបរាជ ត្រូវអង្គុយក្រោយព្រះ { ឱរស / ធីតា } ក្សត្រទីព្រះឧភយោរាជ ដៀតយសថយជាងក្សត្រឧភយោរាជ, ឯព្រះអង្គម្ចាស់ជាព្រះ { ឱរស / ធីតា } ក្សត្រទាំងពីរព្រះអង្គ ដូចមានព្រះនាមមកនេះ បើនឹងចេញចុតហ្មាយឲ្យាយព្រះហស្ត ដាក់ថាចុតហ្មាយព្រះរាជបុត្រា ឬព្រះរាជបុត្រីព្រះអង្គម្ចាស់នេះ ដូចព្រះរាជបុត្រក្សត្រទ្រង់រាជ្យជាអម្ចាស់ផែនដី ពុំបាន ។

ប្រការ ៥– បើក្សត្រទីសម្តេចជាព្រះរាជបុត្រក្សត្រទ្រង់រាជ្យក្តី ឬព្រះរាជបុត្រក្សត្រឧភយោរាជ, ឧបរាជក្តី យកស្តេចក្សត្រីខត្តិយកញ្ញាឯណាទីព្រះអង្គម្ចាស់ ជាបាទបរិចារិកា ហៅថា "ព្រះទេពី" បើមានបិយបុត្រក្សត្រា ហៅថា "ព្រះឱរស" បើជាក្សត្រី ហៅថា "ព្រះធីតា" ព្រះអង្គម្ចាស់នេះ-នោះ ដូចព្រះរាជបុត្រក្សត្រទីព្រះឧភយោរាជ ព្រះមហាឧបរាជ ឲ្យយសថយជាងក្សត្រព្រះ { ឱរស / ធីតា } ក្សត្រទាំងពីរ គឺសម្តេចព្រះឧភយោរាជ ព្រះមហាឧបរាជ ដូចចេញព្រះនាមមកនេះ តែត្រូវអង្គុយបន្ទាប់ក្សត្រ ជាព្រះ ឱរស – ធីតា ព្រះមហាឧបរាជ, បើក្សត្រទីសម្តេចយកខត្តិយកញ្ញាឯណាទីអ្នកអង្គម្ចាស់ជាបាទបរិចារិកា ហៅថា "ព្រះ

ជាយា » បើមានព្រះ { ឱរស / ជីតា } ហៅថា "អ្នកអង្គម្ចាស់."

បើយកស្រ្តីក្រៅពាកខត្តិយកញ្ញា គឺអ្នកកដវង្សក្តី ឯបុត្រសេនាបតីចតុស្តម្ភក្តី ពុំ បុត្រមន្ត្រីទូវបុត្រអាណាប្រជាជនតាំងតួង មកធ្វើជាបាទបរិចារិកា ហៅថា "អ្នកម្នាង" បើមានព្រះ ឱរស - ជីតា ហៅថា "អ្នកអង្គម្ចាស់" ដូចគ្នា ។

ប្រការ ២ – បើក្សត្រទីព្រះអង្គម្ចាស់ យកខត្តិយកញ្ញាឯណាទីព្រះអង្គម្ចាស់ដូចគ្នាជាបាទបរិចារិកា ហៅថា "ព្រះជាយា" បើមានព្រះបុត្រជាក្សត្រា ហៅថា "ព្រះឱរស" ជាក្សត្រី ហៅថា "ព្រះជីតា" ទីព្រះអង្គម្ចាស់ដូចព្រះវរ { បិតា / មាតា } ដោយហេតុមានជាតិស្មើគ្នា,

បើយកស្ត្រីទីអ្នកអង្គម្ចាស់ ជាបាទបរិចារិកា ហៅថា "ជាយា" បើមានព្រះបុត្រ ហៅថា ព្រះ { ឱរស / ជីតា } តែជាទីអ្នកអង្គម្ចាស់ ព្រោះព្រះមាតាជាតិពុំស្មើនឹងព្រះបិតា, បើយកស្ត្រីជាអ្នកកដវង្សក្តី ព្រះវង្សក្តីឬបុត្រសេនាបតីទូវបុត្រប្រជាជនតាំងតួងជាបាទបរិចារិកា ហៅថា(អ្នកម្នាង)

បើមានបិយបុត្រឲ្យហៅថាព្រះ { ឱរស – / ធីតា } ដូចគ្នា តែជាទីអ្នកអង្គម្ចាស់ ។

ប្រការ ៧– បើអ្នកអង្គម្ចាស់យកក្សត្រីទីអ្នកអង្គម្ចាស់ដូចគ្នា ជាបាទបរិចារិកា ហៅថា "ជាយា" បើមានបិយបុត្រ ហៅថាព្រះ { ឱរស / ធីតា } ទីអ្នកអង្គម្ចាស់ដូចព្រះ { បិតា / មាតា } ដ្បិតមានជាតិស្មើគ្នាទាំងពីរ, បើយកស្ត្រីក្រៅពីទីអ្នកអង្គម្ចាស់ដូចគ្នា ជាបាទបរិចារិកា ហៅថា "សំរាប់", បើមានបិយបុត្រហៅថា ឱរស – ធីតា ជាទីអ្នករាជវង្ស, ឯទីអ្នករាជវង្សនេះ ពុំត្រូវប្រើពាក្យរាជសព្ទថា សោយ ថា ស្រង់ ឡើយ ត្រូវឲ្យនិយាយតាមពាក្យធម្មតា ។

ប្រការ ៨ – បើអ្នករាជវង្ស និងអ្នករាជវង្ស យកគ្នាជាស្វាមី–ភរិយា ហើយមានបុត្រ ឲ្យហៅថា បុត្រប្រុស បុត្រស្រី ជាទីអ្នករាជវង្សដូចមាតាបិតា ដ្បិតមានជាតិស្មើគ្នា, បើអ្នករាជវង្ស ទៅយកស្ត្រីទីព្រះវង្សក្តី ឬស្ត្រីមានជាតិទាបជាងក្តី ជាភរិយា ហើយមានបុត្រឲ្យហៅថា "ព្រះវង្ស"

ប្រការ ៩– បើព្រះវង្ស និង ព្រះវង្ស យកគ្នាជាស្វាមីភរិយា

ហើយមានបុត្រ ឲ្យហៅថា ព្រះវង្ស ដ្បិតមាតាបិតាមានជាតិស្មើគ្នា, បើជាព្រះវង្សទៅយកភរិយាក្រៅ ចាកព្រះវង្ស បើមានបុត្រ ត្រូវដាច់ក្រសែព្រះវង្ស និងហៅថាព្រះវង្សពុំបាន ដ្បិតមាតាបិតាមានជាតិពុំស្មើគ្នា ។ ៚—

( ចម្លងចេញពីក្បួនរាជសព្ទ )

— ផែនទីព្រះទីនាំងទេវាវិនិច្ឆ័យ នៅក្នុងព្រះបរមរាជវាំងចតុមុខ —



# ផែនទីពន្យល់ពីព្រះទីនាំងទេវាវិនិច្ឆ័យ

១– ព្រះទីនាំងចក្រាពត្តិ= ព្រះក្រឡាបន្ទំព្រះករុណា

២– ព្រះទីនាំងនារីរតន៍សោភា= ព្រះក្រឡាបន្ទំសម្តេចព្រះអគ្គមហេសី ។

៣– ព្រះទីនាំងហោគ្រៀងភោជា= កន្លែងព្រះស្ងោយ

៤– ព្រះទីនាំងព្រះមហាមន្ទីរ=កន្លែងព្រះមហាស្វេតច្ឆ័ត្រគុនជាទីគំនាល់សំរាប់ព្រះរាជវង្សានុវង្ស ក្សត្រី – ចៅជិត-ចៅចម – ជំទាវ – ខុនណាង ។

៥– ព្រះទីនាំងឧកាញ្ញណា= កន្លែងសំរាប់ព្រះរាជទានសេនាបតី ភ្ញៀវបរទេស – និង មន្ត្រីផ្សេងៗ ក្រាបបង្គំគាល់ ។

៦– ព្រះទីនាំងទេវាវិនិច្ឆ័យ = ខាងមុខព្រះមហាស្វេតច្ឆ័ត្រ សំរាប់ទទួលភ្ញៀវធំៗ – ទទួលសារតាំង និង ធ្វើព្រះរាជពិធីផ្សេងៗ ។

៧– ហោព្រះពុទ្ធរូប = បន្ទប់តម្កល់ព្រះពុទ្ធរូប និង ព្រះត្រៃបិដក ។

៨– ហោព្រះអដ្ឋិ = បន្ទប់តម្កល់ព្រះអដ្ឋិអម្ចាស់ផែនដី និង ព្រះរាជវង្សានុវង្ស ខ្មែរ ដែលពុំទាន់បានហែទៅបញ្ចុះក្នុងព្រះចេតិយ ។

៩– ព្រះមហាស្វេតច្ឆ័ត្រ និង ព្រះរាជបល្ល័ង្ក

# ព្រះរាជពិធីឡើងព្រះទីនាំងព្រះមហាមន្ទីរ ជាប់និងព្រះទីនាំងឧក្យណា ពីខាងក្រោយ

ថ្ងៃសុក្រ ៣ កើត ខែទុតិយាសាឍ ឆ្នាំរោងសំរឹទ្ធិស័ក ព.ស. ២៤៧២ ត្រូវនិងថ្ងៃទី ២០ កក្កដា គ.ស.១៩២៩ ។

រសៀលម៉ោង ៤ រៀបព្រះរាជពិធីឡើងព្រះទីនាំងព្រះមហាមន្ទីរ ។

## របៀបចាត់ការ

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងស្ដេចយាងចេញពីព្រះរាជដំណាក់ច័ន្ទ មកឡើងព្រះមហាមន្ទីរតាមមាគ៌ាដែលក្រាលកន្ទេលនិងសំពត់ស ។

១– ឧកញ៉ាវង្សាពេជ្ជ ចាងហ្វាងព្រះរាជបណ្ឌិត្យ និមន្តព្រះពុទ្ធរូប តម្កល់លើព្រះសុដ្ឋិការ(១)ប៉ាំងព្រះក្ងស់ពណ៌ស ខាងមុខ ។

២– សម្ដេចព្រះឥសីភទ្ទធិបតី ចាងហ្វាងបារគូបុរោហិត, ព្រះព្រហ្មធិរាជបារគូ, ឧញ៉ាហោរាធិបតី ចាងហ្វាងហោរាសាស្ត្រ ខាង-ក្រោយព្រះពុទ្ធរូប ។

៣– ឧកញ៉ាកោសាធិបតី និង ឧកញ៉ាព្រះឃ្លាំងធិបតី "នាយឃ្លាំង" អញ្ជើញភ្លុកដំរី ១ គូ តម្កល់លើព្រះសុដ្ឋិការ ។

---

១– ព្រះសុដ្ឋិការ = ពោក ( ពាក្យរាជសព្ទ ) ។

៤– ឧកញ៉ាបវរនាយក ( នាយឃ្លាំង ) អញ្ជើញ ខ្លុយ ១ គូ តម្កល់លើព្រះពានមាស ហែក្រោយ ឧកញ៉ាហោរាធិបតី ។

( របស់តាំងនេះជាគ្រឿងត្រជាក់ត្រជុំ ចំរើនព្រះសិរីសួស្ដីជ័យមង្គលថ្វាយ ) ។

៥– ស្ត្រីកែវម្នាក់ សៀតសារបាប់ស ឬ "ល្បើក" សំឡុយ ពានាគាគស ប៉ាន់គ្លិប(១) អញ្ជើញព្រះខម្រង់អសុឡ(២) ហែក្រោយព្រះករុណា ។

៦– ស្ត្រីតាំង ៤ ទីប ( ៤ នាក់ ) សៀតសំពត់សារបាប់ព័ណ៌ ឬ "ល្បើកព័ណ៌" ពានាព័ណ៌លឿង កាន់ផ្កាមាស-ប្រាក់, ហែតមកក្រោយទៀត ( ស្ត្រីតាំង ៤ នាក់នេះ ត្រូវរើសយកកូនព្រះរាជត្រកូលប្រកបដោយលក្ខណៈល្អ ) ។

៧– ស្ត្រីម្នាក់ សៀតសារបាប់ ឬ "ល្បើក" សំឡុយ ពានាគាគស ប៉ាន់គ្លិប អញ្ជើញព្រះពានមាសតម្កល់ថវិកា(៣) សារបាប់ដាក់ត្បូងផ្សេងៗ

---

១– ប៉ាន់គ្លិប = សំពត់ជាក់ធរខ្សែសយ ឬ ចំណាយខ្សែសយ ។

២– អសុឡ = លំពែងផងវែង មានចុងក្រោមកន្ទុយជាមុរីនៅបៀង ក៏គោកខ្វែងដែលភ្ជាប់នឹងដង ។

៣– ថវិកា = ចង់ (ពាក្យភាសត្ថ) ។

៨- ស្រីម្នាក់ សៀកពាក់ដូចខាងលើនេះ អញ្ជើញព្រះពាន តម្កល់ថវិកាសារបាប់ ដាក់សុវណ្ណ ។

៩- ស្រីម្នាក់ សៀកពាក់ដូចគ្នា អញ្ជើញព្រះពាន តម្កល់ថវិកាសារបាប់ ដាក់រាជតេជៈ ។

១០- ស្រីម្នាក់ សៀកពាក់ដូចគ្នា អញ្ជើញព្រះពាន តម្កល់មណីសិលាបិទមាស ។

១១- ស្រីម្នាក់ សៀកពាក់ដូចគ្នា អញ្ជើញព្រះពាន តម្កល់ត្រឡាបបិទមាស ។

១២- ស្រីម្នាក់ សៀកពាក់ដូចគ្នា អញ្ជើញព្រះពាន តម្កល់ថវិកាដាក់ល័ក្តជុំគន្ធបិទមាស ។

១៣- ស្រីម្នាក់សៀកពាក់ដូចគ្នា បីនាងវិទ្យាធ្លាញី ពាក់ដីដាំត្បូង-ពេជ្រ ទទឹមមរកត ។

១៤- ស្រីម្នាក់ សៀកពាក់ដូចគ្នា អញ្ជើញគ្រឿងសំរាប់ព្រះរាជឥស្សរិយយស ព្រះមហាក្សត្រ ។

១៥- ព្រះរាជវង្សានុវង្សក្សត្រី និង ស្រីស្នំ - ក្រម្ការ ខ្ញុំរាជការស្រីជំទាវ ខុនណាង គ្រប់ក្រុម ហែតាម ។

១៦– ខាងលើ មុកញ៉ាមហាមន្ត្រី, មុកញ៉ាមហាទេព ស្លៀកសំពត់ ពាក់អាវសារបាប់ និងអាវផាយ ពាក់លំផក[១] ។

១៧– ព្រះព្រហ្មាធិរាជ, ព្រះជយាធិបតី, ព្រះមន្ទ្រធិបតី, ព្រះធម្មរាជ បារគូទាំង ៤ នាក់នេះ ស្លៀកស ពាក់អាវផាយស តំណាងទេវតា ឈរចាំនៅព្រះសោបានៈ[២] ព្រះទីនាំងមហាមន្ទីរ, មាន "ចំអាប ១ គុ, បន្ថែម ១ គុ", "ក្បាលជ្រូកស្ងោរ ១ គូ" ជូនទេវតាដែលរក្សាព្រះសោបានៈ ។

លុះក្បួនទៅដល់

សម្តេចព្រះឥសីភទ្ធធិបតី និងមុកញ៉ាហោរាធិបតីបានហ្វាង សូត្រប្រកាសទេវតាថា:

កោណ្ដា ទេវ សង្ឃា យោ , បពិត្រអស់ពពួកទេវតាដ៏ចំរើន ! បានអញ្ជើញមកសន្និបាតប្រជុំព្រមក្នុងទីស្ថាននេះហើយ ឬ នៅណា ?

តំណាងទេវតាទាំង ៤ ឆ្លើយថា:

យើងបិតនៅរក្សាព្រះមហាស្វេតច្ឆត្រ និង ព្រះមហាមន្ទីរ ក្នុងព្រះ

---

១ - លំផក = ប្រដាប់ពាក់នៅក្បាល ធ្វើដោយសំពត់ស្ពាប់ មានកំពូលស្រួច សម្រាប់ពាក់ក្នុងពិធីធំៗ មានពិធីបំបួសនាគជាដើម ។

២– ព្រះសោបានៈ = ជណ្ដើរ ឬ បង្អោង ។

បរមរាជវាំងនេះជាទិព្វ មិនបានទៅណាទេ ៗ អ្នកមានការអ្វី ចូរថ្លែងសេចក្តីមក?

ទើបសម្តេចព្រះឥសីកទ្ធធិបតី និងឧកញ៉ាលោកធិបតី តាងហ្វាង ឆ្លើយថា:

–យើងខ្ញុំហៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះនាមព្រះបាទសម្តេចព្រះស៊ីសុវត្ថិ- មុនីវង្ស ចមចក្រពង្សហរិរាជបរមិន្ទ្រ ភូវណៃយ ក្រៃកែវហ្វាសុពល័យ ព្រះចៅក្រុងកម្ពុជាធិបតី ស្តេចព្រះរាជដំណើរ មានគ្រឿងឥស្សរិយយស គ្រប់តាមទំនៀមព្រះមហាក្សត្រិយ៍ មកឡើងព្រះទីនាំង ព្រះមហាមន្ទីរ ជាទីគង់ក្រោមព្រះមហាស្វេតច្ឆត្រ ទ្រង់គ្រងរាជសម្បត្តិ ជាអម្ចាស់ជីវិតលើត្បូង ៗ

–យើងខ្ញុំ សូមទេវតា ចំរើនព្រះជន្មវស្សា ថ្វាយឲ្យបាន ១០០ ព្រះវស្សា ជាសុខក្សេមក្សាន្តឋិតថេរបេរកាលតទៅ!, បើទេវតាយល់ថាវេលានេះ “ជាមហាវិជ័យមង្គល មានឫក្សជោគ ចូរសម្តែងប្រាប់មក!” ៗ

ទេវតា ឆ្លើយថា:

– យើងឋិតនៅព្រះមហាមន្ទីរ និង ព្រះមហាស្វេតច្ឆត្រ ក្នុងព្រះបរម-រាជវាំងនេះ បម្រុងថ្វាយព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ - មុនីវង្ស ស្រេចហើយ ៗ

– វេលានេះ ជាថ្ងៃមង្គលឫក្សល្អ ។

– យើងជាទេវតា សូមថ្វាយព្រះមហាស្វេតច្ឆត្រ និង ព្រះមហាមន្ទីរឋាន សូមអញ្ជើញស្ដេចឡើងគង់ តាមសព្វព្រះរាជហឫទ័យ, សូមចំរើនសុខសួស្ដីជ័យមង្គលមហាប្រសើរ, សូមថ្វាយព្រះជន្មាយុឲ្យបាន១០០ ព្រះវស្សា គ្រងរាជសម្បត្តិ រក្សាព្រះពុទ្ធសាសនា និង ច្បាប់ទម្លាប់ទំនៀមព្រះនគរ ព្រះរាជវង្សានុវង្ស ព្រះសង្ឃ ក្រុមារ សេនាបតីនាហ្មឺនសព្វមុខមន្ត្រី កវីបណ្ឌិត ព្រាហ្មណ៍ពិទ្ធ ហោរាចារ្យ ដំណាវខុនណាង និង បណ្ដាក្សត្រ ឲ្យបានប្រកបដោយនូវសេចក្ដីសុខ មហាប្រសើរ ឋិតថេរបវរកាលតទៅ ។

– សម្ដេចព្រះឥសីគន្ធ និង ខុកញ៉ាហោរាធិបតីវាំងហ្វាំង ទទួលស័ព្ទសាធុការពរ

ហើយក្រាបបង្គំទូល អញ្ជើញព្រះករុណា ទ្រង់ស្ដេចយាងឡើងតាមព្រះសោបាន: ។

– ព្រាហ្មណ៍ផ្លុំស័ង្ខ–ខ្ទង់គងជ័យ–ប្រគុំឬត្រី–ពិណពាទ្យ ។

ទើបអ្នកខុកញ៉ាពិជ័យរណៈរៀងជ័យ ចេញមកទទួល ក្រាបថ្វាយបង្គំអញ្ជើញស្ដេចយាងចូលទៅក្នុងព្រះមហាមន្ទីរ គ្រឡាព្រះបន្ទំ " ព្រះទីនាំង

ចក្រពត្តិ ៗ ទ្រង់ទតសព្វគ្រប់តាមព្រះរាជហឫទ័យ រួចស្ដេចយាងចេញ ទ្រង់ព្រះសណ្ដាប់ព្រះសង្ឃចំរើនព្រះបរិត្ត ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ។

ព្រះរាជវង្សានុវង្ស ក្សត្រី-ក្សត្រា ព្រះស្នម ក្រមការ ជំទាវ-ខុនណាង សេនាបតី នាហ៊ឺនសព្វមុខមន្ត្រី ដែលហែជាក្បួនទាំងប៉ុន្មាន ក៏ហែចេញ តាមទៅទាំងអស់ ទៅកាន់ទីកន្លែង ដែលក្រុមព្រះរាជមន្ទីរ រៀបចំចាត់ទុក ជាមុនស្រាប់ ។

– ចប់ព្រះបរិត្ត ក្បួនហែយាងចូលព្រះមហាមន្ទីរវិញ ។

– ព្រះរាជវង្សានុវង្ស-ព្រះស្នម ក្រមការ-ជំទាវ-ខុនណាង-សេនាបតី នាហ៊ឺនសព្វមុខមន្ត្រី ក្រាបថ្វាយបង្គំលា ។

ចប់ព្រះរាជពិធីតែប៉ុណ្ណេះ

ព្រះរាជពិធីនេះ គ្រាន់តែជូនជ្រាបពីរបៀបឡើង ព្រះរាជតំណាក់នៃព្រះមហាក្សត្រយើងប៉ុណ្ណោះ ។ ឯរបៀបយើងជាជនសាមញ្ញ សំរាប់ពិធីឡើងផ្ទះថ្មី ខ្ញុំនឹងរៀបចំជូនទៅខាងចុង ។

## របៀបក្បួនហែឡើងព្រះតំណាក់

១– ព្រះឆុទ្ធរូប

២– ចាងហ្វាងបារគូ· ព្រះព្រហ្មាធិបតី· ចាងហ្វាងហោរា

៣– មន្ត្រីអញ្ជើញកុកដំរី ១ គូ ២ នាក់

៤– មន្ត្រីអញ្ជើញកុយ ១ នាក់

### ព្រះករុណា

៥– ស្រីកែវ កាន់ព្រះខ្ទមធំអសុឡី

៦– ស្រីកាន់ផ្កាមាស ២ នាក់

៧– ស្រីកាន់ផ្កាប្រាក់ ២ នាក់

៨– ស្រីកាន់ថវិកាត្បូង ១ នាក់
៩– ស្រីកាន់ថវិកាសុវណ្ណ ១ នាក់
} គូគា

១០– ស្រីកាន់ថវិកា ព្រះតេជះ ១ នាក់
១១– ស្រីកាន់ព្រះពានសិលាបិទមាស ១ នាក់
} គូគា

១២– ស្រីកាន់ព្រះពានត្រឡាចបិទមាស ១ នាក់
១៣– ស្រីកាន់ថវិកាល័ក្តបិទមាស . . . ១ នាក់
} គូគា

១៤- ស្រី បន្ទាញ . . . . . . . . . . . . . . ១ នាក់
១៥- ស្រី អញ្ជើញគ្រឿងឥស្សរិយយស ១ នាក់ } គូគា

១៦- ព្រះរាជវង្សានុវង្ស

១៧- ខ្ញុំរាជការប្រុស - ស្រី (ចៅផត, ចៅបម, ជំទាវ, ខុនណាង មន្ត្រី ធំ - តូច) ។

ក្រោយព្រះករុណា រៀបជាគូតាំងអស់ទើបប្រមើល

# ភាគទី២

## សេចក្តីអធិប្បាយសំរាប់សាមញ្ញជន

ក្បួនអាពាហ៍ពិពាហ៍មង្គលការនេះ មុននឹងបោះពុម្ព ខ្ញុំបានពឹងសហជីវិន ឈួន-ប៊ុត ជាមិត្រខ្ញុំ ឲ្យជួយត្រួតមើល រិះគន់ សេចក្តីផ្តាំផ្ញើ ឃ្លាល្បះ អក្ខរៈ ព្យញ្ជនៈ ដែលមិនត្រឹមត្រូវ តាមក្បួនច្បាប់ អក្សរសាស្ត្រខ្មែរ និងបាលី ។

# រឿងវិវាហមង្គលការខ្មែរជាតិ

អ្នកឧកញ៉ាមហាវិធិប្ប័យ ចាងហ្វាង “ចៅ” វិត្រេត

បានរៀបរៀងតាមសម័យថ្មី និង បែបចាស់ ទុកជាសណ្ដាប់តទៅ

ព. ស. ២៤៦៨ គ. ស. ១៩២៥

ឆ្នាំឆ្លូវសប្តស័ក

ក្រុងភ្នំពេញ ចតុមុខ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

# បវត្តិវិភាគ

## រឿងរៀបវិវាហមង្គលការខ្មែរជាតិយើង

ដែលបានប្រព្រឹត្តធ្វើរៀងមកគ្រប់និគមជនបទ សឹងតែធ្វើតាមគ្នាជាតម្រាប់តៗមក ដល់បច្ចុប្បន្ននេះ ហើយសឹងតែប្រកាន់ថា ធ្វើតាមច្បាប់ក្បួនពីបុរាណគ្រប់ៗគ្នា តែច្បាប់ក្បួនបុរាណនោះ ក៏ពុំសូវមានអ្នកណានឹងបានប្រទះឃើញ ៗ ទើបតែក្នុងសម័យនេះ ខ្ញុំបានឃើញច្បាប់ក្បួនចាស់មាននៅក្នុង ឃុំសំរោង ស្រុកភ្នំពេញ ក្រោមបង្គាប់លោកចៅហ្វាយខេត្តកណ្ដាល ៗ ខ្ញុំខ្ចីយកមកចំឡងទុកគ្រាន់ជាបែបផែន ហើយបានប្រៀបផ្ទឹមនឹងរបៀបដែលអ្នកនគរធ្វើក្នុងសម័យថ្មីនេះ ក៏ឃើញថាធ្វើតាមរបៀបចាស់មែន មានឃ្លៀងឃ្លាតខ្លះក៏មានបន្តិចបន្តួច ៗ

ឯរបៀបវិវាហមង្គលការនេះ តាមក្បួនច្បាប់ចាស់នោះ បទខ្លះអាងយកសណ្ដាប់តាម ព្រះវេស្សន្តរបរមពោធិសត្វ រៀបវិវាហមង្គលការព្រះរាជបុត្រា បុត្រី គឺ ជាលី និងនាង ក្រឹស្នា, បទខ្លះក៏អាងយកតាមរឿង រាមកេរ្តិ៍ គឺយកតាមសណ្ដាប់កាលព្រះរាម និង នាងសេតា រៀបវិវាហមង្គលការ ៗ ក្នុងគម្ពីរធម្មបទ ( សម័យពុទ្ធកាល ) ក៏មានរៀបវិវាហមង្គលការ បុណ្ណវឌ្ឍនសេដ្ឋី និង នាងវិសាខា ដែរ ។ល។

លុះត្រាក្រោយមកទៀត កាលរាជ្យព្រះបាទសម្តេច ព្រះជ័យចេស្តាភមាធិបតី ជាអម្ចាស់ជីវិត ទ្រង់បានតែងតាំងរៀបរ៉ៃហាមឃ្គលនេះ ទុកជាសណ្តាប់ធ្នាប់ក្បួនតមកទៀត, បានជាយើងកល់គ្នាយកសណ្តាប់តាមបែបនោះ ធ្វើតាមរៀងរាបដរាបមកដល់បច្ចុប្បន្ននេះ ។

តែក្បួនចាស់នោះ របៀបពាក្យពេចន៍ និង របៀបកិច្ចដែលធ្វើនោះច្រើនច្រឡូកច្រឡំមុនជាក្រោយ ក្រោយជាមុនក៏មាន ពុំពិរោះក្បោះក្បាយទាំងពាក្យអធិប្បាយក៏ពុំសូវបានសេចក្តី ។

ហេតុនេះ ទើបខ្ញុំរៀបរៀងឡើងវិញ ឲ្យសមតាមរបៀបនិយមសម័យថ្មី តែតម្រាយសេចក្តីយកតាមន័យក្បួនចាស់ ដែលបានពណ៌នាទុកមកទាំងអស់ និង មានបែកពីក្បួនចាស់ក៏ទេ ដើម្បីទុកជាសណ្តាប់ទំលាប់ទំនៀមតទៅដល់អ្នកស្រុកទាំងឡាយ ដែលនឹងធ្វើជាមេបាក្តី ធ្វើជាអ្នកផ្ញើ-អ្នកមហាក្តី គួរឲ្យចេះចាំរបៀបទំនៀមបុរាណគតិ ដែលលោករៀប-រៀងទុកមកទើបគួរ ព្រោះខេមរជាតិយើងនេះប្រកាន់ទំលាប់ទំនៀមណាស់ហេតុនេះគួរឧស្សាហ៍មើលឲ្យចេះចាំតាមន័យ ដូចមានអធិប្បាយតទៅ :

នេះជាសេចក្តីអធិប្បាយរបស់លោកឪពុកខ្ញុំ

## អារម្ភបទ

ខ្ញុំឧកញ៉ាមហាមន្ត្រី ញិកា-ឆ្នូវ បានទទួលអំណោយក្បួននេះពីលោកជាបិតា ក៏បានសុំក្បួនអំពីសំណាក់លោកថែមទៀត សូមសេចក្ដីបំភ្លឺពន្យល់អំពីកិច្ចផ្សេងៗ ដែលត្រូវប្រតិបត្តិឲ្យត្រឹមត្រូវតាមប្រវេណីពីបុរាណៗ លោកបិតាក៏មេត្តាណែនាំបំភ្លឺឲ្យយល់គ្រប់ពិធីពុំមានខ្វះខាត ។ ខ្ញុំបានកត់ចំណាំតាមទុកក្នុងសតិបញ្ញា ដើម្បីឧបត្ថម្ភញាតិមិត្រជិតឆ្ងាយ ដែលមកហៅរកយកទៅឲ្យជួយ នៅវេលាដែលមានអាពាហ៍ពិពាហ៍មង្គលការកូនចៅប្រុសស្រីតែពល់ ១ ឆ្នាំ ។

ខ្ញុំពុំបានគិតវែងឆ្ងាយថាប្រវេណីនេះ នឹងរលត់បាត់ទៅថ្ងៃក្រោយនោះ ទើបតាំងពីប្រហែលជា គ.ស. ១៩៤០ តមក របៀបរៀបចំកូនប្រុសស្រីឲ្យមានភរិយា-ស្វាមី បេះតែឃ្លាតបន្តិចម្ដងៗ ពុំប្រាកដថាខ្លួនរៀបអាពាហ៍ពិពាហ៍ យកតាមប្រវេណីជាតិណា, បេះតែថា : ខ្លះថាធ្វើឲ្យខ្លីស្រួល, ខ្លះថាធ្វើតែ ១ ពេលស្រួល, ខ្លះថាកុំ-និយាយវែងពេក, ខ្លះថាធ្វើត្រឹមឆេះឆាឆហើយ, ខ្លះឃើញព្រះរាជវង្សានុវង្សទ្រង់រៀបចំតាមរបៀបក្សត្រខត្តិយត្រកូល ខ្លួនជារាស្ត្រ យល់ប្រឡំថា ធ្វើបែបនេះវិញស្រួល, ភ្លេចគិតថា ខ្លួនជារាស្ត្រ មានប្រវេណីខុសពីវង្សក្សត្រនោះនោះ ។

ខ្ញុំឃើញការណ៍វិបត្តិកើតឡើងដូច្នេះ បានជាខ្ញុំរៀបចំក្បួននេះបោះពុម្ពផ្សាយចែកជូនញាតិមិត្រជ្រាប, ខ្ញុំនឹងរំលឹកហេតុដែលនាំឲ្យវិបត្តិកើតឡើងបណ្ដាលឲ្យបុរាណប្រវេណីខេមរជាតិខាងអាពាហ៍ពិពាហ៍ឃ្លៀងឃ្លាតខុសពីរបៀបចាស់, គឺមកពីអារ្យធម៌អឺរុប (La civilisation européenne) ផ្សាយចូលមកកាន់ប្រទេសកម្ពុជា នាំឲ្យយុវជនកូនខ្មែរជំនាន់ក្រោយលះបង់ចោលទម្លាប់ទំនៀមជីដូនជីតា ស្ទើរតែទាំងអស់ ។ ខ្មែរជាន់ចាស់គេមានសេចក្ដីអៀនខ្មាសណាស់ គេមិនបណ្ដោយឲ្យស្រី និង ប្រុសទៅប្រឡូកប្រឡំគ្នាតាមអំពើចិត្តឡើយ, គេមិនបណ្ដោយឲ្យក្រមុំ-កម្លោះ ដើរលេង ឬឈរនិយាយគ្នាលេងតែពីរនាក់ទេ ទោះជាស្ត្រីដែលមានប្ដីហើយក្ដី ក៏គេពុំសូវអាចហ៊ាននិយាយលេងកំប្លែងឡេះឡោះ ជាមួយ និងប្រុសឈ្មោលដទៃ ក្រៅពីប្ដីរបស់ខ្លួនឡើយ ។ សូម្បីតែនៅពេលព្រះរាជពិធីអ្វី ៗ មួយ នៅក្នុងព្រះបរមរាជវាំង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងគ្រប់ព្រះអង្គ ក៏ទ្រង់ព្រះរាជទានព្រះរាជសេវកាមាត្យ ឲ្យរៀបចំទីកន្លែងព្រះរាជទានខ្ញុំរាជការព្រះអង្គ ចូលក្រាបបង្គំគាល់ដោយខ្លួនពីគ្នា ប្ដីមានកន្លែង១ ភរិយាអស់លោកគឺ: ជំទាវ ខុនណាង មានកន្លែង១ដោយខ្លួន ៗ

« ហេតុដែលនាំឲ្យឃ្លាតចាកទម្លាប់ទំនៀមនេះ គឺឃ្លាតចេញមកពី

សាលារៀនជាដំបូង, ព្រោះនៅសាលារៀនមានរបៀបឲ្យសិស្សានុសិស្ស ស្រី-ប្រុស រៀនជាមួយគ្នា ។ ម្ល៉ោះហើយកិរិយាអៀនខ្មាសរវាង ក្រមុំនិងកម្លោះ ក៏ចេះតែបាត់ទៅៗ, ស្រីនិងប្រុសត្រឡប់ទៅជាមិត្រស្និទ្ធជិតដិតគ្នាដូចជាស្រីនិងស្រី ឬ ប្រុសនិងប្រុសដូច្នេះអស់ទៅ ។ រហូតដល់ទៅលេងរបាំរាំវែក ឱប រួបរឹត កៀកកើយគ្នា «dancing» ស្រីនិងប្រុស ប្រុសនិងស្រី ជិតដិតស្និទ្ធស្នាលនឹងគ្នា ឥតរួញរា ជាក្មេងកាមរាគ និងបណ្ដាលឲ្យទៅជាអ្វីទៀត ។

ឪពុកក្ដី ម្ដាយក្ដី ដែលមានប្រាថ្នាចង់ឲ្យកូនមានចំណេះចេះដឹង ជាមនុស្សមានមុខមានមាត់និងគេ ឬ និងបានជាវរជននិងគេក្នុងប្រទេស, ម្ល៉ោះហើយក៏ចេះតែប្រថុយសំណាងទៅ ថាសម្រេចនៅខ្លួនគេចុះ ។ ដល់បណ្ដែតបណ្ដោយ យូរៗទៅ, ឥឡូវនេះ ខ្លះទៅជាយកប្ដីខ្លួនឯង យកប្រពន្ធខ្លួនឯង ។ ម្ដាយឪពុកដាក់គេមិនព្រមយកទេ គេថាស្រេចនៅចិត្តគេទេតើ ដែលត្រូវរួមស្នេហ៍ រួមទុក្ខរួមសុខជាមួយគ្នាទៅអនាគត ពុំមែនឪពុកម្ដាយមកទទួលក័ព្យាសនាជំនួសគេទេ ។ មាតាបិតាខ្លះ គិតពុំជ្រៅទៅពុំឆ្ងាយ ទ័លគំនិត ក៏ទម្លាក់បន្ទុកចោលខ្លះទៅ ទើបអនុគ្រោះរៀបអាពាហ៍ពិពាហ៍ឲ្យតាំងទើសទ័លទៅ ។ លុះដល់ពេលនឹងចាត់ចែងតែងមង្គលការ ក៏ពុំបានពិចារណារកក្បួនតម្រាពីបុរាណ ឲ្យបាន

ហ្មត់ចត់ឡើយ, ថាណ្ហើយ / គ្រីសគ្រាសឲ្យតែហើយៗទៅ កុំឲ្យមានគាស្រូវដល់ក្តើរណ្ហោះ, មិនតែប៉ុណ្ណោះ មានខ្លះបណ្ដើរគ្នាដើរលេងមុនពេលដែលរៀបមង្គលការឲ្យ យើងជាចាស់ឃាត់គេពុំឈ្នះ ក៏ត្រូវតែបណ្ដោយទៅ ។

ទោសដូចមានបរិយាយមកទាំងអម្បាលនេះហើយ បានជាទម្លាប់-ទំនៀមខ្មែរ សំរាប់រៀបមង្គលការពីបុរាណមក ក៏ប្រែក្លាយឃ្លាតចាកពីក្បួនបុរាណអស់ ។

# បំណងមាតាបិតា

មាតាបិតា ឬ អាណាព្យាបាល ចិញ្ចឹមបុត្រធីតាមក បានចំរើនវ័យពេញក្រមុំ-កម្លោះ ហើយរមែងមានចិត្តគិតបង់ទុកដាក់កូនទៅឲ្យមានគូស្រករតាមប្រវេណី ដើម្បីនឹងបានតពូជពង្សវង្សត្រកូលតទៅទៀត ។ បង់ឲ្យកូនទៅបានថ្កុំថ្កើងជាវរជន ឬ ជាមន្ត្រី គហបតី មានសម្បត្តិទ្រព្យប្រកបសុខសាន្តសំរាន្តចិត្តប្តី និងប្រពន្ធ ។ មាតាបិតាគណាញាតិមានភារៈយ៉ាងសំខាន់ដែលត្រូវពិនិត្យឲ្យល្អិតល្អ ឲ្យត្រូវនឹងពាក្យបុរាណបានបង់ជាស្លោកទុកមកថា: “អាក្រាក់ក៏អាក្រាក់ចុះ ឲ្យតែល្អ, ក្រាក៏ក្រាចុះ ឲ្យតែមាន” នេះមានន័យថា “អាក្រក់តែរូប តែមានឫកពាកិរិយាមារយាទសណ្តាប់ធ្នាប់ល្អ, ក្រតែសម្បត្តិទ្រព្យ តែត្រង់ពូជអំបូរមិនថោកថយដុនដាបជាខ្ញុំកំដរគេឡើយ” ក៏ឯការដែលនឹងទុកដាក់កូនទៅផ្សងទាន អាចឲ្យគុណក៏មាន ឲ្យទោសក៏មាន គឺបើទុកដាក់ទៅលើមនុស្សមានគុណសម្បត្តិគ្រប់ខ្នង ជាអនុជាតបុត្រ ឬ ជាអតិជាតបុត្រ គឺជាភ័ព្វព្រេងដ៏ប្រសើរ តែងបានសុខសប្បាយ រីករាយ រុងរឿង ចំរុងចំរើនតទៅ ។ បើប្រទះប៉ះទៅលើពាលមានសន្តានចិត្តជ្រោកជ្រាកជាអវជាតបុត្រ ទាបថោកបំផុត ដោយប្រព្រឹត្តក្រៅគន្លងធម៌នោះ ។

រមែងចង្អិនបង្ហោចទ្រព្យធនធានគ្មានចំរើនសោះ ក៏ធ្លាក់ទៅជាមនុស្សទាបថោកក្រីក្រលំបាកតោកយ៉ាក ក្តៅក្រហាយឥតសប្បាយគ្រប់ពេលវេលាក្រីជាអចិន្ត្រៃយ៍ ជួនកាលមានអន្តរាយដល់ទៅលែងលះគ្នាទៅក៏សឹងមាន ។

ហេតុនេះ មាតាបិតាកាលទុកដាក់កូនចៅឲ្យមានភរិយា - ស្វាមី គេតែងគិតដល់ ពូជពង្ស, ភរិយាមារយាទ, ឆ្នាំ-ខែ-ថ្ងៃ,ធាតុ និង សមពង្ស ជាប្រមាណ តាមពាក្យបុរាណាចារ្យចងទុកជាសុភាសិតថា “ ធ្វើស្រែ មើលស្មៅ ទុកដាក់កូនចៅ មើលផៅសន្តាន ” ព្រោះលោកយល់ថា ធ្វើស្រែមានខុស ១ ឆ្នាំ ត្រូវ ១ ឆ្នាំ, ឯដំណើរមានប្តីប្រពន្ធ តែខុសហើយ រមែងខុសមួយជីវិត ។ មានភាសិតមួយបទទៀតថែងថា: “ បើរើសនាង ឲ្យគន់មើលម្ដាយដង បើចង់ឲ្យហ្មត់ហ្មង ឲ្យមើលដល់ជីដូនទៀត ” ភាសិតនេះ ខ្ញុំបានទទួលផ្ទាល់អំពីព្រះរាជឧក្ការ សម្តេចព្រះសង្ឃរាជ ថ្នាក់ទីមួយ (ខ្លួន-ប៊ុត) ។

អាស្រ័យខ្លាចឲ្យទោសដូចបានពោលមកខាងលើនេះហើយ បានជាលោកបង្កើតឲ្យមានប្រពៃណី ដណ្តឹងរៀបមង្គលការ ដោយសេចក្តី

ព្រមព្រៀងជាការៈលើមាតាបិតា ឬ អាណាព្យាបាល ពុំមែនកូនចៅជ្រើសរើសយកប្ដីប្រពន្ធតាមតែទំនើងចិត្តខ្លួនឯងនោះទេ ។

រឿងរៀបមង្គលការនេះ លោកចែកញែកជា ២ យ៉ាងគឺ:

អាវាហមង្គល ១, វិវាហមង្គល ១

បើអ្នកគ្រប់គ្រងកូនប្រុស ទៅដណ្ដឹងកូនស្រីបានហើយៗ នាំយកមករៀបមង្គលការខាងឯផ្ទះប្រុស លោកឲ្យហៅថា វិវាហមង្គល ។

បើអ្នកគ្រប់គ្រងកូនស្រី ព្រមព្រៀងតាមសេចក្ដីដណ្ដឹងពីខាងប្រុស ហើយ ៗ ព្រមឲ្យយកកូនប្រុស ចូលមករៀបមង្គលការខាងឯផ្ទះស្រី លោកឲ្យហៅថា អាវាហមង្គល ។

តែសព្វថ្ងៃនេះ ថែកពេក លោកអ្នកធ្វើសំបុត្រអញ្ជើញភ្ញៀវមកជាកិត្តិយស(១)លៀងក្រយាហារ ក្នុងឱកាសរៀបមង្គលការកូនចៅលោកៗ តែងសរសេរសំបុត្រហៅភ្ញៀវ ដាក់ចំណងជើងថា: " អាវាហវិវាហមង្គល ឬថា អាពាហ៍ពិពាហ៍ " គឺបានសេចក្ដីថា " រៀបការនៅលំនៅតាំងសងខាង " ។

---

១– មានខ្លះពោះសំបុត្រការដាក់ថា " អញ្ជើញភ្ញៀវទៅជាអធិបតី " នោះខុសទេ ត្រូវថា: " ទៅជាកិត្តិយស " វិញ ទើបត្រូវ។ បើយើងអញ្ជើញភ្ញៀវរាប់រយ ទៅជាអធិបតីទាំងអស់គ្នានោះ ៗ មិនដឹងជាអ្នកណាស្ដាប់អ្នកណាទេ បើសុទ្ធតែធំទាំងអស់គ្នាទៅហើយ ។

# ពិធីរៀបមង្គលការ

## វគ្គទី ១

• ១– ខាងសំដែងអំពីរបៀបកិច្ច ដែលនឹងរៀបមង្គលការ, បណ្ដាជនានុជននឹងរៀបបុត្រ ប្រុស - ស្រី ឲ្យជាសម្ពន្ធសង្វាសជាភរិយា-ស្វាមី និងគ្នា ដោយមាតាបិតាទាំងសងខាង ព្រមព្រៀងគ្នាហើយ ទើបត្រូវរៀបជារបៀបចេញមុខ ដូចមានអធិប្បាយខាងក្រោមនេះ ។

ដើមឡើយត្រូវឲ្យមាតាបិតាខាងកូនប្រុស ពឹងពុំនិង រកស្រីចាស់ទុំម្នាក់ ដែលជាអ្នកមុខ-ការ មានគូស្រករ មិនដែលអភ័ព្វ ហៅថាអ្នកចែចូវ ក្បួនចាស់ ហៅថា អ្នកឃ្នាយ ឲ្យទៅដល់មាតាបិតា-មេបាខាងកូនស្រី ៣ ដង, តែមុននឹងទៅ ត្រូវឲ្យដំណឹងទៅមាតាបិតាខាងស្រីដឹងជាមុនសិន ។

### របៀបនិយាយចែចូវ

១– ដើមមុន ឲ្យអ្នកចែចូវ ឡើងទៅ ជំរាបមេបាខាងស្រីថា «សូមទានជំរាបអស់លោក ជំទាវ ខុនណាង ត្រកូលរាមបង្វែ មេបាធំ-តូច សូមទានជ្រាប», ឲ្យនិយាយជាពាក្យគួរសមយ៉ាងនេះជំរាបជាមុន ទើបរាយសេចក្ដីថា "ដ្បិតលោក...អ្នក...( ឲ្យចេញនាម

ឬឆ្នាំ) ពឹងខ្ញុំឲ្យមកជំរាបលោក . . . អ្នក . . . ថា " សព្វថ្ងៃនេះ មានចិត្តគិតនឹកប្រតិព័ទ្ធស្ម័គ្រស្រឡាញ់លោក - អ្នកណាស់ ចិត្តចង់មកលេងឲ្យស្គាល់ នឹង បានជាសម្ពន្ធមិត្តដ៏ស្និទ្ធតទៅ តែក្រែងចិត្តលោក - អ្នកឯណោះមិនសន្តោសប្រោសឲ្យទៅមក បានជាពឹងខ្ញុំឲ្យមកប្រណិប័តន៍បង់ជីងប្រសាសន៍ តើនឹងជាដូចម្តេច ?

មាតាបិតាខាងស្រីតបថា " ស្រេច នឹង លោក - អ្នក ខាងណោះបើចិត្តស្មោះចំពោះនឹកចង់មកលេងនឹងខ្ញុំ ៗ ក៏មានអំណរដែរ តែខ្ញុំគ្មានកំស្តុរបស់អ្វីជាសមគួរ នឹងតបសេចក្តីបដិសណ្ឋារៈវិញទេ " ។

២– ជើងបន្ទាប់ ឲ្យនិយាយចេញឈ្មោះសាមីដើមការ ពឹងខ្ញុំឲ្យមកជំរាបថា: " ដ្បិតឮថា: លោក . . . អ្នក . . . មានស្រែដើងស្រុកាសំបុកាដើងលាន មានជាតិដីដីល្អ , លោក - អ្នក ឯណោះចង់យកពូជស្រូវមកសាបព្រោះផង ក្រែងបានប្រកបបានពូជធារតទៅ, តើប្រសាសន៍នឹងមេត្តាដូចម្តេច ? "

មេបា ខាងស្រីថា: " ស្រែខ្ញុំនោះបីល្អអាក្រក់ មានមែនក្រែងតែពុំប្រកបន្លា តែបើអ្នកអាល័យ ឲ្យមកញីកា ៗ បើអ្នករលីក ឲ្យមកម្តង ៗ " ។

៣– ជើងក្រោយ ឲ្យរៀបស្លាម្លូ បន្តិចបន្តួច តាមគួរសម យកទៅជាមួយផង, ឲ្យដំកបចេញឈ្មោះដូចមុនថា "កាលដើមមុនមានប្រសាសន៍ថា: "បើអាល័យ ឲ្យមកញឹកៗ បើរលឹក ឲ្យមកម្ដងៗ" ឥឡូវអ្នកឯណោះ ថា: បើ „លោក-អ្នក មេត្តារាប់អានសូមកុំកយទឹងដើរទៅមក គួរពុំគួរសូមអភ័យទោស" ។

មេធា ខានស្រីថា: "ផ្លូវ អ្នកដដែលនាំផ្លូវ តែងដើរ ជាប្រក្តីរ អ្នកដដែលនាំផ្លូវ តែងឡើង" ខ្ញុំមិនដឹងជាថាដូចនេះទេ ស្រេចតែអ្នកឧស្សាហ៍ទៅមកគង់តែនឹងដឹង" ។

ចប់ខែចូរ ៣ ជើងតែប៉ុណ្ណោះ

# របៀបនិយាយដណ្ដឹង

១ ២- លំដាប់តមកទៀត ត្រូវឲ្យមាតាបិតាខាងប្រុស រកស្រីអ្នកមុខអ្នកការ ៣ នាក់ ដែលមានគូស្រករមិនដែលអត់ត្ង ឲ្យធ្វើជាអ្នកថ្វីទៅសុំដណ្ដឹង ៣ ដើងទៀត ត្រូវឲ្យរៀប "រង់សម្លាប(១) ១" ក្រាលកន្ទេលបញ្ចូពណ៌ណិរៀបប្រអប់គ្រឿងគ្រប់ប្រដាប់ ព្រមទាំងស្លាម្លូ ទិង បណ្ណាការតាមគួរសម ហើយឲ្យអ្នកថ្វីស្រីទាំង ៣ នាក់ នាំបណ្ណាការទៅជូនមេបាខាងស្រី ត្រូវនិយាយដូចមានខាងក្រោមនេះ ៖

"ត្រូវជូនពត៌មានទៅខាងស្រី សុំពេលវេលាជាមុន"

១- ដើងមុន ឲ្យជំរាបប្ដឹងមេបាស្រី ថា "សូមទាន សូមជំរាបអស់លោកមេបា ជំទាវ ខុនណាង ត្រកូលវៀមបង្ស សូមជ្រាបដ្បិត (ឲ្យបញ្ចេញនាម ឬ ងារមាតាបិតាខាងប្រុស) ពីងខ្ញុំទាំង ៣ នាក់ ឲ្យជា អ្នកការថ្វើ នាំកិច្ចការបណ្ណាការ មកជូនលោកមេបា សុំស្គាល់សុំស្រឡាញ់ ជាសម្ពន្ធមិត្ត ទិង អស់លោកមេបា ទាំងអស់តរៀងទៅ ហើយសូមដណ្ដឹង កូនស្រីលោកមេបា (ឈ្មោះនាង...) ជានៅទំនេរឥតមានទាក់ទាមសំដីទឹងអ្នកណាទេ ឬ ដូចម្ដេច?

---

១- បើគ្មានរង យកជាសមកប្រើជំនួសក៏បាន ។

មេបាស្រី តបថា "អ្នកទាំង ៣ នាក់នេះ ជាអ្នកផ្ទួរ សំដីនេះពេញហៅត្រូវ ស្ដាប់ទៅពេញហៅពីរោះ ឈ្មោះក៏ល្អ, យើងមេបាក៏មិនសល់ក្រែង ត្រង់ដែលគេមកសុំស្គាល់សុំស្រឡាញ់នោះ, តែក្មួយស្រីយើងនោះសោតជាប់សំដីនិងញាតិ គេបាននាំទុកតាំងពីតូចមក តែឥឡូវបាត់ដំណឹងមកយូរហើយ ។

អ្នកផ្ទួរ ជំរាបថា "បើដូច្នោះ សុំឲ្យលោកមេបាដោះដំពាក់សំដីនិងញាតិនោះឲ្យបានក្រែងបានប្រកបនិងបានជាសម្ពន្ធមិត្តនិងគ្នាទៅ" ។

មេបា តបថា "បើដូច្នោះ ចាំមើលយើងដោះសេចក្ដីដំពាក់សំដីនោះមើលសិន, បើអ្នកៗស្រាហ៍ទៅមកគង់តែនឹងដឹង" ។

៦– ជើងបន្ទាប់ ឲ្យអ្នកផ្ទួរនិយាយថា "សូមទានសូមជំរាប(១) សូមជ្រាប ។ ដ្បិតដើមមុន ខ្ញុំសុំឲ្យលោកមេបា ដោះពាក្យដែលដំពាក់នោះ ឥឡូវនេះលោកដោះរួចហើយឬនៅ ?" ។

មេបា តបថា "យើងបានដោះពាក្យដំពាក់នោះរួចហើយ" ។

លំដាប់នោះ អ្នកផ្ទួរត្រូវជំរាបថា: "សូមទាន សូមជំរាប(២) សូមជ្រាប" ។ ដ្បិតលោក ... អ្នក ... (ឲ្យចេញឈ្មោះ) ពឹងខ្ញុំឲ្យជាអ្នកផ្ទួរមកសុំជាសាច់-

---

១– ២– អស់លោក មេបា ជំទាវ ខុនណាង គ្រូកូលរៀបចំ សូមជ្រាប ។

សន្តានជាស្ពានមេត្រី សុំដណ្តឹងនាង (ឲ្យចេញឈ្មោះ) ជាកូនលោកអ្នក (ឲ្យចេញឈ្មោះ) ឲ្យជាគូសម្ពន្ធវង្ស និង (ឲ្យចេញឈ្មោះ) ជាកូនលោក-អ្នក (ឲ្យចេញឈ្មោះ) គួរពុំគួរសូមអភ័យទោស ។

មេបា តបថា " យើងសព្វថ្ងៃរកតែញាតិច្រើន ក្រែងដើរជិតឆ្ងាយស៊ើបដំណើរ គ្រាន់នឹងបានជាទីសំចត ស្នាក់អាស្រ័យសោះបារម្ភ តែត្រង់មកសុំដណ្តឹងកូនយើងនេះ យើងយល់ថាអ្នកខាងណោះមិនគួរនឹងមកចង់ជាប់ជាសាច់សន្តាននឹងយើងសោះ ព្រោះកូនយើងរូបឆោមលោមព័ណ៌សម្បុរមិនឆើត ហើយល្ងង់ខ្លៅ មិនចេះធ្វើការរកស៊ីឲ្យប្រាកដផង ក្រែងបានទៅជាញាតិសាច់ ហើយត្រឡប់ជាមានដំណិះតិះដៀលដោយ-ហេតុផ្សេង ៗ ដល់មកយើងជាមេបា " ។

អ្នកកាដូរ តបថា " ហេតុត្រង់ណោះ សុំកុំឲ្យលោកមេបាព្រួយ ទោះបីអាក្រក់ល្អសខ្មៅដ្ឋូរដេងដូចម្តេច ចេះតែស្រឡាញ់មិនមានរង្គៀសគ្មានខ្នាញ់ដោយហេតុអ្វី ៗ ទេ បានជាសង្កាតសុំទាំងម្ល៉េះ សូមលោកមេបាមេត្តាអនុគ្រោះអនុញ្ញាតឲ្យផង " ។

មេបា តបថា " បើដូច្នោះអ្នកទៅសិនចុះ ចាំយើងពិគ្រោះនឹងញាតិជិតឆ្ងាយមើលសិន " ។

៣- ជើងក្រោយ អ្នកដូវ ត្រូវប្តឹងថា " សូមទាន សូមជំរាប អស់លោកមេបា ជំទាវ ខុនណាង ត្រកូលរៀមច្បង សូមជ្រាប ៗ ដ្បិតខ្ញុំមក ១ ជើង ២ ជើងមុន ដូចលោកមេបាជ្រាបស្រាប់ ឥឡូវខ្ញុំមកជាគំរប់ ៣ ជើងនេះ សូមដឹងប្រសាសន៍ជាស្រេច លោកមេបានឹងអនុកូលចូលចិត្តឲ្យជាសាច់សន្តាន ជាស្ពានមេត្រីឬទេ ? ៗ

មេបា តបថា " អ្នកដូវ មកជើងមុនយើងក៏ចាំសំដីបាន ឥឡូវអ្នកមកជើងនេះ ថាអ្នក ( ឈ្មោះ ... ) ពឹងឲ្យមកសុំដណ្តឹងនាង ( ឈ្មោះ ... ) ជាកូនយើង ឲ្យជាគូសម្ពន្ធវង្សនឹង ( ឈ្មោះ ... ) ជាកូន ( លោក ... អ្នក ... ) យើងជា មេបាស្រី នឹងសម្រេចសេចក្តីពុំបាន ត្រូវតែ អ្នកដូវ ទៅជំរាបដល់លោក មេបាប្រុសជាមេបាធំ ទើបនឹងសំរេចសេចក្តីឲ្យអ្នកបាន ហើយត្រូវឲ្យ មេបាស្រី ជូនសេចក្តីតាមអ្នកដូវ និយាយនោះ ទៅ មេបាប្រុស " ៗ

១៣- ឲ្យអ្នកដូវ វិលទៅនិយាយនឹងមេបាប្រុសថា " សូមទាន សូមប្រណិប័តន៍ អស់លោក មេបា ឧកញ៉ា ពញា ព្រះ ត្រកូលរៀមច្បង សូមទានជ្រាប ៗ ដ្បិតលោក-អ្នក ( ឈ្មោះ ឬ ងារ ) ពឹងខ្ញុំទាំង ៣ នាក់ ឲ្យជា អ្នកដូវ មកសុំដណ្តឹងនាង

(ឈ្មោះ ...) ជាកូនលោក មេបា ឲ្យជាគូសម្ពន្ធវង្ស នឹង (ឈ្មោះ ...) នោះខ្ញុំទាំងឡាយជា អ្នកផ្សំ បានទៅប្រណិប័តន៍លោកមេបាស្រី ១ ដង ២ ដង គំរប់ជា ៣ ដងហើយ ដូចលោកជ្រាបស្រាប់ នោះលោកមេបាស្រី មានប្រសាសន៍ថា "មិនស្រេចដាច់ខាតនឹងលោកមេបាស្រីទេ ជាស្រេចនឹងមេបាប្រុសដាច់" ។

សេចក្ដីនេះ, សូមលោកមេបា មេត្តាអនុញ្ញាតឲ្យបានជាសាច់សន្តានជាស្ពានមេត្រីសម្ពន្ធវង្សតទៅ ។

គួរពុំគួរសូមអភ័យទោស ។

មេបាប្រុស ថា "អ្នកនិយាយសុំដណ្ដឹងកូនទៅយើងនេះ យើងមេបា នឹងនិយាយកិច្ចការនេះ ជាស្រេចដាច់ខាត នឹង អ្នក ជា អ្នកផ្សំ ពុំទាន់បានទេ ដ្បិតអ្នកជាស្រី ស្មារតីតិច ច្រើនភ្លេចមុខ. ក្រោយ ក្រែងនឹងទទួលការសព្វគ្រប់ទៅពុំបាន, បើដូច្នេះ អ្នកត្រឡប់ទៅប្រាប់អ្នកសាមីដើមការឲ្យតាំងតែរកប្រុស ៣ នាក់ ដែលចេះដឹងចាំវិធីមង្គលការ ហើយប្រកបមានគូស្រករ មិនអភ័ព្វ ធ្លាប់ធ្វើជា មហា មកប្រស្រ័យនឹងយើងជា មេបា ដើម្បីនឹងបាននិយាយការតទៅ ។

"ត្រង់នោះត្រូវឲ្យ អ្នកផ្សំ ទៅប្រាប់អ្នកសាម៉ីដើមការតាមសំដីមេបា" ។

លំដាប់នេះ ត្រូវឲ្យអ្នកសាមីដើមការ រៀបជង់វង់ ពានស្រា ឲ្យ អ្នកមហា ដែលបានពឹងរកមកបំរុងទុកនោះ ព្រមទាំងអ្នកជូនស្រី , ឯអ្នកជូនស្រី ត្រូវប្រើរងសម្លាបដែល ឡើងទៅរកមេបាប្រុស ហើយអ្នកជូនស្រី ជំរាបមេបា ជាមុនថា " សូមទាន សូមជំរាបអស់លោកមេបា ឧកញ៉ា ពញ៉ាព្រះ ត្រកូលរៀមច្បង សូមទានជ្រាប " ។

ដ្បិតដើមមុនលោកមេបាមានប្រសាសន៍ថា ឲ្យអ្នកសាមីដើមការ ពឹងរក មហាប្រុស ឲ្យមកប្រណិប័តន៍និយាយមង្គលការ និង លោកមេបា ឥឡូវអ្នកសាមីដើមការរកបានហើយ ឲ្យខ្ញុំជា អ្នកជូន នាំមកប្រណិប័តន៍លោកមេបា មានប្រសាសន៍ជាមង្គលការគេទៅ ។

ទើបឲ្យមហាប្រុស ជំរាបទៅ មេបា ថា " សូមទាន សូមជំរាបអស់លោក មេបា ឧកញ៉ា ពញ៉ាព្រះ ត្រកូលរៀមច្បង ធំ-តូច សូមទានជ្រាប " ។

ដ្បិតអ្នកសាមីដើមការពឹងពាររកខ្ញុំប្របាទ " នាម ឬ ងារ , ប្រពន្ធ-ឈ្មោះ... នៅភូមិ-ខេត្ត " ឲ្យធ្វើជា មហា មកប្រណិប័តន៍លោកមេបា ជំរាបមង្គលការគេទៅ , សេចក្ដីនេះ សូមលោកមេបា ពិតពិលរមិលមើលសណ្ឋានរូបកងខ្ញុំប្របាទទាំង ៣នាក់ ល្មមធ្វើជាមហាធំ-តូច

និយាយមង្គលការនឹងលោក មេបា ជាគួរសមឬទេ សូមទានប្រសាសន៍

គួរពុំគួរសូមអភ័យទោស ។

មេបា តបថា យើងជា មេបា ពិនិត្យទៅឃើញថា អ្នកទាំង ៣ នាក់នេះ គួរសមល្មមធ្វើជា មហា និយាយមង្គលការបានហើយ ឲ្យរៀបចំខ្លួនប្រាណតាមរបៀបមហាមកចុះ ។

មហា ត្រូវប្ដឹងថា បើលោកយល់ឃើញថាខ្ញុំប្របាទទាំង ៣ នាក់ គួរសមហើយ សូមអនុញ្ញាត ពាក់អាវផាយ ស្រាយមាត់ថង់ តម្រង់មាត់តែង អុជទៀន ប្រណិប័តន៍លោកមេបា " មេបា ក៏បង្គាប់ឲ្យពាក់អាវផាយឡើង ឲ្យពាក់ស្រាអុជទៀន ឲ្យជំរាបមេបា " ។

សូមទាន សូមជំរាបអស់លោក មេបា ឧកញ៉ា ពញា ព្រះ ត្រកូលរៀមច្បង សូមជ្រាប, ដ្បិតលោក-អ្នក ( ឈ្មោះ ប្ដី ឆារ ) ជាសាមីដើមការតឹងខ្ញុំប្របាទទាំង ៣ នាក់ ជា មហា មកប្រណិប័តន៍ លោកមេបា សុំដណ្ដឹងនាង ( ឈ្មោះ ... ) ជាកូនស្រីលោក មេបា ឲ្យជាគូសម្ពន្ធវង្សនឹង ( ឈ្មោះ ... ) ជាកូនអ្នកសាមីដើមការ ឲ្យបានជាសាច់សន្ដានដ៏ស្និទ្ធតទៅ,

គួរពុំគួរសូមអភ័យទោស ។

មេបាតបថា " ដែលមហាជំរាបយើងនេះ យើងក៏ស្ដាប់បាន

តែយើងមិនដែលបានឃើញស្គាល់កូនប្រុសអ្នកសាមីដើមការ មិនដឹងជាសណ្ឋានរូបឆោមល្អ អាក្រក់ វែង ខ្លី ខ្លាញ់ ខ្ទិន ទុព្វលភាពយ៉ាងណាទេ, មួយទៀត បើរូបឆោមលោមពណ៌ល្អបរិសុទ្ធហើយ តែកិរិយាមារយាទខុសឆ្គងអបលក្ខណ៍ ជាអ្នកលេងល្បែង មានសេពសុរាមេរ័យ ជក់អាភៀនញៀនកញ្ឆា លេងបៀប៉ោវថូកំតាត់ជាដើមនេះមួយ មិនចេះធ្វើការរកស៊ីដូចអ្នកទាំងពួងនេះមួយ ឬ មួយមានស្រីកំណាន់ប្រកាន់ចិត្តនេះមួយ ។

ន័យមួយទៀតក្រែងមានជំពាក់បំណុលបុលការគេ និងរាប់ដល់មកកូនយើងនេះមួយ, ហេតុទាំងនេះយើងមេបានិងព្រមឲ្យមិនទាន់បាន ទាំយើងស៊ើបស័ព្ទស្តាប់មើលសិន បើឃើញថាជាល្អបរិសុទ្ធឥតមានមោះចំពោះត្រង់បងឯណាទីមួយទេ យើងមេបា និងថាអ្វី ។

មហា តបថា " ត្រង់សាមីខ្លួនកូនប្រុស និង នាំមកជូនលោកមេបាពិនិត្យមើល ឯត្រង់កិរិយាមារយាទកូនប្រុសអ្នកសាមីដើមការនោះជាបុរសសុភាពរៀបរយល្អបរិសុទ្ធឥតមានសេចក្តីសៅហ្មង ដោយបទអាក្រក់ឯណាទីមួយទេ ទាំងមានចំណេះវិជ្ជាឈ្លៀវឆ្លាតរកស៊ីដូចអ្នកទាំងពួង បើលោកមេបាស៊ើបទៅហើយឃើញថា សាមីខ្លួនកូនប្រុសនោះ ជាមនុស្សផ្លូវជាតិមារយាទអាក្រក់ ដូចប្រសាសន៍បងឯណាទីមួយនេះមហា

ខ្ញុំបាទទទួលខុសលើខ្លួន តាមច្បាប់សម្រាប់ស្រុក, ក៏សុភាបណ្ណាការ ក៏សូមជូនលោកពិសាទទេ មិនឲ្យលោកមេបាបង់ខាតអ្វីសោះ ទុកជាឥតព្រេងសំណាងនិងគ្នាទៅ " ។

មេបា តបថា " បើអ្នកមហាហ៊ានរ៉ាប់រង ទទួលខុសត្រូវលើខ្លួនជាប្រាកដដូច្នេះ ពិតជាគ្មានលិខិតសញ្ញាក៏មែន តែវាជាគុណទីប្រជុំយ៉ាងនេះ ក៏យកជាកិច្ចសន្យាបានហើយ បើអ្នកមហាថាល្អប្រាកដ នេះយើងជាមេបាក៏ព្រមឲ្យ តែបើយើងឲ្យទៅហើយនៅមិនទាន់រៀបមង្គលការ ហើយស៊ើបទៅដឹងថាកូនប្រុសអ្នកសាមីដើមការនោះ ប្រព្រឹត្តបទអាក្រក់ឯណាទីមួយ នោះយើងនឹងហៅអ្នកមហាមកប្រាប់មិនព្រមឲ្យវិញបានឥតមានបទអ្វីមកជំទាស់ទេ " ។

មហា ជំរាបថា "ដែលលោកមេបាមានប្រសាសន៍មកទាំងប៉ុន្មាន មហាខ្ញុំបាទទទួលតាមប្រសាសន៍ទាំងអស់ ឲ្យតែបានជាសាច់សន្តានជាស្ពានមេត្រីទៅ " ។

មេបា តបថា " បើដូច្នោះយើងក៏ព្រមឲ្យកូនស្រីយើងទៅជាគូ-វាសនារួមសម្ពន្ធវង្ស និងកូនប្រុសអ្នកសាមីដើមការខាងណោះ ឲ្យអ្នកមហាទៅប្រាប់អ្នកសាមីដើមការចុះ ថាយើងព្រមឲ្យហើយ " ។

១៤ – ខណៈនេះ ត្រូវឲ្យអ្នកសាមីដើមការរៀបជំនូនទទួលអំណរ និងស្លាម្លូសម្រាប់ស៊ីស្លាដក់ស្លាកន្សែងស្រេច ហើយត្រូវឲ្យមហាមានថង់វង អ្នកផ្លូវមានវេសម្ពាច និងពានស្លាដូចគ្នា នាំកំស្តុការបណ្ណាការឡើងទៅជំរាបមេបាថា "សូមពាន សូមជំរាបអស់លោកមេបា ឱកាញ៉ា-ពាញ៉ាព្រះត្រកូលរៀមច្បងសូមជ្រាប" ។ ដ្បិតអ្នកសាមីដើមការ មានអំណរនិងប្រសាសន៍នៃលោកមេបា ដែលព្រមអនុញ្ញាតឲ្យជាសាច់សន្តានជាស្ពានមេត្រីឲ្យបានជាសម្ពន្ធវង្សតទៅនោះណាស់ ឥឡូវឲ្យនាំកំស្តុការបណ្ណាការមកជូនលោកមេបា ទទួលអំណរទាំងសុំស៊ីស្លាដក់កន្សែង ក្នុងគ្រានេះផង គួរពុំគួរសូមអភ័យទោស" ។

មេបា ទទួលជំនូនហើយត្រូវប្រជុំញាតិស៊ីស្លាដក់-កន្សែង ត្រូវបរោភ លើកថង់វង អ្នកផ្លូវលើកវេសម្ពាច មានម្លូរ ២ សន្លឹក ហៅថា "ស្លាមាត់ពាប" ដាក់ជូនមេបា ។ ត្រូវបាច់ ១ គូម្នាក់គ្រប់ញាតិទាំងអស់ ។

„ដែលពណ៌នាក្នុង ១៤ នេះ គឺធ្វើដាច់ពេលពីគ្នា បើធ្វើរួមពេលគ្នា ជាមួយនិងស៊ីស្លាធំសុំភ្ជាប់មាត់ពាក្យនោះ ( ១៤ នេះ ត្រូវលើកទុកធ្វើរួមគ្នាទៅខាងមុខតែម្តង ) " ។

ហេតុដែលត្រូវមានស៊ីស្លាដក់-កន្សែងនេះ នឹងអធិប្បាយទៅខាងក្រោយឲ្យដឹង ។

អស់វគ្គដាបចិមតែប៉ុណ្ណោះ

## វគ្គទី ២

១៩ - លុះមេបាព្រមអនុញ្ញាតឲ្យហើយ ត្រូវឲ្យអ្នកសាមីដើមការរៀបក័ស្តុការបណ្ណាការ និងរបស់គំជាប់ចិត្ត គឺជាមាសប្រាក់ ឬគ្រឿងអាភរណៈទាំងពួង តាមកម្លាំងធនធានដោយគួរសម, ស្រេចហើយត្រូវឲ្យមហានិងអ្នកជូន ទៅជំរាបមេបាជាមុនថា " សូមទាន សូមជំរាបអស់លោកមេបា ឧកញ៉ា ពញាព្រះ ត្រកូលរៀមច្បង " សូមជ្រាប ។

ដ្បិតដើមមុន មហាខ្ញុំបាទមកប្រណិប័តន៍លោកមេបា សូមដណ្ដឹងកូនស្រីលោកមេបា ៗក៏អនុញ្ញាតព្រមឲ្យ ឥឡូវអ្នកសាមីដើមការឲ្យមហាខ្ញុំបាទមកជំរាបលោកមេបា សូមលើកក័ស្តុការបណ្ណាការនិងរបស់គំជាប់ចិត្តនិងសូមស៊ីស្លាធំសូមភ្ជាប់មាត់ពាក្យ សូមលោកអនុញ្ញាតតាមការ (មេបាត្រូវអនុញ្ញាតតាមមហាសុំ) ។

មហា និងអ្នកជូន លើកថង់រង់ជួបគ្នា (អ្នកជូនត្រូវឈប់ប្រើរង់សម្រាប់ត្រឹមណោះ) ឲ្យនាំក័ស្តុការបណ្ណាការនិងរបស់គំជាប់ចិត្តឡើងទៅត្រូវរបា ជំរាប មេបា ថា " សូមទាន សូមជំរាបលោកមេបា ឧកញ៉ា ពញាព្រះ ត្រកូលរៀមច្បង " សូមជ្រាប ។

ជៀតអ្នកសាមីដើមការឲ្យមហាខ្ញុំបាទនាំកស្តុការបណ្ណាការ និងរបស់គំជាប់ចិត្ត មកដាក់បង្ហូនលោកមេបា សូមស៊ីស្លាកំជាប់ពាក្យ សូមលោកមេបាប្រមូលគណៈញាតិមកចាំពិសាស្លា, គួរពុំគួរសូមអភ័យទោស ។

" បើធ្វើមេត្រូវបេញចាំងស្លាជក់ - កន្សែងផង "

មេបា ត្រូវទទួលកស្តុការបណ្ណាការ រួចត្រូតមើលរបស់គំជាប់ចិត្ត ត្រូវឲ្យមេបាស្រីជួយត្រួតមើលទៀតឲ្យដឹងជារបស់អ្វីខ្វះឲ្យប្រាកដ ដើម្បីជាកសិណតទៅ រួចហើយបើមានគ្រឿងអាករណៈត្រូវឲ្យអ្នកផ្ញើស្រី យកទៅបំពាក់ឲ្យសាមីខ្លួនកូនស្រី ឬ ប្រគល់ឲ្យទៅមាតាបិតាខាងស្រីក៏បាន ។

ឯកស្តុការបណ្ណាការ ឲ្យបង្អន់កុំអាលលើកយកទៅ ចាំព្រេនស៊ីនឯប្រដាប់ព្រេនត្រូវខាងស្រីរៀបនៅទីកណ្តាលប្រជុំមេបា មានកន្ទេលទ្វេយ សំពត់សក្រាលពីលើឈមក្បាលកន្ទេលទៅរកទិសដង្ហើមរស់តាមវិធីព្រាហ្មណ៍ មាន ពានស្លា ថ្កុលទឹក ហើយមេបាប្រើបំរើឲ្យចាប់យកកស្តុការ " នំ, ចំណី " មួយមុខ១ ( ដាក់ពាន១ គូ ) យកមកដាក់នៅទីព្រេននោះ ឲ្យមហាលើកជង់រងចាំងគូ ដាក់សងខាងឲ្យស្មុដទៀនធូបស្រេចហើយ ឲ្យ មេបាប្រុស - ស្រី ព្រមទាំងអ្នកមហា និងអ្នកជាប់ធ្វើសច្ចកិរិយារំលឹកថា :

" ឱតេជៈ ថ្ងៃនេះ ថ្ងៃជា ពេលាល្អ ដ្បិត (ឲ្យបេញ ឈ្មោះ . . .:) រៀបឲ្យនាង (ឈ្មោះ . . .) ជាកូន ឲ្យមានស្វាមី គឺឲ្យទៅ (ឈ្មោះ . . .) ជាកូន (ឈ្មោះ . . .) ឥឡូវយើងខ្ញុំ សូមប្តឹងអស់លោកតាស់ខ្ញុំ ជីដូន ជីតា មាតាបិតា ញាតិសាលោហិត ទាំងសងខាង ដែលអនិច្ចកម្មទៅកាន់បរលោកនាយ កុំឲ្យប្រកាន់ទោសថា: " ទុកដាក់កូនចៅ ឲ្យមានគូស្វាមី មិនជំរាបឲ្យជ្រាប ដូច្នេះសូមអញ្ជើញអស់លោកតាស់ខ្ញុំ មកជួបជុំសេពសោយក្រយាហារ ហើយជួយឲ្យស័ព្ទសាធុការពរ ដល់សាមីខ្លួន ឲ្យបានសុខសុវត្ថិ អាយុយឺនយូរ ឲ្យមូលស្វាមីភរិយា ជាសុខចិតថេរបេរកាលតទៅ " ថា យ៉ាងនេះ គំរប់ ២ ដងហើយ ឲ្យចាប់ទឹសំណែននេះបន្តិច ៗ ដាក់ចាន ១ និងស្លា ១ មាត់ អុជទៀន ហើយឲ្យមហាចាក់ស្រាប្រួច រួចនិយាយថា " ឥឡូវលោកតាស់ខ្ញុំពិសារួចហើយ ត្រូវចាប់សំណា លាសំណែនឲ្យអស់តាហាន តាក្លែវ អ្នកដើងអង្រឹង ដើងស្នែង ដែលតាមលោកតាស់ខ្ញុំ មកនោះសេពសោយ ហើយជួយឲ្យស័ព្ទសាធុការពរ ដល់អ្នកសាមីខ្លួន ឲ្យបានសេចក្ដីសុខគ្រប់ប្រការ" ហើយត្រូវលើកប្រដាប់ព្រេន ព្រមទាំងក៏ស្ដុការបណ្ណាការទាំងអស់ទៅប្រគល់ឲ្យមាតាបិតាខាងស្រី ។

( ឯពិធីព្រេននេះ ជាពិធីព្រាហ្មណ៍សាសនា យើងជាពុទ្ធសាសនិកជនមិនធ្វើពិធីនេះក៏បាន ) ។

លុះចប់ព្រេនហើយមហាត្រូវផឹកបរមេបាថា " សូមមាន សូមផឹកបៗលៗ " សូមជ្រាប ។ សូមលោកមេបាប្រជុំគណៈញាតិប្រុសស្រី អញ្ជើញពិសាស្លាធំកំជាប់មាត់ពាក្យ " ទើបឲ្យមហា ចាត់ក្មេងប្រុសម្នាក់ បីថង់ផែជូនមេបាប្រុស ចំណែកអ្នកជាវស្រីក៏ត្រូវចាត់ក្មេងស្រីម្នាក់ឲ្យបីថង់ផែជូនមេបាស្រី ត្រូវឲ្យមេបាណាដែលជាបង្អែកក្នុងមង្គលការនោះ ឲ្យចាប់មុនគេ ឲ្យចាប់មួយសន្ទឹក, ទើបមេបាចាប់ជាលំដាប់ដកបតែអស់ញាតិគ្រប់គ្នា ។ បើគ្រប់គ្នាហើយត្រូវលើកថង់ផែទៅឲ្យមេបាជាបង្អែកនោះចាប់ម្តងទៀត ហៅថា " ប្រុសត្បុម្មុ " ឲ្យមេបាឲ្យពរដល់សាមីខ្លួនឲ្យបានសេចក្តីសុខ ស្រេចហើយឲ្យវត្តមាត់ថង់ ។ ក្នុងវេលាមេបាស៊ីស្លា (ត្រូវលេងភ្លេងជាត់ជាយ, តាផែ្សងក្រហម, អន្តរកាឡ) ។

បើធ្វើខុសពេលពីថ្ងៃស៊ីកំណត់ ថ្ងៃសំពះនោះ វគ្គនេះត្រូវឲ្យគោះថង់ផែតែម្តង ។ ឯប្របាប់គោះថង់នោះ ត្រូវខាងប្រុសរៀប ឲ្យមានស្លាម្លូ ធៀនធូប និងប្រាក់ តាមគួរសមនិងវង្សត្រកូល ។ ត្រូវឲ្យយកហារមែងខាងស្រីឲ្យគោះ ។ បើធ្វើរួមជាប់ជាមួយនិងថ្ងៃសំពះ វគ្គនេះមិនត្រូវគោះថង់ទេ ត្រូវបន្ទន់ទុកដល់ថ្ងៃបង្ហើយ ។

ដែលធ្វើតាំងពីវគ្គ ១ មកដល់វគ្គគំរប់២ នេះ ច្បាប់ថាពាក់កណ្ដាលការ សាមីខ្លួនកូនប្រុសនិងទៅនៅបំរើមាតាបិតាក្មេកក៏បាន ឯសាមីខ្លួនកូនស្រី ត្រូវរៀប ចាយ, ស្លា ចារ៍, ឲ្យសាមីខ្លួនកូនប្រុសបាន់ តែឲ្យអ្នកដទៃ យកទៅឲ្យ ។

១៦– លំដាប់ពីស៊ីស្លាកំជាប់ពាក្យរួចហើយ ត្រូវរៀបកំណត់ពេលាបេកមាស ជូនមេបា ជាលំដាប់មកទៀត តែបើរួមវេលាគ្នា នោះត្រូវជូនពេលារួមជាមួយនិងពេលដែលជូនរបស់កំជាប់ចិត្តនោះតែម្ដង កុំបាច់ញែកជា ២ ពេលឡើយ ឲ្យមហាជំរាបមេបារួមទាំងអស់តែម្ដង ។

ឯពេលាបេកមាសនោះ ត្រូវខាងប្រុសរកហោរាចារ្យគេមើលឲ្យ ។ សេចក្ដីការដាក់ក្នុងពេលាបេកមាស ស្រេចលើអាចារ្យគេរៀបរៀងឲ្យ (ត្រូវធ្វើទុកជាមុន) ។ ដល់ថ្ងៃវេលាទឹងនាំពេលាបេកមាសទៅជូនមេបា នោះ ត្រូវរៀបតម្កល់កំណត់ពេលានោះនិងពាន ១ ជាន់ឬ ២ ជាន់ មានបំណីតាមគួរ និងបេកទុំ ១ គូ ហើយឲ្យមហានាំឡើងទៅជូនមេបា ឲ្យជំរាបថា "សូមពាន សូមជំរាប . . . ។ ល ។" សូមជ្រាប ។

ដ្បិតអ្នកសាមីដើមការ ឲ្យ មហា ខ្ញុំបាទ នាំពេលាបេកមាស មកជំរាបជូនលោកមេបា ដើម្បីឲ្យជ្រាបកំណត់ថ្ងៃនិងហែផ្កាស្លាព្រះពរ

នាំសាម៉ឺនកូនប្រុសមកក្រាបសំពះលោកមេបា ដូចមានន័យក្នុងកំណាត់ពេលាស្រាប់ សូមលោកមេបាបង្គាប់តាមទំនៀម :

មេបាទទួលពេលា ហើយត្រូវបង្គាប់តាមទំនៀម "ឲ្យមេបាបង្គាប់ផ្ទះ ៣ ល្វែង (ហប់មុខក្រោយ) និងក័ស្តុការបណ្ណាការ គឺស្លាពាន់, ម្លូពាន់, ថ្នាំ ៣ នាឡិ, ស្លាផ្កា ៣ នាឡិកខ្ទះ, កំបោ ២ ក្អម, អង្ករខ្សាយ ៣ តៅ, អង្ករដំណើប ១ ថាំង, ត្រីស្រស់ ៧ ស្នែង (ក្នុង ១ ស្នែង ៣០ កយ), ត្រីងៀត ១៥ កន្ទុយ, ត្រីឆ្អើ ១៥ បន្ទាក់, មាន់ ៣០, ទា ១៥, ប្រហុក ៥ នាឡិ, អំបិល ១ ពាងតូច, ស្រា ៤ ក្អម ឬ ៨ ដុំទន ស្រាពពុះ ១ ក្អម ឬ ដុំទន, នំបំណាំផ្លែឈើ ៣០ មុខ (១ មុខ ១ ស៊ឹក-៥ ផ្ទូន), ហើយឲ្យបំរុងថាសបាយសំរាប់ភ្ញៀវតាមចំនួនតិចច្រើនផង ។

" នេះជារណ្តាប់ការជំ "

ឯ ស្លាកំណាត់ ស្លាកំដាប់ពាក្យ ស្លាជក់ - ស្លា - កន្សែង ត្រូវបង្គាប់បន្ថយពាក់កណ្តាលពីការធំ រៀងទៅតាមលំដាប់តាមបវទីមួយ ៗ ឯរណ្តាប់បង្គាប់យ៉ាងនេះ គឺមានតាំងពីកល្ប ព្រះបាទសម្តេចព្រះជ័យជេស្តាមហាធិបតី ទ្រង់តែងតាំងទុកមក ។

ដែលពណ៌នាពីលំដាប់បង្គាប់មកនេះ គ្រាន់តែឲ្យដឹងស្គាល់ទំនៀមពីបុរាណកាលមកប៉ុណ្ណោះ សម័យឥឡូវនេះ យើងនឹងយកតាមទំនៀមនេះ

ជាការដាច់ខាតក៏ពុំបានដែរ ត្រូវប្រព្រឹត្តទៅតាមកាលតាមសម័យដែលមាតាបិតាខាងប្រុស ឬខាងស្រីនិយាយគិតគូព្រមព្រៀងគ្នាដូចម្ដេចត្រូវធ្វើដូច្នោះចុះ ។

មហា ត្រូវទទួលតាម មេបា បង្គាប់ ស្រេចហើយ ត្រូវឲ្យរៀបលៀងភោជនាហារភ្ញៀវ មេបាបរិភោគអាហារ (លេងភ្លេង ជ្រង-ស្រដាត់) ។

ចប់កិច្ចក្នុងវគ្គទី ២ តែប៉ុណ្ណោះ

## វគ្គទី ៣

១៧– លុះដល់ជិតថ្ងៃនឹងរៀបមង្គលការធំ ត្រូវឲ្យមាតាបិតាប្រុសទៅគិតគូនឹងមាតាបិតាខាងស្រី សុំទឹកដី : សង់រោង តម្កល់ផ្កាស្លា និងរោងក្នុងកៅ ឲ្យត្រូវតាមទិស ក្បាលនាគ កន្ទុយនាគ ( តាមក្បួនហោរាសាស្ត្រកំណត់ទុកមក ) ។ មាតាបិតាខាងស្រីត្រូវសម្តែងទីឲ្យតាមអ្នកម្ខាងសុំ ឯរោងតម្កល់ផ្កាស្លា ត្រូវធ្វើ ៣ ល្វែង រោងចុងភៅមិនកំណត់ល្វែងទេ ធ្វើយ៉ាងណាឲ្យតែធ្វើការបានស្រួល ។ កំណត់ថ្ងៃចូលរោងមង្គលការនោះ គឺគេយកមុនថ្ងៃស៊ីស្លាកំណត់ ១ ថ្ងៃ នៅវេលារសៀលថ្ងៃនោះ ពេលម៉ោង ៥ ឬ ៦ ។ ត្រូវមាតាបិតាខាងកូនប្រុសរៀបថង់រង ១ គូ និងក៏ស្លាដែលបំរុងទុកក្នុងមង្គលការនោះ ព្រមទាំងនាំសាម៉ីខ្លួនទៅចូលរោងមានគណៈញាតិខ្លះជូនទៅផង ។ ដល់ទៅរោងត្រូវឲ្យវាយឃ្មោះ ៣ បទ ដើម្បីកំណត់ឲ្យដឹងថា " បានចូលរោងមង្គលការហើយ " តែមុននឹងទៅចូលរោងនោះ ត្រូវជំរាបមាតាបិតាខាងស្រីឲ្យដឹងជាមុន ។ លុះចូលរោងរួចហើយ សាម៉ីខ្លួនកូនប្រុស គេមិនឲ្យដើររហេតរហូតទៅណាមកណាឡើយទេ ក្រែងមានការណ៍វិបត្តិផ្សេងៗ នាំឲ្យស្កុនការដល់សាម៉ីខ្លួន ។

ឯមាតាបិតាខាងស្រីសោត បើមានបង្គាប់ឲ្យខាងប្រុសធ្វើផ្ទះនោះ កូនថ្លៃប្រុសចូលពេលត្រូវរៀបឲ្យកូនស្រីឡើងផ្ទះថ្មីនោះដែរ បើគ្មានបង្គាប់ឲ្យធ្វើផ្ទះថ្មីទេ កិច្ចដែលឡើងផ្ទះនោះក៏លើកចេញមិនត្រូវធ្វើឡើយ ។

១៨– លុះព្រឹកឡើងជាថ្ងៃស៊ីស្លាកំណត់នោះ ត្រូវឲ្យសាមីដើមការរៀបចង់រង ១ គូ និង ពានស្លា ឲ្យអ្នកផ្ទូរអ្នកមហាដែលខ្លួនបានពឹងគេមកនោះ ។ លុះមេបាជួបជុំហើយ ត្រូវឲ្យអ្នកផ្ទូរអ្នកមហាឡើងទៅជំរាបមេបា ។

" កិច្ចកង់វគ្គនេះ, បើវគ្គមុន ៗ មិនទាន់បានធ្វើសោះ ហើយរួមធ្វើជាមួយគ្នាតែម្ដងនោះ ៗ ត្រូវឲ្យតែអ្នកផ្ទូរឡើងទៅនិយាយចែចូវ - ដណ្ដឹង ( ដូចមានន័យក្នុងវគ្គទី ១ វគ្គទី ២ ស្រាប់ ) " ។ បើបានធ្វើសព្វគ្រប់ហើយ ខណៈនោះត្រូវឲ្យមហាជំរាបថា " សូមទាន សូមជំរាបអស់លោក... ។ល។ " សូមជ្រាប ។

ជៀតដើងមុន ឬ ថ្ងៃមុន " បានរៀបដណ្ដឹងនិងស៊ីស្លាដក់ កន្សែងកំជាប់មាត់ពាក្យនិងជូនវេលាបេកមាសរួចស្រេចអស់ហើយ ឥឡូវថ្ងៃនេះជាថ្ងៃស៊ីស្លាកំណត់នឹងរៀបវិវាហមង្គលការធំ នោះអ្នកសាមីដើមការឲ្យមហាខ្ញុំបាទជំរាបជូនផ្ទះថ្មី ដែលមេបាបង្គាប់ឲ្យធ្វើនោះ (ត្រង់ណេះបើគ្មានធ្វើផ្ទះទេ មិនត្រូវនិយាយពីផ្ទះឡើយ ) ត្រូវនិយាយថា: " សូមទាន សូមជំរាបអស់លោក... ។ល។ " សូមជ្រាប ។

សុំកំពង់ចតទូក សុំទីជំរកនេះ សុំដីសង់រោង ផ្កាស្លា-រោងពុងពោ សុំដីដីកកុក-ចង្ក្រាន ។

( ដែលឲ្យមហានិយាយដូច្នេះ នេះគ្រាន់តែជាទីគោរពប៉ុណ្ណោះ ឯកិច្ចទាំងនេះបានធ្វើមុនរួចមកហើយ ) ។

“ មេបាត្រូវអនុញ្ញាតតាមមហាសុំ ”

១ ដើងទៀតត្រូវឲ្យមហាជំរាបអស់លោក...។ល។ សូមជ្រាប។

សុំបើកជញ្ជាំងចងក្លាក់ដៃ-ក្រាលកន្ទេលហើយ សូមឲ្យលោកមេបា ប្រមូលញាតិពិសាស្លាកំណត់ និង លើកក័ស្ដការ បណ្ណាការតាមដែលមេបាបង្គាប់មកប្រណិប័តន៍ជូន ។

មេបា ត្រូវអនុញ្ញាត តាមមហា ប្ដឹង ”

មហាត្រូវលើកក័ស្ដការបណ្ណាការឡើងមក ( ត្រូវលេងភ្លេង ជាត់ជាយ-កន្សែងក្រហម-អង្គរភាជ ) ឯក័ស្ដការបណ្ណាការត្រូវ រៀបតាំងនៅទីចំពោះមុខមេបា ហើយជំរាបថា “ សូមទាន សូមជំរាប អស់លោក...។ល។ ” សូមជ្រាប, ដ្បិតអ្នកសាមីដើមការ ឲ្យមហា ខ្ញុំបាទ នាំបណ្ណាការតាមដែលបង្គាប់ពីថ្ងៃមុន មកប្រណិប័តន៍ជូនលោក មេបា សូមមេត្តាពិនិត្យត្រួតមើល បើខ្វះខាតមុខណា ទំនងសូមបំពេញជូន ។

“ គួរពុំគួរសូមអភ័យទោស ”

តែបទនេះ បើគ្មានបង្គាប់ទេ ដោយយកតម្លៃរូបទៅហើយ មហាមិនត្រូវនិយាយថា “សុំឲ្យគ្រូមើលនោះទេ, គ្រាន់តែថាសុំប្រណិប័តន៍ជូនប៉ុណ្ណោះបានហើយ” ។

មេបា កាលបើបានទទួលបណ្ណាការរួចហើយ ត្រូវរៀបព្រេង (ឯរបៀបព្រេនដូចគ្នានឹងសេចក្ដីក្នុង ១ ទី ៥) ។

បើរួចកិច្ចព្រេនហើយ ត្រូវ មហាជំរាបថា “សូមទាន សូមជរាបអស់លោក ... ។ល។” សូមជ្រាប, ដ្បិតលោកមេបាបានរៀបព្រេនរួចហើយ ឥឡូវសុំលោកមេបាប្រជុំគណៈញាតិពីសាស្លាកំណត់, បើរួមត្រូវថាទាំងស្លាដក់-កន្សែង ស្លាធំកំដាប់ពាក្យកំណត់រួមគ្នាទាំងអស់តែម្ដង, បើបានធ្វើគ្រប់វគ្គមកហើយ ត្រូវនិយាយតែត្រឹមស្លាកំណត់ ១ ប៉ុណ្ណោះ ។

ស្រេចហើយត្រូវឲ្យ មហា និង អ្នកជូវ លើកថង់រង់ជូន មេបា “ឯរបៀបសុំស្លាត្រូវធ្វើដូចមានន័យក្នុង ១ ទី ៥ ដូចគ្នា តែបើធ្វើដាច់វេលាពីគ្នា នោះមិនត្រូវមានស្លាទាត់ចាបទេ, មេបា សុំស្លាកំណត់(ត្រូវលេងក្លូនជាត់ជាយ, កន្សែងក្រហម, អង្ករពេជ) សុំស្លារួចហើយ ត្រូវលៀនខាទនិយៈភោជនីយាហារទៀត ។

អស់កិច្ចពេលព្រឹកតែប៉ុណ្ណោះ

១៩– លុះដល់ពេលរសៀល ត្រូវរៀបកាត់សក់សាម៉ីខ្លួនប្រុស–ស្រីដែលរៀបមង្គលការនោះ ។ ឯរបៀបកាត់សក់នោះត្រូវរៀបគ្រឿងសំការ ១ គ្រឿង ព្រមទាំង កន្ត្រៃ, ក្រាស, កញ្ចក់, ទឹកកសំបួរ ១ ផ្តិល, ជង់រង ១ ក្លូ និងត្រូវរៀបកំណាល់ព្រះពិស្ណុការ ឲ្យជាងកាត់សក់ផង របស់ទាំងនេះត្រូវយកទៅរៀបតាំងនៅទីកាត់សក់នោះ ( ដូចមានក្នុងផែនទីស្រាប់ ) ហើយត្រូវឲ្យកូនស្រីរៀបខ្លួនចេញមកកាត់សក់ ។ ត្រូវឲ្យអាចារ្យរម្ញាប់កាត់ ៣ កន្ត្រៃឲ្យជាមុន ទើបឲ្យជាងកាត់ឲ្យជាក្រោយ ។ រីឯជាងដែលកាត់សក់នោះ ត្រូវយកស្ត្រីមានគូស្រករ មិនដែលមានអក់ព្យឲ្យកាត់ឲ្យ ក្នុងវេលាកាត់សក់នោះ ត្រូវលេងភ្លេង ជាត់ជាយ, ស្រីស្ទើរ, សារិកាកែវ, កាត់ស្លឹក )។ ឯចំណែកសាម៉ីខ្លួនកូនប្រុស ឲ្យជាងប្រុសកាត់ឲ្យក្នុងពេលផ្កាស្លា នៅវេលាជាមួយគ្នា ។

លុះដល់រសៀលម៉ោង ៤ ឬ ៥ មហាត្រូវឡើងប្តឹងមេបាសុំរៀបគ្រូពាលីនិងប្តឹងទេវរក្ខតាស់ស្រុក, ឯរបៀបក្រុងពាលីស្រេចនៅលើអាចារ្យគេបង្គាប់ ។

លំដាប់តមកទៀត ត្រូវឡើងប្តឹង មេបា សុំឲ្យសាម៉ីខ្លួនកូនប្រុសឡើងមកស្តាប់ព្រះសង្ឃចំរើនព្រះពុទ្ធមន្ត រួមជាមួយនិងកូនស្រីផង ។

មេបា ត្រូវអនុញ្ញាតឲ្យតាមមហាសុំ ត្រូវបើកឲ្យសាមីខ្លួនកូនប្រុសឡើងមកស្ដាប់ព្រះពុទ្ធមន្តនៅល្វែងមុខបាន តែមិនអនុញ្ញាតឲ្យអង្គុយដល់ល្វែងបន្ទប់ពុំទាន់បានទេ ។ លុះដល់មេបាអនុញ្ញាតហើយ ខណៈនេះបើគួរលៀងភ្ញៀវឲ្យហើយក៏ឲ្យរៀបលៀងភ្ញៀវទៅ ឬមិនឲ្យរៀបលៀងជាខាងក្រោយក៏បាន ។ មុនព្រះសង្ឃនិមន្តមកដល់ត្រូវឲ្យរៀបកន្លែងសូត្រព្រះពុទ្ធមន្ត ។ ខាងប្រុសត្រូវយកកន្ទេល១, ខ្នើយ ១ ទៅក្រាលនៅទីដែលមេបាអនុញ្ញាតនោះទុកឲ្យសាមីខ្លួនកូនប្រុសក្រាបនមស្ការស្ដាប់ព្រះបរិត្ត ឯសាមីខ្លួនកូនប្រុសត្រូវតែងខ្លួនស្លៀកពាក់ជាទីបេញមុខដោយគួរសម ។ លុះព្រះសង្ឃនិមន្តមកដល់ហើយ អ្នកមហា និង អ្នកជំនូន ត្រូវនាំកូនប្រុសឡើងមក មានបង់រងនិងផ្កាស្លាខ្ពរ, ស្លា, ម្លូ សម្រាប់ដោតផ្កាស្លាព្រះពរឲ្យតម្កល់និងគោកម្ពុ តាមគួរសម និង ពពិល មានអង្ករដៃយ ១ សៀន, ទៀនពពិល និង ទៀនពេលា កាន់ដើរឡើងមកខាងមុខសាមីខ្លួន ។ លុះមកដល់ទីអង្គុយ ត្រូវរៀបតាំងរបស់ទាំងនេះខាងមុខសាមីខ្លួន បង្គាប់កូនប្រុសឲ្យក្រាបអភិវាទព្រះសង្ឃ៣ដង ហើយក្រាបហ្លួបទៅលើខ្នើយដោយសុភាព ចាំស្ដាប់ព្រះសង្ឃចំរើនព្រះបរិត្ត ។ កាលកូនប្រុសឡើងមកដល់លើផ្ទះ ត្រូវវាយឃ្មោះទទួល ៣ បទ ។

ឯសាមីខ្លួនកូនស្រី ត្រូវរៀបតាក់តែងកាយដោយគ្រឿងអលង្ការ

ស្រេចហើយ ត្រូវមេបាស្រីនាំចេញមកអង្គុយក្រាបអភិវាទព្រះសង្ឃ នៅទីកម្រាលដែលក្រាលទុកនៅល្វែងចំនួនខាងក្រៅ ។ វេលាដែលកូនស្រីចេញមកនោះ (ត្រូវឲ្យវាយឃ្មោះ ៣ បទ), ស្រេចហើយឲ្យអាចារ្យទូន្មានរំលឹកសាមីខ្លួនទាំងប្រុសទាំងស្រីថា "ឲ្យតាំងចិត្តយកគុណព្រះរតនត្រ័យទាំង ៣ គឺ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ជាទីពឹងទីរឭក ដរាបអស់ជីវិត" ។ ឧបទ្ទវន្តរាយ ទាំងពួង ចូរកុំបីមានដល់យើងខ្ញុំនិង សូមចំរើនសុខសួស្តិជ័យមង្គលដល់យើងខ្ញុំ ហើយឲ្យអាចារ្យអុជទៀនធូបគ្រឿងសក្ការៈបូជា ដែលបានរៀបតាំងនៅទីនោះ ថ្វាយព្រះរតនត្រ័យ រួចឲ្យអាចារ្យយកអាបោះក្អុក សៀតត្រចៀក ឲ្យកូនប្រុសស្រី សាមីខ្លួនទាំងពីរនាក់ (ប្រុសសៀតស្តាំ, ស្រីសៀតឆ្វេង) ទើបអារាធនាសីល រួចព្រះសង្ឃចំរើនព្រះបរិត្ត ។ លុះចប់ហើយត្រូវឲ្យកូនស្រីអភិវាទព្រះសង្ឃចូលទៅក្នុង (ត្រូវវាយឃ្មោះ ៣ បទ) ទើបឲ្យកូនប្រុសអភិវាទព្រះសង្ឃ ចុះទៅកេងផ្កាស្លាវិញ (វាយឃ្មោះ ៣ បទ) អាចារ្យត្រូវប្រគេនទេយ្យទាន ដែលសាមីដើមការបំរុងទុកប្រគេននោះចំពោះព្រះសង្ឃ ។

១១០– លុះចំរើនព្រះបរិត្តរួចហើយ ត្រូវមេបាស្រីរៀបសែនចងដៃកូនស្រី នៅទីល្វែងចំនួន ។ ឯរបៀបសែននោះ មាន ចំអាប ១ ក្ដូ,

បន្ថែម១គូ, ក្បាលជ្រូកស្ងោរ១គូ, ចានចាយតម្កល់ពាន ១គូ, ផ្តិលទឹក១, ស្លាម្លូដីប ១ពាន, មានកន្ទេលខ្នើយ សំពត់សក្រាលពីលើ ។ ក្រាលកន្ទេលត្រូវក្រាលទៅរកទិសដង្ហើមរស់ (តាមហោរាសាស្ត្រ) ឯសម្រាប់បន្ថែមចំអាបទិនរបស់ឯទៀតនោះ ត្រូវរៀបតាំងឆ្វេងស្តាំ, ស្រេចហើយត្រូវយកថង់រង ទៅរៀបដាក់បើកបាយ-ស្រី ១គូ, ផ្តិលទឹកសំបួរ១ មានអំបោះចងដៃដាក់ក្នុងផ្តិលនោះផង យកមកតាំងពីខាងមុខ ។ ស្រេចហើយត្រូវឲ្យមេបាស្រីនាំសាមីខ្លួនកូនស្រីចេញមក (ត្រូវរាយឈ្មោះពាបទ), ឲ្យអង្គុយលើសំពត់សដែលក្រាលនោះ ហើយឲ្យក្រាបសំពះទៅលើខ្នើយ ដែលមានកន្សែងសំពះក្រាលនៅពីលើនោះ ទើបឲ្យអាចារ្យយកប្រណាក ឬ អកកំបោសំរិទ្ធ ឲ្យសាមីខ្លួនទ្រ ដើម្បីឲ្យមានតេជៈសំរិទ្ធិជោគ ដល់សាមីខ្លួន ស្រេចហើយមេបាស្រី-ប្រុស គណៈញាតិទាំងមហា ធ្វើសច្ចកិរិយាដូចមានន័យក្នុង ១ ទី៥ (ត្រូវលេងភ្លេងដាត់ជាយ, ចាយខុង) ។ សំណែនត្រូវចាប់តែម្ខាង កុំឲ្យចាប់ទាំងសងខាង ទុកខាងស្តាំឲ្យប្រុសចាប់ទៀត ។ ស្រេចហើយឲ្យលើកសំណែនទាំងអស់ទៅរៀបនៅរោងផ្កាស្លា គ្រង់ល្វែងច័ន្ទ រៀបរបៀបដូចខាងស្រីរៀប ទើបឲ្យអាចារ្យយកផ្តិលអំបោះចំណងដៃ (ធ្វើកិច្ចតាមវិធីព្រាហ្មណ៍) ឲ្យចងដៃឲ្យពរ រួចឲ្យមេបាមាតាបិតាខាងស្រី-

ស្រេចហើយ ត្រូវមេបាស្រីនាំចេញមកអង្គុយក្រាបអភិវាទព្រះសង្ឃ នៅទីកម្រាលដែលក្រាលទុកនៅល្វែងច័ន្ទខាងក្រៅ ។ វេលាដែលកូនស្រីចេញមកនោះ (ត្រូវឲ្យវាយឃ្មោះ ៣ បទ), ស្រេចហើយឲ្យអាចារ្យទូន្មានរំលឹកសាមីខ្លួនទាំងប្រុសទាំងស្រីថា "ឲ្យតាំងចិត្តយកគុណព្រះរតន-ត្រ័យទាំង ៣ គឺ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ជាទីពឹងទីពុក-ដរាបអស់ជីវិត" ។ ឧបទ្ទវន្តរាយ ទាំងពួង ចូរកុំបីមានដល់យើងខ្ញុំនិង សូមចំរើនសុខសួស្តីជ័យមង្គលដល់យើងខ្ញុំ ហើយឲ្យអាចារ្យអុជទៀនធូបគ្រឿងសក្ការៈបូជា ដែលបានរៀបតាំងនៅទីនោះ ថ្វាយព្រះរតនត្រ័យ រួចឲ្យអាចារ្យយកអំបោះក្ដុក សៀតត្រចៀក ឲ្យកូនប្រុស-ស្រី សាមីខ្លួនទាំងពីរនាក់ (ប្រុសសៀតស្ដាំ, ស្រីសៀតឆ្វេង) ទើបអារាធនាសីល រួចព្រះសង្ឃចំរើនព្រះបរិត្ត ។ លុះចប់ហើយត្រូវឲ្យកូនស្រីអភិវាទព្រះសង្ឃចូលទៅក្នុង (ត្រូវវាយឃ្មោះ ៣ បទ) ទើបឲ្យកូនប្រុសអភិវាទព្រះសង្ឃ ចុះទៅពេងផ្កាស្លាវិញ (វាយឃ្មោះ ៣ បទ) អាចារ្យត្រូវប្រគេនទេយ្យទាន ដែលសាមីដើមការបំរុងទុកប្រគេននោះចំពោះព្រះសង្ឃ ។

១១០- លុះចំរើនព្រះបរិត្តរួចហើយ ត្រូវមេបាស្រីរៀបសែនបងដៃកូនស្រី នៅទីល្វែងច័ន្ទ ។ ឯរបៀបសែននោះ មាន ចំអាប ១ ក្លុ,

បង្អែម ១ គូ, ក្បាលជ្រូកស្ងោរ ១ គូ, ចានចាយតម្កល់ពាន ១ គូ, ដ្ដឹលធីតា ១, ស្លាម្លូដីប ១ ពាន, មានកន្ទេលខ្នើយ សំពត់សក្រាលពីលើ ។ ក្រាលកន្ទេលត្រូវក្រាលទៅរកទិសដង្ហើមរស់ (តាមហោរាសាស្ត្រ) ឯសម្រាប់បង្អែមចំអាបទិនរបស់ឯទៀតនោះ ត្រូវរៀបតាំងឆ្វេងស្តាំ, ស្រេចហើយត្រូវយកថង់រង ទៅរៀបដាក់បើកបាយ. ស្រី ១ គូ, ផ្ដឹលទឹកសំបូរ ១ មានអំបោះចងដៃដាក់ក្នុងផ្ដឹលនោះផង យកមកតាំងពីខាងមុខ ។ ស្រេចហើយត្រូវឲ្យមេបាស្រីនាំសាមីខ្លួនកូនស្រីចេញមក (ត្រូវវាយឃ្មោះពាបទ), ឲ្យអង្គុយលើសំពត់សដែលក្រាលនោះ ហើយឲ្យក្រាបសំពះទៅលើខ្នើយ ដែលមានកន្សែងសំពះក្រាលនៅពីលើនោះ ទើបឲ្យអាចារ្យយកប្រណាក ឬ អកកំបោសំរិទ្ធ ឲ្យសាមីខ្លួនទ្រ ដើម្បីឲ្យមានតេជៈសិរិទ្ធិជោគ ដល់សាមីខ្លួន ស្រេចហើយមេបាស្រី-ប្រុស គណៈញាតិទាំង មហា ធ្វើសច្ចកិរិយាដូចមានទ័យក្នុង ១ ទំ ៥ (ត្រូវលេងភ្លេងជាត់ជាយ, ចាយ ១ ឆ) ។ សំណែនត្រូវចាប់តែម្ខាង កុំឲ្យចាប់ទាំងសងខាង ទុកខាងស្តាំឲ្យប្រុសចាប់ទៀត ។ ស្រេចហើយឲ្យលើកសំណែនទាំងអស់ទៅរៀបនៅកេងផ្កាស្លា ត្រង់ល្វែងបន្ទួ រៀបរៀបដូចខាងស្រីរៀប ទើបឲ្យអាចារ្យយកផ្ដឹលអំបោះចំណងដៃ (ធ្វើកិច្ចតាមវិធីព្រាហ្មណ៍) ឲ្យចងដៃឲ្យគេ រួចឲ្យមេបាមាតាបិតាខាងស្រី-

ប្រុសនិងគណៈញាតិចងដៃជាលំដាប់គ្នា រួចហើយឲ្យបញ្ចប់កូន ។ ត្រូវមហា ឬ អាចារ្យឲ្យពរជ័យសួស្ដីគ្រប់ ៣ បទ រួចសាមីខ្លួនកូនស្រីចូលទៅក្នុងវិញ ( ឲ្យវាយឃោះ ៣ បទទៀត ) ស្រេចកិច្ចខាងស្រី ។

១ ១១ - លុះរៀបសែនចងដៃកូនស្រីរួចហើយ ត្រូវឲ្យមហាដំកបមេបា " សូមទាន សូមដំកបអស់លោក . . . ។ល។ " សូមជ្រាប ។ ដ្បិតបានសែនចងដៃកូនស្រីរួចហើយ ឥឡូវសូមអញ្ជើញលោកមេបាទៅជួយសែនចងដៃកូនប្រុសឯកេងផ្កាស្លាទៀត ។

" មេបាត្រូវទទួលតាមមហាអញ្ជើញ "

មហា ត្រូវទៅរៀបទឹកខ្ទងតាមគួរសម ទុកឲ្យមេបាអង្គុយ ហើយឲ្យប្រជុំគណៈញាតិខាងប្រុសឲ្យជួបជុំ ស្រេចហើយសាមីខ្លួនកូនប្រុសតែងកាយពាក់អាវផាយ មកអង្គុយនៅទីសែននោះ(ឲ្យវាយឃោះ ៣ បទ) ហើយឲ្យកូនប្រុសនោះក្រាបសំពះទៅលើខ្នើយ ហើយឲ្យទ្រជាវ ដើម្បីឲ្យមានតេជះ, រួចឲ្យអាចារ្យមហាមាតាបិតាគណៈញាតិខាងប្រុស - ស្រី ធ្វើកិច្ចសែនចងដៃជូនគ្នានិងកូនស្រី ( រួចហើយឲ្យវាយឃោះ ៣ បទទៀត ) កិច្ចដែលត្រូវធ្វើពីល្ងាចចប់តែប៉ុណ្ណោះ ។

( ឯកិច្ចដែលសែនចងដៃនេះ បើយើងជាពុទ្ធសាសនិកជន មិនចង់ធ្វើកិច្ចនេះក៏បាន ព្រោះជាពិធីព្រាហ្មណ៍ ) ។

១ ១៦– លុះដល់ម៉ោង ១១-១២ មហាត្រូវឡើងដំកបមេបាសុំឲ្យរៀងថ្លៃឈើតាមចំនួនភ្ញៀវមានតិច-ច្រើន "គឺខ្ចប់នំបុងទុកដែលមានរូបបិយ:ឬវត្ថុអ្វីមួយ ទុកសម្រាប់បង់ថៃសាមីខ្លួនទាំង២ នោះ ត្រូវឲ្យមេបាខាងស្រីរើសស្ត្រីក្រមុំ(១)ព្រហ្មចារី ៤ នាក់ ឲ្យជាអ្នករៀបនំខ្ចប់ (ត្រូវលេងភ្លេងជូនស្លាយ, វត្តសារិកាកែវ) បើអ្នកដើមការមានបំណាំបន្ថែម លៀងភ្ញៀវហើយ រៀងថ្លៃឈើនេះមិនបាច់ធ្វើក៏បាន ។

១ ១៧– លុះដល់យប់ម៉ោង ២–៣ ពេលជាស់ទំ ត្រូវមហាឡើងដំកប មេបា សុំជាវខាន់ស្លា ថា: "សូមទាន សូមដំកបអស់លោក... ។ល។" សូមជ្រាប ។

ក្មួងស្រីលោកមេបា, តើលោកទឹងពិសាថ្លៃខាន់ស្លាប៉ុន្មាន? វេលានេះត្រូវលេងភ្លេងអង្គរាជ, ខ្មែរដំបណ្ដែត, កាដំស្លោយ ។

មេបា ត្រូវកាត់ថ្លៃខាន់ស្លា តាមកូនច្បង-កូនកណ្ដាល-កូនពៅ, ឯកូនច្បងនិងកូនពៅ ថ្លៃខាន់ស្លាដូចគ្នា ឲ្យមេបាកាត់ថ្លៃជាប្រាក់ ៣០ តម្លឹង ១ បាទ ២ ស្លឹង នេះតាមប្រាក់ចាយ ក្នុងរាជ្យព្រះជ័យចេស្ដា បើគិតជាប្រាក់រៀលយើងដែលចាយក្នុងសម័យនេះ (ត្រូវជា ១២ រៀល

---

១– ស្ត្រីក្រមុំទាំង ៤ នាក់នេះ គេឲ្យឈ្មោះថា: នាងកែវ, នាងកង, នាងមាស, នាងប្រាក់ ។

២៥ សេន) ត្រូវឲ្យមេបាសុំបំពេញថែម ៦ តម្លឹង ៣ បាទ ២ ស្លឹងទៀត គិតជាប្រាក់យើងសម័យឥឡូវ (២៧៥ សេន) បង្គ្រប់ជា ១ ណែន ។ ឯកូនកណ្ដាលត្រូវថយចុះពីកូនច្បង ២ តម្លឹង តែត្រូវឲ្យមេបាបំពេញឲ្យគ្រប់ ១ ណែនដូចគ្នា, ដែលឲ្យមេបាបំពេញយ៉ាងនេះ ដើម្បីជាទីចំរើនសិរីដល់កូនស្រីមេបា, ដែលកាត់ថ្លៃខាន់ស្លាយ៉ាងនេះគឺធ្វើតាមបែបចាស់គេធ្វើរៀងមក, តែក្នុងសម័យថ្មីនេះ បើអ្នកមានទ្រព្យស្ដុកស្ដម្ភម៉ាមួន និងកាត់ថ្លៃឲ្យលើសពីនេះទៅទៀតក៏បាន ស្រេចហើយនៅព្រមព្រៀងគ្នាតាមវង្សត្រកូល, ឯថ្លៃខាន់ស្លាត្រូវបានទៅមាតាបិតាខាងស្រី បើនិងឲ្យទៅកូនក៏បានតាមចូលចិត្ត ។

១ ១៤– លុះដល់ម៉ោង៤ ដីតក្ខ ត្រូវឲ្យមេបាឡើងទៅដំកបមេបាសុំជុំពេលា ត្រូវឲ្យមានបេកខ្ទុនទុំដាក់ពាន ១ គូ, បង់ចិញ្ចៀនមាស ១ វង់ ព្រមទាំងផ្លែបេក, ស្លា និងទំ, ដំណាប់ដាក់ពាន ១ គូ ១, គ្រឿងសំអាង ១ គ្រឿង, ទឹក ១ ផ្តិល លើកយកទៅជាមួយនិងបង់វង់ ហើយដំកបមេបាថា "សូមតាន សូមដំកបអស់លោក . . . ។ល។" សូមជ្រាប ។

ដ្បិតអ្នកសាមីដើមការ បានគេហោរាចារ្យ ឲ្យគន់គូរមើលពេលាបេកមាសកូនប្រុស-ស្រីថា "ពេលាបេកមាសល្អ តើនឹងបើកបាននៅពេលម៉ោងប៉ុន្មាន ?" ជាមង្គលសួស្តីល្អ និងនាំសាមីខ្ទួនកូនប្រុស ព្រមទាំង

ផ្កាស្លាព្រះពរ មកក្រាបសំពះគោរពអស់លោកមេបាមាតាបិតាត្រកូល រៀមច្បង និងសុំឲ្យលោកមេបា រៀបប្រដាប់ប្រដាតាក់តែងកាយឲ្យសាមីខ្លួនកូនស្រីដោយគ្រឿងអលង្ការ បំរុងខ្លួនចាំទទួលពេលា តាមន័យអាចារ្យបង្គាប់ ហើយនិងចេញផ្ទឹម, តើអស់លោកមេបានិងអនុញ្ញាតយកពេលាណា? ។ មេបា តបថា "ឯពេលាពេកមាសនេះស្រេចនៅកូនប្រុស បើអ្នកមហាយល់ថាពេលាណាល្អ យើងមេបាក៏តាមមិនយល់តាស់ទេ ឲ្យតែប្រាកដមង្គលសួស្ដីល្អមែន" ។ បើមហាថាល្អ តើមានអ្វីជាកសិណាឲ្យឃើញជាក់ស្តែង ល្មមយើងជាមេបានឹងជឿជាប្រាកដផង ?

មហាត្រូវលើកបេក. ទទឹងស្ករ ជូនមេបាថា "បេកនេះហើយដែលផ្លែចេញមកមានមាសបង្កើតឡើងជាប់មកជាមួយ តាំងជាតិដីដក់មាសរស់ផ្អែមល្អ ខ្ញុំបាននាំយកមកទុកជាជ័យមង្គល សូមលោកមេបាពិនិត្យរូបពិសាមើលចុះ" ។

មេបាត្រូវធ្វើកិច្ចតាត់ឲ្យម្នាក់ពិនិត្យបើឃើញមានពិតដូចមហាថាមែន ហើយ ត្រូវឲ្យចំពៀនមាសនោះទៅមហាវិញ ហើយប្រាប់ថា "ត្រូវឲ្យយកទៅបំពាក់ឲ្យសាមីខ្លួនកូនប្រុសចុះដើម្បីឲ្យបានជាមង្គលសួស្ដីទៅ" ។

១១៥– លុះដល់ពេលាហើយ មហាត្រូវឲ្យរៀបដោតផ្កាស្លា ឲ្យសាមីដើមការពឹងគេអ្នកមុខអ្នកការប្រុស ៣ នាក់ ដែលមានគូស្រករមិនដែល

អក្តិពុមកដោតផ្កាស្លាឲ្យ ឯដោតផ្កាស្លានោះត្រូវរកគូប(១) មាស-ប្រាក់ ឬវត្ថុអ្វីដ៏សមគួរ យកមករៀបដោតតម្កល់និងពានផ្កាស្លាទាំង ៣ នោះ ។ ផ្កាស្លាច្បង ដោតម្ជុ ២១ សន្ទឹក, ស្លា ២១ (យកតាមគុណបិតា), ផ្កាស្លាកណ្ដាល ដោតម្ជុ ១២ សន្ទឹក, ស្លា ១២ (យកតាមគុណមាតា), ផ្កាស្លាពៅ ដោតម្ជុ ៦ សន្ទឹក, ស្លា ៦ (យកតាមគុណញាតិ), ក្នុងវេលាដោតផ្កាស្លានោះត្រូវលេងភ្លេងជាជំឆគាំ, សំពោធ, ដំរីយោលដៃ ឯប្រាក់ខាន់ស្លាត្រូវដាក់នៅពានផ្កាស្លាច្បង ។

កុំភ្លេច : ឲ្យមេបាបង្រៀនសាមីខ្លួនកូនប្រុស ឲ្យបេះសំពះទទួលផ្កាស្លា ជូនមេបាជាមុន ឲ្យបានរៀបរយល្អ កុំឲ្យឆ្គង ។

១ ១៦– ឯអាចារ្យ មុនធ្វើពិធីចាំពេលានោះ ត្រូវឲ្យរៀបពានពេលាដែលបានធ្វើចុកមកហើយនោះ ថ្វាយទេវតា (ឯរបៀបពាននោះស្រេចនៅលើអាចារ្យបង្គាប់). លុះរៀបហើយត្រូវឲ្យលេងភ្លេង តាធាង, សារាយអណ្ដែត, សារាយណែងណង ។ ឯសាមីខ្លួនប្រុសត្រូវតែងកាយស្លៀកបំពាក់ផង គឺស្លៀកសំពត់សារាបាប់ ឬហូល, ល្បើក, ផាមួង តាមបាន តែត្រូវស្លៀកសំឡូយ ពាក់អាវសារាបាប់ (អាវផ្កាមាស)

---

១– ពានគូប មានមាត់ធំមឡើងលើ សណ្ឋានជាត្របកល្បូក ធ្វើពីមាស-ប្រាក់ ឬស្ពាន់-សម្រាប់ទ្រផ្កាស្លាផ្លាស់ ដែលគេឯងតម្រួតលើពានឬគោកធំ ។

អាវកុតស ឬ អាវសាក្លាត ក៏បាន ពាក់អាវផាយក្រហមពីក្រៅ, ស្រេចហើយឲ្យអាចារ្យនាំទៅសំពះទៀនពេលា រួចឲ្យរៀបអង្គុយចាំពេលា បើមានធ្វើកិច្ចដូចម្តេចទៅទៀត ស្រេចនូវអាចារ្យបង្គាប់ ត្រូវឲ្យលេងភ្លេងចារីស្តេចដើរ ។

ឯរបៀបចាំយកពេលានោះ ត្រូវឲ្យរៀបក្រាលកន្ទេលចាប់តាំងពីទីចាំយកពេលានោះ ដរាបដល់ដំណើរថ្មី ដែលឡើងទៅសំពះផ្ទឹមនោះ ត្រូវឲ្យអ្នកាដូវ-អ្នកាមះភាកាន់ជង់រដ់ដើរមុខ, បន្ទាប់មក ពានតម្កល់ ពពិល, អង្គារដ័យ, ពានម្លូដ័យ, ស្លាដ័យ, ទៀនបើកា ចាយស្រី ១ គូ, ផ្កាស្លាច្បង, កណ្តាល-ទៅ ផាលិផាប់ រៀងទៅ ដល់សាមីខ្លួន ។

ឯផ្កាស្លាត្រូវរៀបឲ្យមានជ័ត្រពណ៌ស្រស់ ប៉ាំងតាំង ៣ លុះដល់បានពេលា អាចារ្យត្រូវកយឃោះជាសញ្ញា រួចហើយគណៈញាតិមិត្រត្រូវដង្ហែកូនប្រុសឡើងទៅផ្ទឹម ។ ឯភ្លេងក៏ត្រូវលេងដូនដំណើរទៅជាមួយផង, មានអាចារ្យខ្លះ ឲ្យសាមីខ្លួនកូនប្រុស អង្គុយចាំយកពេលានៅទីសំពះផ្ទឹមនោះតែម្តងក៏មាន, នេះស្រេចនៅចូលចិត្តចុះ តែទោះបីជាយ៉ាងណារបៀបដែលដើរឡើងទៅ ក៏ត្រូវរៀបតាមន័យខាងលើដូចគ្នា ។ ឯសាមីខ្លួនកូនប្រុសវេលាដែលឡើងទៅនោះ ត្រូវឲ្យមានប្រាក់ ១ បាទ ឬ ១ រៀល ដាក់

ជាប់និងខ្លួនទៅជាមួយផង សម្រាប់ទុកឲ្យអ្នកលាងជើង-ដឹកដៃ ទៅកាន់កន្លែងសំពះផ្ទឹមនៅទីល្វែងចំនួនោះ ។

១ ១៧– ចំណែកមេបាខាងស្រី ត្រូវរៀបក្រាលកន្ទេលសំពះ (តាមអាចារ្យបង្គាប់) មានខ្នើយនិងមានកន្សែងសំពះក្រាលពីលើ រៀបទុកឲ្យស្រេចមុនពេលសាមីខ្លួនឡើងមក ។ ឯកូនស្រីក៏ត្រូវតែងកាយ សំលៀកបំពាក់ធំ គឺស្លៀកសំពត់សារបាប់ ឬ ហូល ឬ ល្បើក (សំឡុយ) ពាក់អាវព្រាបំពង់វែងព័ណ៌ ដណ្ដប់ផាហ៊ុមវែងព័ណ៌ បួងសក់ ពាក់វែបនិងតែងគ្រឿងអាភរណៈទាំងពួងតាមបាន (សំលៀកបំពាក់ដូចពោលមកនេះជាបែបចាស់), សម័យឥឡូវគេនិយមស្លៀកសំពត់សំឡុយ ដណ្ដប់ផាហ៊ុមព័ណ៌ពីកុង ដណ្ដប់កួយប៉ាក់ពីក្រៅ ឬ ពាក់ស្បៃក៏បាន និងគ្រឿងអាភរណៈទាំងពួងតាមចូលចិត្ត ។ ឯរបៀបតែងខ្លួនទាំងពីរយ៉ាងនេះ ស្រេចតែនឹងចូលចិត្តចុះ យកតាមបែបណាមួយក៏បាន មិនជាទីទាស់ទេ ។ ត្រូវតែងខ្លួនឲ្យរួចមុនពេលវេលា (បើអាចារ្យបង្គាប់ដូចម្ដេចឲ្យធ្វើតាម) ។

១ទៀត, ត្រូវឲ្យក្រាលសំពត់ស ឬ កន្ទេល តាំងពីក្បាលជណ្ដើរថ្មី នោះរៀងទៅដល់ទីសំពះ និងឲ្យមានប្រុសម្នាក់ចាំសែនក្បាលជណ្ដើរ

ឲ្យមានថ្នូរលើងស្អាត ១ ដុំ ដាក់នៅជើងជណ្ដើរ ហើយឲ្យមានរេបស្លា-ក្រនៀត(១) ១ មាត់ ដាក់ទិងជាយកន្សែងប្រឋុប ឲ្យក្មេងប្រុស ឬស្រីម្នាក់ ដែលត្រូវជាប្អូន ឬ ជាក្មួយសាមីខ្លួនកូនស្រីនោះកាន់ មានទឹក ១ ផ្តិលផង គម្ពុលទុកឲ្យក្មេងនោះឈរចាំនៅជើងជណ្ដើរ លុះសាមីខ្លួនកូនប្រុសដល់មក ឲ្យឈរលើថ្នូ ឲ្យក្មេងនោះហុចទឹកឲ្យសាមីខ្លួនលាងជើង (មានខ្លះឲ្យលាងទាំងទឹកដូងខ្ចីក៏មាន) ។ ក្នុងឱកាសនេះ ត្រូវឲ្យអ្នកចាំសែនក្បាលជណ្ដើររៀបសែនក្បាលជណ្ដើរ, លុះសាមីខ្លួនប្រុសនោះលាងជើងរួចហើយ ឲ្យក្មេងកាន់កន្សែងស្លានោះហុចទៅឲ្យសាមីខ្លួនប្រុសស្រាយយកស្លាស៊ី ។ រួចត្រូវដឹកដៃសាមីខ្លួនប្រុសឡើងមក ឲ្យដើរលើសំពត់សដែលក្រាលនោះ ទៅដល់ទីដែលសំពះ ត្រូវឲ្យសាមីខ្លួនប្រុស ឲ្យប្រាក់ដែលបំរុងជាប់ទិងខ្លួននោះទៅក្មេងដែលដឹកដៃ ។ ឯរណ្ដាប់ដែលកាន់កំដរខ្លួនមកនោះ ត្រូវរៀបតាំងពីខាងមុខ ។ អ្នកកាន់ផ្កាស្លាត្រូវឲ្យអង្គុយរៀងជាជួរពីខាងស្តាំសាមីខ្លួន ។ រីសាមីខ្លួនប្រុសដល់ទៅទីសំពះហើយ ឲ្យក្រាបសំពះគោរពមេបា ៣ ដង លើខ្នើយសំពះនោះ ទើបឲ្យអ្នកកាន់ផ្កាស្លាប្យង ហុចទៅឲ្យសាមីខ្លួនទទួលជូនទៅមេបា (គឺបិតាទទួល) បើគ្មានបិតាត្រូវឲ្យញាតិជាឪពុកធំ ឬ មា ទទួលក៏បាន រួចឲ្យក្រាបសំពះ ៣ ដង

---

១– ស្លាក្រនៀតឬស្លាថ្នាត់ គឺម្លូដែលគេរៀបបត់ញាត់បញ្ចូលមុខគ្នា ។

ទៀតទើបឲ្យអ្នកកាន់ផ្កាស្លាបន្ទាប់ហុចទៅឲ្យសាមីខ្លួនៗ ត្រូវជូនទៅមេបា (ត្រូវមាតាទទួល) បើគ្មានមាតាត្រូវម្តាយធំ-មីងទទួល រួចឲ្យសំពះ៣ដងទៀត ឲ្យអ្នកកាន់ផ្កាស្លាទៅហុចឲ្យទៅសាមីខ្លួនទទួលជូនទៅមេបា ត្រូវឲ្យញាតិជាឪពុកធំ-មា-មីង-បង ទទួល ។ សំពះផ្កាស្លាគោរពមេបារួចហើយ ត្រូវរៀបឲ្យសាមីខ្លួនប្រុសអង្គុយក្រោយខាងស្តាំ (ខណៈដែលសំពះផ្កាស្លានេះ ត្រូវលេងភ្លេង ព្រះថោង) ។

ទើបឲ្យអ្នកតាដូនស្រី យកថង់រង ចូលទៅខាងក្នុងរាំងនន ប្តឹងមេបាស្រី សុំឲ្យសាមីខ្លួនកូនស្រីចេញមកជួប ត្រូវមេបាតបឬអ្នកភ្លេងក៏បាន កាន់ផ្តិតរាំបើករាំងនន (លេងភ្លេងអង. សសរគាព្រោង) ។

ត្រូវអ្នកតាដូនស្រី ឬស្ត្រីអ្នកមុខអ្នកការដឹកដៃសាមីខ្លួនកូនស្រីចេញមកជួប (លេងភ្លេងជាជាត) ឲ្យសាមីខ្លួនកូនស្រីអង្គុយក្រោយសំពះ (ខាងឆ្វេង) សាមីខ្លួនកូនប្រុស (ខាងស្តាំ) ។ វេលាដែលកូនស្រីចេញមក (ឲ្យរាយឃោះ ៣ បទ) ឲ្យក្រោយសំពះរួមខ្នើយនឹងសាមីខ្លួនកូនប្រុស (លេងភ្លេងឆាត់ពន្ធុ) រួចឲ្យអាចារ្យរៀបបង្វិលពពិលតាមវិធីព្រាហ្មណ៍ ឲ្យយកប្រុស ៥ នាក់ រួមទាំងអ្នកកាន់ផ្កាស្លាផង និងស្រី ៤ នាក់ទៀត រួមជា ៩ នាក់ រើសសុទ្ធតែអ្នកមានគូស្រករមិនដែលអក់ព្ធ ឲ្យមកអង្គុយបង្វិលពពិលជាទក្ខិណាវត្ត ១៩ ជុំ (លេងភ្លេងជុំត្រែ) ។ ស្រេច

ហើយឲ្យកំបើកទៀបចាយស្រី ឲ្យយកសំពត់ស ឬស្បៃមកព័ទ្ធទៀប ទាំងគូ ។ អ្នកកាន់នោះត្រូវកំហូតដាវពីស្រោម ក៏ឲ្យពរជ័យសួស្ដី ហើយ ច្រៀង ៣ បទ ។ រួចយកចុងដាវទាត់សំពត់ស ឬស្បៃពីលើទៀបមក ក្រវាត់ រួចសើកដាវទៅក្នុងស្រោមវិញ រួចកំបើកគ្រប់បាយស្រីឲ្យពរជ័យ សួស្ដី ៣ដងទៀត ជាសួរេច (លេងភ្លេងគាំធូរ - បណ្ដាយ យាដ-យាស) ។ ឯសំពត់ទិងទឹកក្នុងទៀបទាំងគូនេះ ត្រូវឲ្យទៅអ្នកកាំ ។ រួចត្រូវអាចារ្យឲ្យពរចងដៃ ឲ្យសាមីខ្លួនទាំង ២ នាក់ទ្រដាវ ឲ្យដាក់ដង ទៅខាងប្រុស រួចឲ្យស្រាយផ្កាស្លាកណ្ដាលទិងពៅ យកផ្កាស្លាបែកញាតិ ប្រុស-ស្រីបាចឲ្យពរសើត្តសាធុការ ព្រមៗ ទាំងអស់គ្នាឡើង ហើយក៏តាំង ចងដៃជាលំដាប់គ្នាៗទៅ (លេងភ្លេងចាយខុង) ។ ឯផ្កាស្លាច្បង់ត្រូវ តម្កល់ទុក ៣ ថ្ងៃ បំរុងទុកឲ្យសាមីខ្លួននាំយកទៅប្រគេនព្រះសង្ឃ ដែល ត្រូវជាព្រះឧបជ្ឈាយ៍គ្រូអាចារ្យរបស់ខ្លួន ។ ចងដៃរួចហើយឲ្យបញ្ឈប់ភ្លេង ត្រូវមហាបុគ្គអាចារ្យឲ្យពរជ័យជាសួរេច ។ រួចឲ្យសាមីខ្លួនប្រុស-ស្រី ក្រោកឡើងចូលទៅក្នុងកាំងនន ត្រូវឲ្យសាមីខ្លួនប្រុសដើរកាន់ជាយស្បៃ សាមីខ្លួនស្រី (លេងភ្លេងលោមធាង, ចាយខុង ក្ដី / ដៀវ } ជប់ជឹកា)

លុះសាមីខ្លួនប្រុស-ស្រីចូលទៅក្នុងកាំងននផុតហើយ ត្រូវឲ្យស្រីលើកយក

សំពត់ដែលសំរាប់ឲ្យជាចំណងដៃប្រុសនោះ មកឲ្យប្រុសផ្លាស់ ។ រួច ហើយក៏បោះទៅឲ្យស្រី ។ ត្រូវសំពះ ហើយឲ្យស្លាក្រទៀត ១ មាត់ មក ប្រុសស៊ី ហើយប្រុសក៏ចេញមកក្រៅវិញ ។

សម្តែងពិធីវិវាហមង្គលការត្រឹមណោះ ស្រីនិងប្រុសឈ្មោះថាបានជាគូស្វាមីភរិយានិងគ្នា ពេញច្បាប់តាមប្រពៃណីបុរាណ ។

(ច្បាប់អត្រានុកូលដ្ឋានបានបញ្ញត្តិទុកមកថា "ក្នុងថ្ងៃបង្ហើយការ ឬ ក្រោយការ ៣ ថ្ងៃ ត្រូវឲ្យសាមីខ្លួន (ស្វាមី-ភរិយា) ព្រមទាំង មាតាបិតាទាំងសងខាង និងសាក្សី២នាក់ នាំគ្នាទៅចុះបញ្ជីអត្រានុកូលដ្ឋាន នៅសាលាឃុំទុកជាសំគាល់ ថាជាគូស្វាមីភរិយាត្រឹមត្រូវតាមលក្ខណៈ ច្បាប់" ។ មាតាបិតាទាំងសងខាង ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ផ្ទាល់ខ្លួនជាប់ទៅជាមួយផង ក្រែងមេឃុំ គេត្រូវការសួរបញ្ជាក់) ។

១១៨– លុះផ្ទឹមរួចហើយ ត្រូវឲ្យមហាជំរាបមេបាថា "សូមបាន សូមជំរាបអស់លោក . . . ។ល។" សូមជ្រាប ។ ព្រោះបានសំពះ ផ្ទឹមរួចហើយ ឥឡូវសុំឲ្យលោកមេបារៀបគោះចងដៃសំរេចការ ។

មេបា ត្រូវបង្គាប់ឲ្យយកញាតិខាងស្រី ដែលត្រូវជាមា-មីង-បង (ឲ្យយកប្រុស ២ នាក់ ស្រី ២ នាក់) ។ ក្នុងចងដៃ ១ ត្រូវឲ្យស្រីម្នាក់ ប្រុសម្នាក់ជាអ្នកគោះ (ឯរណ្តាប់គោះចងដៃដូចមានពោលក្នុង ១១៥ រួចមក

ហើយ) ។ អ្នកគោះផង់រង ត្រូវឲ្យពរថា ថ្ងៃនេះ ជាថ្ងៃមង្គលសួស្តី យើងទាំងឡាយ បានរៀបវិវាហមង្គលការកូនក្មួយជាសាមីខ្លួន ឲ្យជាស្វាមីភរិយា ជាស្រេចហើយ, ឥឡូវយើងទាំងឡាយសូមគោះបង់រងបង្ហើយមង្គលការ សូមឲ្យអស់ទេវតាជួយឲ្យសព្ទសាធុការពរ ដល់អ្នកសាមីខ្លួនទាំង២នាក់ ដែលរៀបមង្គលការថ្មី ឲ្យបានប្រកបសុខសុវត្ថិ មូលស្វាមីភរិយាជរាបដល់យាវជីវំទៅហោង ! ហើយឲ្យអ្នកគោះផង់រងនោះ លតទៀន រូតមាត់ផង់ទុកជាស្រេចការលេងប្រើផង់រងត្រឹមណោះ ហើយឲ្យមហាជំពបមេបា សុំឲ្យរៀបបង្គុយនិងលើកស្លាកបាយមកជូនអស់លោកមេបាពិសា ។

១ ១៩ (ត្រូវលេងភ្លេងសាកាដ្ហូល) ឯកិច្ចលេងសាកទ្ហូលនេះ តាមគតិបុរាណដែលបានធ្វើមកនោះ ព្រោះមានហេតុជាអបមង្គលបង្កើតឡើងក្នុងពេលកំពុងសំពះផ្ទឹម បានជាកើតមានលេងសាកទ្ហូលជាទំលាប់មក ដូចមានអធិប្បាយទុកខាងក្រោយប្រាប់ហេតុឲ្យដឹង :

សម័យឥឡូវនេះ បើមេបា មិនចូលចិត្តឲ្យធ្វើក៏បាន តែបើធ្វើក៏គួរធ្វើតែត្រឹមលេងលគាំកាដ្ហូល ក៏ជាទំរើកាយក្នុងមង្គលការទៅហើយ ។ ឯវិធីលេងសាកទ្ហូលនេះ ត្រូវឲ្យអ្នកភ្លេងដែលធ្លាក់ក្នុងកិច្ចលេងនេះយក

ចន្ទល់ផ្ការ១ មកបង្ចិញ្ចៀនមាស១វង់ ដាក់មូរក្នុងកន្ទេលសំពះនោះហើយ ឲ្យលើដើរ ច្រៀងបណ្តើរ ស្រែកពពាយនាយលក់កន្ទេល ។ ឯសាមីខ្លួនដែលការថ្មីត្រូវឲ្យចេញមកទាំងគូ អង្គុយទន្ទឹមគ្នា ចាំទទួលទិញកន្ទេល ឲ្យអ្នកលក់កន្ទេលនោះ និយាយអធិប្បាយសរសើរគុណានិសង្សកន្ទេលថា: « កន្ទេលនេះបើអ្នកទើបរៀបមង្គលការហើយថ្មីៗ ទិញយកទៅក្រាលដេក នឹងកើតមាស កើតប្រាក់ » ឲ្យអ្នកដទៃសួរបញ្ជាក់ថា « ក្រែងមិនពិតដូចអ្នកថាទេ ឬ ? បើដូច្នេះចូរអ្នកក្រាលដេកទៅយើងនឹងមើល បើពិតដូចអ្នកថាមែន យើងនឹងឲ្យកូនចៅយើងដែលទើបនឹងរៀបការថ្មី គេទិញ » ។ ឲ្យអ្នកលក់កន្ទេលក្រាលដេក គឺដេកគងជើង ហើយឲ្យច្រៀង (ជ្រង់ ៣ បទ) ហើយលាកន្ទេលយកមាស-ប្រាក់ដែលមានដាក់នៅក្នុងកន្ទេលនោះមកបង្ហាញឲ្យគេមើល ទើបឲ្យយកទៅលក់ឲ្យសាមីខ្លួនដែលទើបនឹងការហើយថ្មីៗនោះ (ត្រូវមានទំនិញប្រាក់ចាំទទួលទិញ) ។ អ្នកលក់កន្ទេលត្រូវឲ្យពរជ័យមង្គលដល់សាមីខ្លួនទាំង ២ នាក់ ហើយលើកកន្ទេលឲ្យទៅសាមីខ្លួនទាំងស្វាមីភរិយា ៗ ក៏ទទួលកន្ទេលសែនយកទៅទុកខាងក្នុងបំរុងនឹងក្រាលជាកន្ទេលដំណេក ។

១ ២០ - លុះចប់កិច្ចលាកន្ទេលហើយ ឲ្យរៀបលៀងខាទជ័យ:

គោជទីយាហារកៀវ ត្រូវឲ្យមហោរីរៀបលេងភ្លេងកំដរ ឲ្យមានតែប៉ី ១, ទ្រ ១, អ្នកច្រៀងម្នាក់, មកច្រៀងជូនឲ្យកៀវស្តាប់ តាមបទចាបផ្តាប់ ៗ

បណ្តាគណៈញាតិនិងមិត្តសំឡាញ់រាប់អាន ដែលបានមកជាកៀវទាំងប៉ុន្មាន គួរមានរបៀបៈ ឬ តែអ្វីមួយ គួបព្រលឹងសាមីខ្លួនទាំងពីរនាក់ តាមសមគួរដោយសេចក្តីរាប់អាន ដែលបុរាណាចារ្យលោកបានបង្កើតឲ្យមានជាការបដិសណ្ឋារៈដល់គ្នានិងគ្នាទៅវិញទៅមកនេះ ឃើញថាជាការប្រពៃណាស់ ព្រោះបានជួយជាកម្លាំងដល់សាមីខ្លួនដែលទើបនឹងបានគ្នាជាស្វាមីភរិយាគ្រាន់នឹងបានជាទុនរកស៊ីតទៅ ឬ ទុកថាជាការជួយជាតិរបស់ខ្លួនក៏បាន ហើយនាំឲ្យមានធម៌សាមគ្គីដល់គ្នានិងគ្នាផង, របស់ដែលគួបផ្ទៃទាំងនុ៎ះ បើទុកជាសាបសូន្យទៅក៏គង់តែនឹងបានទៅ [illegible]មកវិញទេ ៗ ហេតុនេះ គួរយើងកុំលះបង់ឡើយ ក្នុងការជួយធុរៈគ្នាម្តងម្នាក់នេះ ។

⁂

## កិច្ចផ្សំដំណេក

១២១– លុះដល់ពេលយប់គេត្រូវរៀបផ្សំដំណេក ត្រូវឲ្យមាតាខាងស្រីរៀបកន្លែងដំណេកដែលកូនស្រីដេក, ឲ្យរៀបបាយ ១ ស្ពត ដាក់នៅទីដំណេកនោះ ។ ឲ្យមាតាខាងប្រុសយកចេកទុំ ៣ ផ្លែ និងផ្កាឈើ ៣ ទង ហើយឲ្យចាស់ទុំស្រី ៣ នាក់ នាំសាមីខ្លួនប្រុសស្រីទៅអង្គុយអម

ស្តកបាយ , ឲ្យប្រុសពូតបាយ ២ ពំនូត បញ្ចុកទៅស្រី, ឲ្យស្រីបកចេក ២ បញ្ចុកទៅប្រុស, ឲ្យប្រុសបកចេក ១ បញ្ចុកទៅស្រី, ស្រេចហើយឲ្យស្ត្រីចាស់ទុំ ដែលនាំសាមីខ្លួនទៅផ្សំដំណេកនោះ យកផ្កាបាចឲ្យពរ រួចឲ្យចាប់ក្បាលប្រុស និងស្រីទង្គិចគ្នា ហើយប្រាប់ថា: « ឲ្យបានគ្នាជាស្វាមីភរិយាចុះ ! » បើធ្វើរួចស្រេចហើយឲ្យប្រុសដេកមុន (ដេកស្តាំ), ឲ្យស្រីដេកក្រោយ (ដេកឆ្វេង) ។

ចប់វគ្គទី ៣

ពណ៌នាមកក្នុងពិធីមង្គលការចប់បរិបូណ៌តែប៉ុណ្ណេះ

# បទភ្លេង

## ច្រៀងក្នុងឱកាសរៀបពិធីមង្គលការ

### បទជាវខាន់ស្លា

ទំនុកច្រៀងទី ១

ស្រីស្រស់មុខម៉ង្ហ ស្រីស្រគត់មុខថ្លា
សូមជាវខាន់ស្លា លោកមេបាពីសាប៉ុន្មាន?

X X X

ទំនុកច្រៀងទី ២

ស្លារៀងក្រោមថ្នក់ ស្លាបត់ក្រោមខ្នើយ
បងទាញមកកើយ ខ្នើយអើយជួយបង ។
សុវណ្ណបន្ទុប្បជា សុវណ្ណបន្ទុប្បជា
ម្តាយកាត់ខាន់ស្លា ៣០ ជម្លឹង ១ បាទ ២ ស្លឹង ។
ឱមាសម្តាយអើយ កាត់កូនឲ្យសខាត
៣០ ជម្លឹង ១ បាទ ២ ស្លឹងអស់ថ្លៃ ។
ឱស្រីពៅម្តាយ ម្តាយចិញ្ចឹមកូនពីតូចដល់ធំ
កូនពេញក្រមុំ សុំប្រាក់ខាន់ស្លា ។

v v v

បទភ្លេងច្រៀងក្នុងពិធីការសំលៀងក្រយាហារគ្រៀវ

មេបាបង្គាប់ឲ្យច្រៀងភ្លេងជ្រង ៣ បទ ។

*បទច្រៀងទី១ថា* "ស្រណោះពែងប្រាក់ បំឡាក់របធា ជំរាបអ្នកផ្ទះ ទូវអ្នកមហា ឲ្យរៀបចាក់ស្រា នឹងកែវបរណៃ រំពើញលោកមេបា ទាំងប្រុសទាំងស្រី ចាប់ក្រយាប្រពៃ ជូនជ្រិងស្រងាត់ ១ បទ" ។

*បទច្រៀងទី២ថា* "ជ្រិងអាយជ្រិងឆាយ ជ្រិងអ្នកបង្ហាយ ជជាយឡើងគាល់ មេបាប្រុសស្រី ពិសារៀងរាល់ ជជាយឡើងគាល់ អស់លោកមេបា ជំរាបអ្នកផ្ទះ ទូវអ្នកមហា ឲ្យរៀបចាក់ស្រា នឹងកែវបរណៃ ជំរាបជូនមេបា ទាំងប្រុសទាំងស្រី ជូនជ្រិងស្រងាត់ ២ បទ" ។

*បទច្រៀងទី៣ថា* "ថ្ងៃត្រង់ហើយណា ជំរាបលោកមេបា ជូនជ្រិងស្រងាត់ គំរប់បទបី សេចក្តីប្រណិប័តន៍ សូមទានលោកចាត់ ភ្លេងតទៅហោង" ។

ꕥ ꕥ
ꕥ

បទបង្គាប់ឲ្យច្រៀងភ្លេង "ដោះក្រាល" ៣ បទ

បទច្រៀងទី ១ ថា "ដោះក្រាលទើបប៉ិច លេបឡើងដូចផ្កា ផ្ទឹមផ្អាប់នុរា ត្រកាលកន្លង ជំរាបអស់លោក មេបាដោឬង មេត្តាខ្ញុំផង ជូនដោះក្រាល ១ បទ" ។

បទច្រៀងទី ២ ថា "ស្រណោះដោះក្រាល ត្រកាលឡើងក្បឹ លោកមេបាតូបធំ ឲ្យកូនមានប្ដី មានទាំងមហាទេព មាន ទាំងមហាមន្ត្រី ផ្សំឲ្យមានប្ដី របស់លោកណា ជំរាបអ្នកផ្សំ ឥវអ្នកមហា អញ្ជើញបាក់ស្រោ យកទៅគំនាប់ ជូនលោក មេបា តូបធំគួរគាប់ ខ្ញុំបាទរៀបរាប់ ជូនដោះក្រាល ២ បទ ។

បទច្រៀងទី៣ថា "ស្រណោះដោះក្រាល លេបឡើងសញ្ញែក ខ្ញុំកាប់សង្រែក វែកជូនមេបា ជំរាបអ្នកផ្សំ ឥវអ្នកមហា ជំរាបលោកមេបា ជូនដោះក្រាល ៣ បទ ។

⁂

បទបង្គាប់ឲ្យច្រៀងភ្លេង "ការកែទ្រាំង" ៣ បទ

បទច្រៀងទី ១ ថា "ផ្សំណាទៅទ្រាំង ទៅរាំងទំលុះ ផ្សំណា

ទៅគួស ទៅរកបរពល បានទាំងប្រុសស្រី មូលមករងស់ ទុំទៅបរពល គាល់លោកមេបា ជំរាបអ្នកផ្លូវ នូវអ្នកមបា ជំរាបលោកមេបា ជូនកន្សែនទ្រាំង ១ បទ" ។

*បទព្រៀនទី២និងទី៣ថា* "ផ្លូវណាទៅទ្រាំង ទៅរាំងទំលុះ ផ្លូវណាទៅគួស ទៅស្រែរនោង មានផ្លូវណាត្រង់ តម្រង់ទៅស្មោង ពីស្រែរនោង ទៅត្នោតបុងស្រង់ ទៅកេណ្ឌប្រុសស្រី មូលមករហង់ ពីត្នោតបុងស្រង់ គាល់លោកមេបា ជំរាបអ្នកផ្លូវ នូវអ្នកមបា ឲ្យរៀបបាក់ស្រោ ដាក់កែវបរណៃ ជូនលោកមេបា ទាំងប្រុសទាំងស្រី ជូនកន្សែនទ្រាំង ៣ បទគ្រប់ហើយហោង ។

⁂

*មេបាបង្គាប់ឲ្យព្រៀនភ្លេង "ខ្មោ ៣ បទ"*

*បទព្រៀនទី១ថា* "ស្រណោះភ្នំខ្មោ ធំខ្ពស់ជ្រងោ មានអាងទឹកអប់ ព្រលិតលំបង់ ពិដោរឈ្មុយឈ្ងប់ ដោរជួបអ្នកអប់ សាយសព្វទិសា ជំរាបអ្នកផ្លូវ នូវអ្នកមបា ជំរាបលោកមេបា ជូនភ្លេងខ្មោ ១ បទ" ។

*បទចម្រៀងទី២ថា* "ស្រណោះភ្នំខ្មៅ ខ្ពង់ខ្ពស់ជ្រងោ ឈើផ្កា ត្រៀបត្រា ក្តាំងដាសៅយុត មង្ឃុតសេតា សឹងមានផ្លែផ្កា ក្រាស់ក្រៃកន្លង ខ្ញុំយកដៃបេះ ប្រទេះត្រកង បុប្ផាផលផង ដោយក្តីមគោរម្យ ជំរាបលោកមេបា ញាតិការតូចធំ កុំយកទោសខ្ញុំ ជូនភ្លេងខ្មោ២បទ" ។

*បទចម្រៀងទី ៣ ថា* "ស្រណោះភ្នំខ្មៅ វែងធំជ្រងោ សឹងមានសិលា ឬខ្មៅធ្មេញសេះ ឬផេះឬដា ជំរាបលោកមេបា ជូនភ្លេងខ្មោ ៣បទ" ។

✕ ✕
✕

*មេទាបង្គាប់ឲ្យច្រៀងភ្លេង "ខ្នងភ្នំ" ៣ បទ*

*បទចម្រៀងទី ១ ថា* "ខ្ញុំដើរក្នុងព្រៃក ឮមាត់ខ្ទៃកឃុំ ដើរដល់ខ្នងភ្នំ ឮសត្វស្រដី ខ្ញុំកាប់ឈើវែង ខ្ញុំសែងឈើខ្លី ពីព្រោះប្អូនស្រី បីថ្ងៃហើយណា ជង្គង់ខ្ញុំលុត ដៃខ្ញុំរន្ធា អស់លោកមេបា សុំជាបុត្រតទៅ ជំរាបអ្នកមហា ព្រមទាំងអ្នកផ្សាបាក់ស្រាជូនទៅ ជូនខ្នងភ្នំ ១ បទ" ។

*បទចម្រៀងទី២ថា* "ខ្ញុំដើរជើងភ្នំ ទ្រូគមឯកា ឮសត្វបក្សា យាសយំស្រងាត់ លន្លោកម្នាក់ឯង កណ្ដោចពេកក្ដាត់ ស្រងូតស្រងាត់ ឥតដល់សង្សារ ប្រសិនបើបាន កល្យាណស្នេហ៍ មួលមកផងរ៉ា ម្លេះសមសប្បាយ ជំរាបលោកមេបា ធំតូចទាំងឡាយ មេត្តាកុំណាយ ជូនខ្ញុំភ្នំ២បទ" ។

*បទចម្រៀងទី៣ថា* "ស្រណោះភ្នំតូច ស្រោងស្រួបទន្ទឹប ទាញតោងសន្សើម ប្រវាចាប់ជាប់ ត្រកាលបំបែក ភ្នំឯកគួរគាប់ បានឡើងមានភ័ព្វ បុរាណព្រេងហោង សុទ្ធសឹងរុក្ខាបុប្ផាច្រើនផង ឈ្មុយឈ្ងប់កន្លង ដោយរសបុប្ផា ជំរាបអ្នកផ្ញើនូវអ្នកមហា ជំរាបលោកមេបា ជូនខ្ញុំភ្នំ៣បទ" ។

⁂

*មេបាបង្គាប់ឲ្យច្រៀងភ្លេង "របងមាស" ៣ បទ*

*បទចម្រៀងទី១ថា* "របងមាស របងដំរី របងប្អូនស្រីល្បាតសឹងបង្ហា ជុំជិតស្និទ្ធល្អ កម្រនឹងផ្កា របងលោកមេបាទាំងខាងពេកក្ដាត់ លុះបានឫក្សល្អ ស្មោះសមិតបាត់ ទើប

លោកថែងកាត់ បើកបានដោយងាយ ជំរាបលោកមេបា មេត្តាសាយអាយ ឲ្យផ្ការទូលាយ ជូនរបងរមាស ១ បទ" ។

*បទចម្រៀងទី ២ថា* "របងរមាស របងជំរឹ របងប្អូនស្រី ចាក់សក់មិនលេច គន់ទៅចំណង ត្រឹមជួបគេក្តិប ចាក់សក់មិនសេច របងលោកណា ជំរាបអ្នកផ្សំ គួរអ្នកមេបា ជំរាបលោកមេបា ជូនរបងរមាស ២ បទ" ។

*បទចម្រៀងទី៣ថា* "របងរមាស របងជំរឹ របងលោកមេបា-ប្រុសស្រី ធ្វើរាំងប្រាសាទ ជំរាបអ្នកមេបា ចាក់ស្រាពែងស្អាត សូមកុំប្រមាថ ជូនរបងរមាស ៣ បទ" ។

x x
x

មេបាបញ្ចប់ឲ្យចម្រៀងភ្លេង "ទឹកជប់" ៣ បទ

*បទចម្រៀងទី ១ ថា* "ទឹកអើយទឹកជប់ ទឹកហូរក្នុងម្លប់ ទឹកជក់រងប្លា ទឹកនេះទឹកឯក បម្លែករស្វាប្ញ ទឹកបកពីណា ក្នុងជ្រោះជ្រាលជ្រៅ ជំរាបអ្នកមេបា ព្រមទាំងអ្នកផ្សំ ចាក់ស្រាជូនទៅ ជូនទឹកជប់ ១ បទ" ។

*បទចម្រៀងទី ២ ថា* "ស្រណោះទឹកជប់ ទឹកនៅក្នុងម្ប់
សោឡសវិស្សា រង់ចាំកំណត់ ឫក្សពារពេលា បានល្អកាលណា
ទើបបើកទឹកបាន អញ្ជើញលោកមេបា ពិសាកំសាន្ត សូម-
ទានស្មោះស្មាន ជូនទឹកជប់ ២ បទ" ។

*បទចម្រៀងទី ៣ ថា* " ទឹកអើយទឹកជប់ ទឹកនៅក្នុងម្ប់
ជោកជាំធរណី រង្វូរដើមឆ្នាំ ភ្លៀងលិចទួលទី ជោកជាំធរណី
ឥតអ្នកហ៊ានបើក លុះដល់ពេលក ល្អជាមានរើក មិនចាំ
បាច់បើក ទំនប់ធ្លាយឯង ដំរាបអ្នកមហា មេត្តាខ្ទះខ្ទែង
បាក់ស្រោងដាក់តែង ជូនទឹកជប់ ៣ បទ" ។

⁂

*មេបាបណ្តាប់ឲ្យចម្រៀងកូន "ក្រោមឆាយ" ៣ បទ*

*បទចម្រៀងទី ១ ថា* "មកពីក្រោមឆាយ ហៅមហាលំបាក
តែងតោងតោកយាក ជំនោរជាបដល់ វាជាបទាំងតូក វាជាប
ទាំងខ្ទល់ ជំនោរជាបដល់ ជាបខ្នងប្អូនស្រី អគ្រាត្រស្រងាត់

បងលើកឡើងបី ជាបខ្ទង់ប្អូនស្រី ទន់អស់កាយា ជំរាបអ្នកផ្ទរ នូវអ្នកមហា ប្ដឹងលោកមេបា ជូនក្រោមនាយ ១ បទ" ។

*បទចម្រៀងទី ២ ថា* " ទឹកជោរសាយប្រាំង ជន់ខ្លាំងសាយអូរ សូមមេបាអាសូរ ដ្បិតខ្ញុំក្បាលមួយ បើលោកបេះស្លឹក លោកកុំភាត់ទ្រួយ ដ្បិតខ្ញុំក្បាលមួយ សង្ឃឹមតែលោក ពែងកែវទាំងគូ ដាក់ប្ដិល់លើតោក ចាក់ស្រាជូនលោក ជូនក្រោមនាយ ២ បទ" ។

*បទចម្រៀងទី ៣ ថា* "ជំនោរខ្យល់ជូន រៀបឫស្សីបងក្បូន នាំប្អូនទៅស្រុក លាទាំងលោកម្ដាយ លាទាំងលោកឪពុក នាំប្អូនទៅស្រុក សូមសុខសប្បាយ លាទាំងញាតិជិត លាទាំងញាតិឆ្ងាយ សូមសុខសប្បាយ ពីលោកមេបា ជំរាបអ្នកផ្ទរ នូវអ្នកមហា ប្ដឹងលោកមេបា ជូនក្រោមនាយ ៣ បទ" ។

ចំនុកច្រៀងកំបើកកំផង ៣បទ

បទច្រៀងទី១ថា "អនអើយស្រីអន សុំបើករាំងនន ជូនអនដេកលក់ សុំដាស់អនឡើង រកទឹកលុបមុខ ជូនអនដេកលក់ ប្រេងាកលើខ្នើយ" ។

បទច្រៀងទី២ថា "អនអើយនាងអន សុំបើករាំងនន នាំអនមកផ្ញឹម អនទឹងបេញមក អនដើរសង្ស៊ឹម នាំអនមកផ្ញឹម ទន្ទឹមលើខ្នើយ" ។

បទច្រៀងទី៣ថា "អនអើយផាត់ជាយ ផាត់បេញឲ្យឆ្ងាយ សោះរាំសាន់រាន់ កន្ទេលខ្នល់ខ្នើយ បម្រុងគ្រប់គ្រាន់ សូមអនរួសរាន់ ពេលាបានហើយ !

## ហេតុដែលនាំឲ្យជាប់ជាទំនៀម
## ក្នុងរឿងមង្គលការតៗមក

លំដាប់តទៅនេះ នឹងពោលអំពីដំណើរហេតុដើម ដែលបង្កើតឲ្យធ្វើកិច្ចនីមួយៗជា វិវាហមង្គលការ ជាប់ជាទំលាប់ទំនៀមតមកដល់បច្ចុប្បន្ននេះ តាមក្បួនបុរាណលោកបានពណ៌នាទុកមក ហៅថា "ច្បាប់ធម្រង់ការ" មានសេចក្ដីអធិប្បាយយ៉ាងពិស្ដារ តែក្នុងសម័យនេះ យើងរើសយកតែន័យខ្លីៗ មកពណ៌នា បង្អួលឲ្យដឹងហេតុដើម ដូចមានតទៅ:

ក្នុងវគ្គជាបឋម តាំងពី ខ ទី ១ ដល់ ខ ទី ៤ ដែលមាន ស៊ីស្លាដាក់-កន្សែង នោះ តាមហេតុដើមថា: មានបុរស ២ នាក់ ទៅឃ្វាលក្របី ជួបគ្នា សុំគ្នាធ្វើជាក្លើហើយសាកសួរគ្នាពីមានកូន ម្នាក់ថាមានកូនប្រុស ម្នាក់ថាមានកូនស្រី ក្លើដែលមានកូនប្រុស និយាយសុំផ្សំផ្គុំកូននិងកូនឲ្យជាគូសម្ពន្ធនឹងគ្នា, បុរសមានកូនស្រីក៏ព្រម ទើបបុរសមានកូនប្រុសយកកន្សែងស្លាពីថ្នក់ខ្លួន ស្រាយលាឲ្យបុរសមានកូនស្រីនោះស៊ីហើយថា: " ដ្បិតមកក្នុងព្រៃគ្មានអ្វីឲ្យជាគ្រឿងបញ្ចាំចិត្តទេ សុំឲ្យសំឡាញ់ស៊ីស្លាកន្សែងនេះ ១ មាត់ចុះ ដើម្បីជាកិច្ចសញ្ញាដល់គ្នានឹងគ្នាតទៅ " បុរសដែលមានកូនស្រីក៏ព្រមទទួលតាម ។

ហេតុនេះ បានជាកើតមាន ស៊ីស្លាដក់-កន្សែង, ចង់-សម្លាប តាំងពីគ្រឹមនោះមក ។

✕ ✕
✕

ន័យមួយទៀតថា, កាលរាជព្រះបាទសម្តេច ព្រះជ័យជេស្ឋា រាមាធិរាជ ទ្រង់ព្រះរាជតិតទុកថាៈ បើអ្នកនគរទីងដណ្តឹងកូនទៅ ក្រមុំគេឲ្យកូនប្រុសខ្លួន ត្រូវឲ្យរកស្រី ៣ នាក់ ហៅថាអ្នកឃ្លាយ គឺ អ្នកចែចូវ" ទៅនិយាយនឹងមាតាបិតាខាងស្រីជាតម្រាយមុន ៣ ដើង, ទើបរកស្រី ៣ នាក់ ហៅថាអ្នកជូន ឲ្យទៅដណ្តឹងម្តងទៀត, បើខាងស្រីព្រមព្រៀងឲ្យហើយ ត្រូវឲ្យសុំស៊ីស្លាដក់-កន្សែង ។

បានជាកើតមានអ្នកចែចូវ-អ្នកជូន-មានស៊ីស្លាដក់-កន្សែង ជាទំលាប់ទំនៀម តមកដល់សព្វថ្ងៃនេះ ។

កូនវគ្គជាតំរប់ ២ តាំងពី ១ ទី ៥ ដល់ ១ ទី ៦ ដែលរៀបរាប់វិវាហ-មង្គលការហើយមានអ្នកជូន, អ្នកមហា, ជំរង, អាចារ្យ កាន់ពេលា, បង្វិលពពិល នេះ, តាមក្បួនបុរាណលោកបាននិពនថា "ធ្វើតាមតម្រាប់ព្រះបរមពោធិសត្វព្រះវេស្សន្តរ កាលព្រះអង្គទ្រង់រៀបវិវាហមង្គលការ ព្រះរាជបុត្រា – បុត្រី គឺជាលី និង ក្រឹស្នា ផ្សំផ្គុំឲ្យជាព្រះស្វាមី ព្រះជាយា ទ្រង់បង្កើតឲ្យមានតាំងពីគ្រឹមនោះមក" ។

ក្នុងវគ្គជាតំរប់៣ តាំងពី ១ ទី ៧ រៀងទៅ ដែលរៀបវិវាហមង្គលការ ហើយធ្វើកិច្ចនីមួយៗ ទៅតាមន័យក្បួនចាស់ ក្នុងប្រការ ១៤ បានពោលថា “ កាលរាជព្រះបាទសម្ដេច ព្រះជ័យជេដ្ឋា ទ្រង់តែងតាំងទុកជាសណ្ដាប់មកដល់សព្វថ្ងៃនេះ” ។

ន័យ ១ ទៀតថា: កាលព្រះបាទធសរដ្ឋ ជាព្រះរាជបិតារៀបមង្គលការព្រះ រាម និងនាង សេតា, បាននិមន្តឥសី ៨ អង្គ មកថ្វាយទេយ្យទាន បានជាអ្នកនគរធ្វើវិវាហមង្គលការ គេនិមន្តព្រះសង្ឃ ៨ អង្គ មកចំរើនព្រះបរិត្ត កើតមានតាំងពីត្រឹមនោះមក ។

ន័យ ១ ទៀត, ដែលមានស៊ុះស្លាកាំជាប់ពាក្យ, ស្លាកាំណាត់មានប្រសព្វមុខជង់, គោះជង់រង់ជួនពេលា, មេបា ត្រូវបង្គាប់ឲ្យធ្វើជ្រុះ និងជូនកំស្ដុភារបណ្ណាការនោះ ។ ក្នុងក្បួនចាស់បានអធិប្បាយថា “កាលរាជព្រះបាទសម្ដេច ព្រះជ័យជេដ្ឋា ទ្រង់ព្រះរាជនិពន្ធទុកឲ្យជាសណ្ដាប់រៀងមកដល់បច្ចុប្បន្ននេះ ” ។

ឯញ្ញាស្លាពានោះ មានក្នុងក្បួនបុរាណត្រង់ប្រការ ៤ តំណាលថា: មានបុរស ៤ នាក់ ទៅរៀនសិល្បសាស្ត្រជាមួយគ្នា: ម្នាក់រៀនបាញ់. ម្នាក់រៀនឆាយ, ម្នាក់រៀនជ្រោះ, ម្នាក់ទៀតរៀនមុជទឹក លុះរៀនចេះតែសព្វខ្លួនហើយ ក៏នាំគ្នាត្រឡប់មកលំនៅ

ខ្លួនវិញ ។ ដល់មកស្ទឹង ១ បុរសចេះទាយ ។ ថា ថ្ងៃនេះនឹងមានសត្វកយុកក្ស នាំស្ត្រីក្រមុំម្នាក់ មក នឹងបានជាភរិយាយើង ។ ថ្ងៃពីសត្វកយុកក្ស ក្នុងថ្ងៃនោះឯង កចាបយកនាង ទេមរី ជាបុត្រីព្រះចៅក្រាមា ដែលកំពុងក្រសាលក្នុងទឹកស្រះបានហើយក៏ហើរទៅៗ លុះមកដល់ស្ទឹងដែលបុរសទាំង ៤ នាក់នោះឈប់ បុរសចេះបាញ់ឃើញក៏ចាប់ធ្នូបាញ់ទៅត្រូវសត្វកយុក្កក្ស ។ ទម្លាក់នាង ទេមរី ធ្លាក់ទៅក្នុងទឹក ទើបបុរសចេះមុជទឹកក៏មុជទឹកទៅស្រង់នាងនោះបានមក តែនាងនោះស្លាប់ ។ ទើបបុរសចេះព្រោះ ក៏តាំងព្រោះនាងនោះឲ្យរស់ឡើងវិញ ។ បុរសទាំង ៤ នាក់ ឃើញនាងទេមរី មានរូបឆោមលោមពណ៌ល្អក៏ចង់បានធ្វើជាភរិយាតែរៀងៗខ្លួន តែមិនដឹងជានឹងសម្រេចបានទៅលើរូបណា ៗ រឿងនេះក៏កើតជាអគ្គសេចក្ដីដល់ព្រះពោធិសត្វ ។ កាត់សេចក្ដីឲ្យថា នាងនោះត្រូវបានទៅជាភរិយាបុរសដែលមុជទឹកទៅយកនាងនោះ ព្រោះគេបានចាប់កៀកបីតរប៉ះពាល់រូបនាងនោះរួចមុនគេទៅហើយ ( ធម្មតាស្ត្រីមានភរិយាបថល្អ មិនដែលមានបុរសណាមកប៉ះពាល់ដល់ខ្លួននាង ១ ជា ២ ឡើយ ), បុរសចេះទាយ លោកទុកជាបិតា, បុរសចេះព្រោះ លោកទុកជាមាតា, ឯបុរសចេះបាញ់លោកទុកជាបង " ។

គ្រានោះ ព្រះបរមពោធិសត្វ ឲ្យបុរសមុជទឹកនោះហោតផ្កាស្លាព្រះពរ ៣, ផ្កាស្លាព្រៀង ហោតស្លាម្លូ ២១ (តបគុណបិតា), ផ្កាស្លាបន្ទាប់ ហោតស្លាម្លូ ១៤ (តបគុណមាតា), ផ្កាស្លា ចៅ ហោតស្លាម្លូ ៦ (តបគុណបង) បានជាកើតមានផ្កាស្លា ៣ ជាប់ជាតំណតរៀងមកដរាបដល់សព្វថ្ងៃនេះ ។

ដែលគេឲ្យសាមីខ្លួនកូនប្រុស-ស្រីរៀបពិពាហមង្គលការស្លៀកសំពត់សំឡយ ពាក់អាវផាយ ពាក់វែប ប្ដូនសក់នោះ, មានតំណាលក្នុងក្បួនចាស់ថា "កាលព្រះរាមាបួលសាសទ្ធា ទ្រង់បញ្ញត្តិថា: ប្រុសដែលនឹងឡើងសំពះមង្គលការ ត្រូវឲ្យស្លៀកសំពត់សំឡយពាក់អាវផាយ, ស្រីឲ្យប្ដូនសក់, ពាក់វែប, បានជាមានជាប់ជាទំនៀមតាំងពីត្រឹមនោះមកដល់បច្ចុប្បន្ននេះ ។

ក្នុងក្បួនចាស់បានពណ៌នាថា "កាលព្រះរាជកុមារបាននាងណាគ គឺ ជាព្រះរាជបុត្រី ស្ដេច ភុជង្គនាគ ៗ ក៏បានឡើងមករៀបអភិសេកព្រះថោង ៗ ពេលនោះរៀបឲ្យមានអាចារ្យកាន់ពេលាថ្វាយព្រះថោង, ឲ្យព្រះថោងឡើងគង់លើបល្ល័ង្កចាំពេលា ឲ្យមហាកាន់ឈ្មោះរាយប្រជុំ ហើយឲ្យមានភ្លេងត្រែស័ង្ខដង្ហែព្រះថោង ឡើងទៅសំពះមង្គលការ ៗ លុះសំពះទទួលពរជ័យស្រេចហើយ ព្រះថោង នឹង

យាងទៅពិភពនាគ , ពេលនោះជាជោគឲ្យព្រះថោងជាស្វាមី តោងដោយស្បៃនាង ទើបទៅបាន ។ លុះទៅដល់ពិភពនាគវេលាណា នាងនាគក៏យកគ្រឿងប្រដាប់នាគ មកថ្វាយព្រះថោងទ្រង់" ។

ហេតុនេះ បានជាអ្នកនគរយកតម្រាប់តាមគេរៀងមក បើអ្នកណាមួយ រៀបវិវាហមង្គលការកូន·ចៅ គេឲ្យមានអាចារ្យកាន់ពេលា ឲ្យអ្នកយបាំ ពេលា ៗ លុះសំពះ ហើយក្រោកចូលទៅក្នុង "គេឲ្យប្រុស តោងដោយស្បៃស្រី" រួចឲ្យស្រីឲ្យសំពត់ទៅប្រុសផ្លាស់ ជាប់ជាទំនៀមផ្សេង ៗ តាំងពីព្រះថោងតោងស្បៃនាងនាគ ដរាបមកដល់សព្វថ្ងៃនេះ ។

ដែលមានជាប់ជាតំណឲ្យពរជ័យ-ស្វស្តិ៍ នោះ ក្បួនចាស់បានសម្តែងថា: មានបុរសបងប្អូន ២ នាក់ បងឈ្មោះជ័យ ប្អូនឈ្មោះស្វស្តិ៍ ជាបុគ្គលមានបុណ្យអស្ចារ្យ ។ មានរឿងដំណាលថា "គ្រានោះជួនជាផុតវង្សក្សត្រិយ៍ក្នុងនគរកម្ពុជាយើងនេះ អស់នាហ្មឺនសព្វមុខមន្ត្រីពិជ-បរោហិតាចារ្យផ្សងដំរីសេះមង្គលឲ្យស្វែងរកអ្នកមានបុណ្យ, ដំរីសេះនោះក៏ដើរតម្រង់ត្រោះទៅគេហស្ថានជ័យ-ស្វស្តិ៍នោះ ទើបនាហ្មឺនសព្វមុខមន្ត្រីដឹងថា បុរស ២ នាក់នេះមានបុណ្យ ក៏អញ្ជើញបុរសទាំងពីរនាក់នោះឲ្យឡើងជិះដំរីមក ។ បងឈ្មោះ ជ័យ អភិសេកឲ្យធ្វើជាស្តេចក្រុងរាជ្យ ប្អូនឈ្មោះស្វស្តិ៍ ក៏តាំងឲ្យធ្វើជាឧបរាជ ។ វេលាដែលអភិសេក

នោះ ពួកប្រជារាស្ត្រទាំងអស់ ក៏នាំគ្នាស្រែកថ្វាយសព្ទសាធុការថា: "ជ័យហោង!, សួស្តីហោង!, មែនហោង!" ព្រមៗ ទាំងអស់គ្នា ។

ហេតុនេះបានជាកើតមានឲ្យពរជ័យ - សួស្តី តាំងពីគ្រានោះមក ។

x x
x

រីឯរឿងសាកខ្មោចនោះ ក្នុងក្បួនចាស់ពណ៌នាថា: មានបុរសពីរនាក់ ស្និទ្ធនឹងគ្នា, បុរសម្នាក់រៀបវិវាហមង្គលការខ្លួន ខ្វះក្រមួននឹងលុញទៀន ពេលា បានឲ្យខ្មោចម្នាក់ជូនទៅរកឃ្មុំមកសិតជាក្រមួន លុះទៅដល់ព្រៃ ឃើញឈើធំ ១ ដើម មានឃ្មុំច្រើន, ខ្មោចដែលនឹងរៀបការក៏យកបង្អោងទៅ ឡើងដើមឈើនោះប្រយោជន៍នឹងយកឃ្មុំ លុះឡើងទៅដល់ចុងឈើ ខ្មោច ដែលនៅដីក៏យកបង្អោងចេញ រួចយកបន្លាស្រោសគល់ថែមទៀត ហើយ ក៏រត់ទៅប្រាប់ឪពុកម្តាយខាងស្រីថា "ខ្មោចខ្ញុំដែលត្រូវជាកូនប្រសាអ្នកនោះ ខ្លាខាំពាំនាំយកបាត់ទៅហើយ!" វេលានោះជួនជាជិតដល់ពេលានឹងផ្សំ ទៅហើយ មាតាបិតាខាងស្រីបានដឹងដូច្នោះ មិនដឹងជាគិតយ៉ាងណា ទាល់គំនិត ក៏យកខ្មោចបាបមិត្រនោះ ទៅផ្សំនឹងកូនស្រីរបស់ខ្លួនទៅ ។

និយាយពីខ្មោចជាសាមីខ្លួនវិញ លុះបានឃើញខ្មោចរបស់ខ្លួន យក

បង្អោងចេញ ហើយយកបង្ខាមកស្រោសផ្ទោះ ក៏គិតថា "អញនឹងពុះពី ពុងឈើ ក៏ពុះមិនរួចដែរពេលនេះ" ។

គ្រានោះ, មានទេវតា ១ ព្រះអង្គ មកនិម្មិតជាខ្លាឃ្មុំ ១ ឡើងទៅស៊ីឃ្មុំ ក្នុងនោះក៏ប្រថុយស្លាប់, លុះខ្លាឃ្មុំទេវតានោះរៀបនឹងចុះមកវិញ បុរសនោះ ក៏លបតោងកន្ទុយខ្លាឃ្មុំសម្រូតចុះមក រួចមកដល់ដី ហើយក៏ម្នាក់ទៅផ្ទះ ដែលរៀបមង្គលការខ្លួននោះជាប្រញាប់ ដល់ហើយក៏ឡើងលើផ្ទះឃើញ ក្មេកខ្លួនកំពុងតែក្រាបផ្ទឹមជាមួយនឹងប្រពន្ធខ្លួន ខឹងខ្លាំងណាស់ ក៏ចាប់ដាវ កាប់ក្មេកស្ដុមិត្រនោះស្លាប់ទៅ ។ ឈាមខ្ទាតប្រឡាក់កន្ទេលខ្នើយដែល ផ្ទឹមនោះអស់ ។ ពេលនោះអាចារ្យក៏សូត្រមន្តបញ្ជរហើយឲ្យសាយក កន្ទេលដែលប្រឡាក់ឈាមនោះចេញទៅ ។ ឲ្យយកកន្ទេលថ្មីមកក្រាល រួចឲ្យបុរសដែលជាសាមីខ្លួននោះផ្ទឹមចងដៃឡើងវិញ ។

ហេតុនេះ, បានជាកើតមានរឿងសាកន្ទេល - លាក់កន្ទេល តាំងពីគ្រានោះមក ។

⁘ ⁘
⁘

រីកិច្ចដែលឲ្យមាន រៀងផ្ទៃឈើនោះ តាមក្បួនចាស់ដំណាលថា: "កាលព្រះរាមប្រាបលង្កា បាននាំនាងសេតា និងពួកពានរជា បរិពារ, ដល់មកព្រះពន្លាកងព្រៃហិមពាន្តក៏ឈប់នៅទីនោះ ។

គ្រានោះ, មានឥសី ១ អង្គ មកអភិសេកឲ្យពរព្រះរាម ទង់នាង សេតា អស់ពួកពានរទាំងឡាយ ក៏បបួលគ្នាទៅរកបេះផ្លែឈើទុំខ្ចី តាមនិស្ស័យសត្វមកប្រគេនឥសី ។

ហេតុនេះ បានជាឲ្យកើតមានរឿងផ្លែឈើ តាមរឿងនេះ ជាទំលាប់ តាំងពីជំនាន់នោះ លុះមកដល់បច្ចុប្បន្ននេះ ។

សម្តែងមកតាមហេតុដើមដែលជាប់ជាទំនៀមនិមួយ ៗ គេរៀងមក ដោយសង្ខេបខ្លី ៗ អស់សេចក្តីតែប៉ុណ្ណេះឯងហោង ។

## បទនគររាជ

នគររាជតាំងតាមព្រះនគរ ឮខ្ចារខ្ចរគ្រប់ភពម្លប់ដែនដី
ផ្ដោះត្រង់នគរវត្តរង្គល្បាញល្បី ប្រាសាទកំពូលត្រើទង់ជ័យជាតិ,
ភ្លេងនគររាជជាគ្រឿងតន្ត្រី ជោគសួស្តីបេស្តាមហាពិណពាទ្យ
គោរពរាជដំណើរស្តេចយាងយាត សម្រាប់ជាកិត្តិយសឈ្មោះ
នគរ ។

នគររាជអើយនគររាជរម្យ រសៀលស្រទំរងំដូចផ្គរ
លាន់សម្លេងប៉ីសែតាមថ្នាក់ទ្រ ត្រូវសម្លេងស្គរខ្ចរឮគ្រឹមៗ ។
សែនស្រណោះអស់សម័យថ្ងៃទន់ល្ងាច លេងភ្លេង
នគររាជពីរោះរងំ ស្រង្វូតស្រងាត់ថ្វាយក្សត្រយ៍ស្តេចបួលផ្ទំ
លើទេវរត្នរម្យផ្ទំរើបផែបខ្នើយ ។ កែបជាខ្នល់កល់ខ្នងកង
ប្រឹស្តាង្គ(១) ព្រះស្នំគង់ម្លាងកាងកៀកព្រងើយ ប្រកិតឱភា
ព្រះកាណ៌(២)ស្តាប់ហើយបេ នគររាជអើយគួរឲ្យមានសប្បុស្សៈ ។

---

១– ព្រះប្រឹស្តាង្គ "ខ្នង" ។ ២– ព្រះកាណ៌ "ត្រចៀក" ពាក្យភជស័ព្ទ ។

# បទស្ដេចផ្ទំ

ព្រះអង្គស្ដេចផ្ទំ ក្នុងព្រះបន្ទំ លើទែនរត្នមណី ជាទីសុខ-
សាយ ស្ដេចផ្ទំសម្ងំ ព្រះស្នំម្នាបម្នោយ នូតសញ្ចាំងកាយ
សាយសព្ទាឱរ្ស(១) ។ លើរងព្រះសិរ នែបអង្គទាំងទ្វេ អែប
កាយទាំងគូ ផាហ៊ុមរូបធាគ ទ្រង់ស្លៀកទទ្វរ ពីត្រឹមឱរ្ស
ដល់ព្រះស្សូរង(២) ។

ស្ដេចផ្ទំស្កប់ស្កល់ ជូនជំនោរខ្យល់ ផាត់ជំរុម្ភង ៗ
ថែមស្បូវទ្រព្យ ជន្ទ្រីផ្ទូរផង ថ្វាយព្រះប្បាស់ប្បង កំដរស្ដេចផ្ទំ ។

ស្ដេចផ្ទំស្កល់ហើយ មហោរីរាទ់ផ្ទើយ ពិរោះរងំ ធារី
សករាទ់ ធីតាក្រមុំ ច្រៀងបទស្ដេចផ្ទំ សមដោយសម្លេង ។
សមរូបធារី សមនឹងទេពទី សមដោយគ្រឿងភ្លេង សមរូបរង្សី
បក្រីនៅក្មេង សមបារមីច្រេង ព្រះប្រិយមហាក្សត្រិយ៍ ។

ស្ដេចផ្ទំស្កល់ស្កប់ ពីពេលព្រលប់ លុះអគ្រោត្រស្វាត់

១– ព្រះឱរ្ស "ទ្រូង" ។ ២– ព្រះសុរង "ក" (ព. រ. ស.) ។

ទ្រង់តើនបាកទែន ព្រះវិបនបក្រពត្តិ ឡើងទែនមណីរត្ន ក្នុងក្រឡាបន្ទំ ។

បឋមទៀបព្រឹក ស្ទូរស័ព្ទសន្ធឹក គ្រឹកគ្រេងធរណី ដោយសារស័ព្ទភ្លេង ក្រុមក្មេងនារី ដោយព្រះភូមិ ទ្រង់ទឹកំសាន្ត ។

× × ×

## បទព្រះថោន

ឪភ្នំស្រែបអើយ ស្រែបអំតែងឯង មានភ្នំក៏វែង ធំហើយវែងផង ។

× + ×

## បទជ្រុនសម្មាត៌

ស្រណោះអកយំ នៅភ្នំឥស្សរ ស្រណោះអកប៉ូរ នៅភ្នំប្រសិទ្ធិ របងរមាស របងដំរី របងប្អូនស្រី បាក់ទុកមិនលេប ។ បងដើរក្នុងព្រៃក ស្តាប់ខ្មែកវាយំ បងដើរខ្ទង់ភ្នំ ស្តាប់ឃ្មុំយកផ្កា ។ យកតាំងពីប្រាំង ធ្លាក់ដល់វស្សា ស្តាប់ឃ្មុំយកផ្កា បំពេញក្បាលទំក ។

× × ×

## បទសំពោង

ស្រីសសំពោង ចេញពីក្នុងរោង ញឹកញ៉ាក់ទៅណា ដៃឆ្វេងកាន់ឃ្នុំ ដៃស្ដាំកាន់ស្លា ញឹកញ៉ាក់ទៅណា យកស្លាឲ្យបង ។ បងសុំស្លាស្រី ស្រីថាស្លាគ្មាន បងចាប់ដៃបាន ស្លាពេញទាំងថ្នាក់ ។ ត្រង់ស្លានិងម្លូ ប្អូនឲ្យបងបាន ឯត្រង់ខ្លួនប្រាណ ឲ្យមិនបានទេ ។

សំពោងផ្ការាំង យកដៃទៅឃាំង ក្នុងវាំងសិរីវុទ្ធ ផ្ការាំងបាយអ រៀបថ្មីប្រកិត ក្នុងវាំងសិរីវុទ្ធ យកស្រីឲ្យបាន ។

x x x

## បទសារិកាកែវ

សារិកាកែវអើយ សារិកាកែវកើប បងល្បួងឲ្យសើប ម្ដេចក៏ស្រីយំ គន់មើលជើងសក់ រត់ជួរមេញ គន់មើលជើងធ្មេញ ល្អហើយសមផង ។ សារិកាកែវអើយ សារិកាកែវកង ស៊ីផ្លែដំបង ប្រចឹកគ្នាលេង ស្លាបវាចាក់ក្បាច់ មាត់វាធ្វើភ្លេង ប្រចឹកគ្នាលេង លើមែកព្រឹក្សា ។

v v v

## បទដាត់ដាយ

ស្បែនេះស្បែពីណា ស្បែនេះស្បែពីណា
ស្បែលោកមេបា ឡក្រវាត់បើកបាយស្រី ។
ដាវអើយដាវដែក ដាវអើយដាវដែក
ដាវនេះបម្លែក បានមកពីកំពង់ស្វាយ ។
ផ្ញើពីឪពុក ស្រោបពីអ្នកម្ដាយ
ដាវដែកកំពង់ស្វាយ ឈ្មោះមារសត្រូវ ។

× × ×

## បទបំពេ

ខ្មោអើយស្រីខ្មៅ ខ្មោអើយស្រីខ្មៅ ល្ងាចណាបងទៅ ខ្មៅចាប់ផ្តៃបង ។ អាលោខ្មៅឆាងចាប់ អាលុកខ្មៅស្រីបង ខ្មៅចាប់ផ្តៃបង ល្ងាចបងទៅលេង ។

កំពោៗអើយ បានទូកពីណាធ្លង មានតែទូកបង ធ្លងកំពោអ្នូនរូប ។ ថ្ងៃអើយអ្នកថ្ងៃ ថ្ងៃអើយអ្នកថ្ងៃ

ខែភ្លឺដូចថ្ងៃ នរណាហៅថ្លៃមក ។ កាំភ្លើងបាំជ្រែង ដាវវែង
បាំប្រក ប៉ុះនរណាហៅថ្លៃមក បានជាព្រលប់អ្នកដល់ ។

× ×
×

## បទដំរីយោលដៃ

ដំរីភ្លុកទក បរមកបិញ្ចាប អូនអើយកុំខ្លាច
សណ្ដានដនអើយ ដំរីបងទេ ។ ដំរីបងមួយ ឈ្មោះវាអាស្នួន
បរទៅស្រុកយួន ពីព្រឹកវិលល្ងាច ។

× ×
×

## បទអាឡេ

អាឡេ ៗ អើយទៅបាញ់ប្រវឹក បាញ់ដាំងត្រូវទឹក
ត្រូវគុម្ពស្រងៃ ។

× ×
×

## បទដាក់ដាយ

ព្រហាមផ្កាយរះ បញ្ញៀមកសំពះ ពេលាបានហើយ អនអើយស្រីអន សូមបើកវាំងនន សូមអនមកផ្ទឹម សូមទាំងញាំងផ្ទិត សូមទាំងញាំងដៃ សូមអនមបហាវ្លៃ ពេលាបានហើយ !

ចប់ចម្រៀងប្រពៃណី ដោយសង្ខេប

# ភាគទី៣

សេចក្ដីពន្យល់ខ្លីៗ និងផែនទីរបៀប

## ១១–ប៉ៃប៊ូវ

ជើងមុន អ្នកជូរ ទៅតែដៃទទេបាន

ជើងទី ២, អ្នកជូរ ទៅតែដៃទទេទៀត ដើម្បីសួរចិត្តថ្លើមមាតាបិតាខាងកូនស្រី, បើប្រហែលជាសង្ស័យ

ជើងទី ៣, ត្រូវឲ្យរៀបស្លាម្ហូបចិត្តចូលតាមគួរសមយកទៅផង គឺត្រូវរៀបឲ្យមានគូ ។

(កន្សោក ១ ឬ ជើងពាន ១ ត្រូវរៀបម្លូខ្លះ ស្លាខ្លះ ថ្នាំជក់ខ្លះ កំពោរខ្លះ) ។

★

## ១២_ដណ្ដឹង

រកស្រីអ្នកមុខអ្នកការ ៣ នាក់ ដែលមានគូស្រករល្អមិនដែលអត់ត្រូវឲ្យធ្វើជាអ្នកជូរទៅនិយាយដណ្ដឹង ។ ត្រូវរៀបរង់សម្លាប ១ គឺ :

រង់(១) គេត្រូវក្រាលកន្ទេលបញ្ចព័ណ៌ (ប្រពុម) រៀបគ្រឿងប្រអប់ស្លាគ្រប់ប្រដាប់ ព្រមទាំងស្លាម្លូ, ថ្នាំជក់, ស្លាផ្ដា, កំពោរ មានរបស់ទាំងនេះដែ

---

១– បើគ្មានរង់ ប្រើជាសម្រាក់ ឬ ជាសស្កាងក៏បាន ។

ទៅផង គឺមានស្លាម្ហូបកាលចែកខ្លះ ប៉ុន្តែត្រូវថែមឲ្យមានជាផ្លែឈើ ឬ នំ ១ គូ ឬ ២ គូផង ។

★

## ១៣–មហានិយាយការ (ត)

អ្នកជូនាំមហាមកជូនមេបាប្រុស ត្រូវមានថង់ស្លា, ពានស្រា (ស្រា ១ ដបតូច និងកែវតូចៗ ១ គូ) អ្នកជូនស្រី ត្រូវប្រើស្លាសម្លាប ជាផែល ។

★

## ១៤–ទទួលអំណារ

### ស៊ីស្លាជក់ - ស្លាកន្សែង

មានក័ន្ទក្រាបណ្ណាការជំនូនបន្ទិចបន្តួច ៤ ឬ ៦ គូ ។

ធ្វើតែក្រុមញាតិនិងអ្នកជិតខាងប៉ុណ្ណោះ (បើមិនធ្វើចាំធ្វើរួមទៅលើស្លាធំ ក៏បាន) ។

★

## ១៥– ស៊ីស្លាដំកំដាប់ពាក្យ

ត្រូវរៀបកស្តុកាបណ្ណាការយ៉ាងច្រើន ព្រមទាំងរបស់កំដាប់ចិត្ត គឺមាស ប្រាក់ និងគ្រឿងអាភរណៈទាំងពួងតាមកម្លាំងធនធាន ដោយគួរសម ។

ត្រូវអញ្ជើញញាតិមិត្រលៀងក្រយាហារ ១ ពេលព្រឹក ។ សម័យឬនេះ, ខ្លះគេលើកទៅរួមដល់ថ្ងៃស៊ីកំណត់តែម្តងក៏មាន ស្រេចហើយតែនិងព្រមព្រៀងគ្នាទាំងសងខាង ។

★

## ១៦– ជូនពេលាចេកមាស

គប្បីតែជូនពេលាចេកមាសរួមជាមួយ និងជូនរបស់កំដាប់ចិត្តនោះតែម្តង តដាលំដាប់ដាប់គ្នាមក ។

ឯពេលាចេកមាស ត្រូវខាងប្រុសគេហោពាក្យរម៉ែលឲ្យ រៀបជាសេចក្តីសរសេរលើក្រដាសក្រហម ដាក់ក្នុងស្រោមក្រហម តម្កល់លើពាន ១ ជាន់ ឬ ២ ជាន់ មានទាំងតែលាវ ១ គូ, តែ ១ គូ, ចេកទុំ ១ គូ អមទៅផង, ប៉ាំងឆ័ត្រក្រហម, លេងភ្លេងហែនាំមុខឡើងទៅជូនលោកមេបា ដូចមានផែនទីពន្យល់តទៅនេះ :

(សេចក្តីពេលាមានជាគំរូនៅខាងចុង)

# ផែនទីហែពេលាចេកមាស



ភ្លេង



ឆ័ត្រ



ពេលា



ចេក



តែ



នំ

## ១៧- កន្លែងសង់រោងមង្គលការ

១- ត្រូវសង់រោងផ្កាស្លា ៣ ល្វែង សំរាប់ឲ្យកូនប្រុសនៅ (ត្រូវរើសទិសតាមក្បួនហោរាសាស្ត្រ) ។

២- រោងបុងកៅឥតកំណត់ល្វែងទេ ឲ្យល្មមតែធ្វើការបានស្រួល ។

### ទិសសង់រោងផ្កាស្លា

| | |
|---|---|
| ផល្គុន<br>ពិសាខ | ទិសទក្សិណ |
| អាសាឍ | ទិសបស្ចិម |
| កត្តិក | ទិសឧត្តរ |
| បុស្ស | ទិសបូព៌ |

ពីបុរាណកាល គេរាប់ខែទាំង៤នេះ ថាជាខែមានបុណ្យលក្ខណ៍ គេនិយមរៀបមង្គលការតែក្នុងខែទាំង៤នេះ ហោរាចារ្យគន់គូរលេខអត្ថៈ រកពេលាកសី ក៏នៅតែក្នុងខែទាំង៤នេះដែរ ។ តែឥឡូវនេះ គេការបានគ្រប់ខែទាំងអស់ៗ បើដូច្នេះតាមតែសន្និដ្ឋានបុះ ជឿណាក៏បានមិនជឿណាក៏បាន។

### ពិធីមង្គលការ

ទម្លាប់ទំនៀមរៀបមង្គលការអាពាហ៍ពិពាហ៍របស់ខ្មែរតាំងពីបុរាណរៀងមក លោកបានកំណត់ទុកជា ៣ ថ្ងៃ :

## ២៨–ថ្ងៃទី២ (ស៊ីកំណត់)

ត្រូវប្រជុំញាតិមិត្រ នៅព្រឹកថ្ងៃសូត្រព្រះពុទ្ធមន្ត ជូនកស្ដុការ បណ្ណាការម្ដងទៀតសំរាប់ស៊ីស្លាកំណត់ និងរៀបវិវាហមង្គលការធំ ៗ

★

## ២៩–ពិធីកាត់សក់–បំរើនព្រះពុទ្ធមន្ត

### ក) ពិធីកាត់សក់

កាត់សក់គេត្រូវរៀបគ្រឿងសំអាងកាយ : ក្រាស, កាំបិតកោរ, កន្ត្រៃ, ទឹកសំប៉ូរ ១ ផ្ដិល, ចង់រង ១ គូ, កញ្ចក់ឆ្លុះ ១, រណ្ដាប់ទ្រទឹប ព្រះពិស្ណុការ ១ ប្រដាប់ (រៀបដាក់នៅមុខសាមីខ្លួន) ដូចមានផែនទី និងសេចក្ដីពន្យល់តទៅនេះ :-

# ផែនទីកាត់សក់




១ - តោកគ្រឿងសំអាងកាយ
២ - ជើងពាន ក្រាស-កាំបិតកោរ-កន្ត្រៃ
៣ - ផ្តិលទឹកសំបួរ
៤- } ជង់រង
៥- }
៦- កញ្ចក់ឆ្លុះ
៧- រណ្តាប់ព្រះពិស្ណុការ
៨- សាមីខ្លួនកូនស្រី

# សេចក្ដីពន្យល់អំពីរបៀបកាត់សក់

បុកណាលោករៀបចំកាត់សក់ឲ្យកូនស្រី-ប្រុស តាមរបៀបខាងលើនេះ នៅពេលសៀលដូចគ្នា ។ កូនស្រីកាត់សក់នៅលើផ្ទះ, កូនប្រុសកាត់សក់នៅក្នុងរោងផ្កាស្លា ។ ប្រដាប់ប្រដានិងគ្រឿងសំអាងកាយត្រូវរៀបចំរៀងខ្លួន, ឯថង់រង់ត្រូវចែកគ្នា ១ ម្នាក់ ។

ឥឡូវនេះ, គេនិយមកាត់សក់រួមកន្លែងគ្នាតែ ១ ទៅហើយ គឺគេកាត់ម្ដងម្នាក់, ហេតុនេះបានជាខ្ញុំរៀបថង់រង់ទាំងពីរឲ្យនៅក្នុងទីតែមួយ ។ ចំណែកករណ្ដាប់ព្រះពិស្ណុការ គេត្រូវរៀបឲ្យមានពីរប្រដាប់ ព្រោះជាងស្រីកាត់ឲ្យកូនស្រី ជាងស្រីនោះគេយករណ្ដាប់របស់គេទៅហើយ ។ លុះដល់ជាងប្រុសកាត់ឲ្យកូនប្រុស ជាងប្រុសនោះក៏គេត្រូវយករណ្ដាប់គេ ១ ផ្នែកទៅទៀត, គ្រាន់ណោះស្រេចតែលោកចុះ ។

អំពីពិធីបង្គុយ – បុកណាពេលកាត់សក់ឲ្យកូនស្រី លោកឲ្យកូនស្រីអង្គុយពបនៅកន្ទេលឬគ្រែ ហើយដាក់ជើងម៉ាធំ ១ ឲ្យល្មមតែចុះគ្រឿងប្រដាប់ទាំងអស់ពីមុខ (ដូចមានផែនទីពន្យល់ស្រាប់) ។ ដែលលោករៀបឲ្យអង្គុយពបយ៉ាងនេះ ព្រោះចាស់ទុំស្រីប្រុសដែលទៅអង្គុយកំដរនោះ

លោកអង្គុយក្រោម មិនសមរម្យនឹងឲ្យកូនចៅអង្គុយកៅអី(១)សំយុងជើងខ្ពស់ជាងចាស់ទេ ព្រោះអស់លោកចាស់ទុំទាំងនុះ លោកប្រកាន់ណាស់អំពីគារវកិច្ចនេះ ។

តែមកដល់សម័យទំនើបនេះ លោកជាមាតាបិតាចូលចិត្តតម្កើងកូនឲ្យខ្ពស់ជាងខ្លួន ក្មេងគិតដល់ឋានន្តរសក្តិក្មេងនឹងចាស់សោះ ។ ចំណែកឯក្មេងវិញ គេថាគេពិបាកបត់ជើងណាស់ ឬ ថាបត់ជើងមិនកើត ។ ចុះកាលពីស៊ីកំណត់ក៏យើងអង្គុយពបកើត, កាលលោកចំរើនព្រះពុទ្ធមន្តក៏អង្គុយពបកើត, កាលសំពះផ្ទឹមក៏អង្គុយពបកើត, ចុះដល់ទៅពេលកាត់សក់ ហេតុដូចម្តេចក៏ថាអង្គុយពបមិនកើត ? ត្រង់ណោះសូមលោកអ្នកពិចារណាចុះ ។ ខ្ញុំគ្រាន់តែជំណាលជូនឲ្យបានជ្រាបប៉ុណ្ណោះទេ, លោកអ្នកសម័យនិយមធ្វើយ៉ាងណាក៏ស្រេចនៅចូលចិត្តចុះ ។

រីឯកូនប្រុស ត្រូវរៀបតុ-កៅអី ដូចសព្វថ្ងៃនេះត្រូវហើយ ព្រោះគ្នានៅពេលក្រាលកន្ទេលផ្ទាល់នឹងដី ។ ជំនាន់ដើមស្រុកគ្មានកៅអី រកអ្វីឲ្យអង្គុយមិនបាន គេយកត្បាល់បុកអង្ករ មកផ្កាប់ឲ្យអង្គុយជំនួសកៅអីក៏មាន ។

១_ បើចង់ឲ្យសាមីខ្លួនអង្គុយកៅអីក៏បាន តែត្រូវរកកៅអីឲ្យចាស់ទុំទាំងនុះអង្គុយឲ្យបានគ្រប់គ្នាផង ទើបសមរម្យ ។

រឿងកាត់សក់នេះ ស្រេចតែលោក-អ្នកធ្វើឲ្យស្រួលចុះ ព្រោះជាកិច្ចៗ សំរាប់បំពេញពិធីយកសិរីជ័យជោគទេ, ព្រោះសក់យើងបានកាត់ស្អាតរួចមុនទៅហើយ. កូនស្រីខ្លះក៏បានអ៊ុតសក់នៅហាងរួចអស់ទៅហើយដែរៗ

⁂

## ខ) ពិធីចំរើនព្រះពុទ្ធមន្ត

ចំរើនព្រះពុទ្ធមន្ត គេត្រូវរៀបចំកន្លែងឲ្យត្រឹមត្រូវ គឺឲ្យមានតុតូច ១ ល្មមជាអាសនៈតាំងគ្រឿងសក្ការៈនិងព្រះពុទ្ធរូបជាដើម ។ តុនោះរៀបដាក់នៅមុខជាប់និងជញ្ជាំងបន្ទប់កូនស្រី, ដូចមានគំរូផែនទីខាងក្រោមនេះ :–

### ផែនទីកន្លែងចំរើនព្រះពុទ្ធមន្ត




នៅលើតុតម្កល់ព្រះពុទ្ធរូបត្រូវមាន : ១– ព្រះពុទ្ធរូប, ២– ថូផ្កាស្រស់, ៣– ប្រដាប់ដោតធូប - ទៀន, ៤– ស្លាធម៌ទ្រង់គ្រឿងកន្ទុយប្រើស ១ ។

## រណ្ដាប់ចំរើនព្រះពុទ្ធមន្តដូចមានផែនទីខាងលើ

១ – តុតម្កល់ព្រះពុទ្ធរូប និងគ្រឿងសក្ការៈបូជា

២ – ស្លាធមិទ្រង់គ្រឿង

៣ – ព្រះសង្ឃ ៥ អង្គ

៤ – ផ្ដិលទឹកសំបួរ

៥ – ផ្កាស្លា

៦ – អង្ករជ័យ និងពពិល

៧ – តោកដាក់ទៀនពពិល - ម្លូនិងស្លាសំពប់ដោតផ្កាស្លា

៨ – ថង់រង

៩ – ថង់រង

១០ – កូនស្រី

១១ – កូនប្រុស

១២ – អាចារ្យ

១៣ – អ្នកមហា

១៤ – អ្នកថ្លៃ

១៥ – កម្លោះ ៤ នាក់ កំដរកូនប្រុស

១៦– ក្រមុំព្រហ្មចារិនី ៤ នាក់ កំដរកូនស្រី

១៧– ចាស់ទុំ

១៨– ភ្ញៀវ

១៩– អ្នកភយហោះ

ត្រូវចាំថា :

ក – រៀបចំយ៉ាងណាទៀសវាង កុំឲ្យសាមីខ្លួនទាំងពីរនាក់បែរមុខទៅទិសខាងលិចឲ្យសោះ ។

ខ – កុំភ្លេចថា កូនស្រីត្រូវអង្គុយនៅមុខបន្ទប់ខ្លួន ឬ នៅធ្នឹមទិងលោកគ្រូដើមអាសន៍ ។

គ – កន្ទេល ឬ កំរាលសំរាប់កូនទាំងពីរ ត្រូវក្រាលឲ្យឈៀងឈមមុខបន្ទិចកក្តា ដូចមានក្នុងផែនទីខាងលើនេះជាកំរូសំរាប់ ។

× ×
×

# ខ ១០-១១ រណ្ដាប់សែនប្ដឹងដីដូនដីតា
# ញាតិការ ៧ សន្ដាន

១- ចំអាប ១ គូ

២- បង្អែម ១ គូ

៣- មាន់ស្ងោរ ១ គូ

៤- ក្បាលជ្រូកស្ងោរ ១ គូ

៥- បាយពានធំ ១ គូ

៦- ទឹក ២ ផ្ដិល

៧- ស្លាបារី ២ ពាន

៨- កន្ទេល ១, ខ្នើយ ១ ក្រាលសំពត់សពីលើ (ក្រាលឈមមុខទៅរកទិសដង្ហើមរស់) ។

៩- ថង់រងទាំងពីរ និងពានស្រាទាំងពីរ

១០- ទៀបបើកបាយស្រី ១ គូ

១១- ផ្ដិលទឹកសំបូរ និងអម្បោះចងដៃ

១២- ប្រណាក ១ ឬ អកកំបោរ ១ "សំរាប់កូនស្រីកាន់"

១៣- ដាវ ១ (សំរាប់កូនប្រុសកាន់) ។

x x
x

ខ ១០-១១ (គ)

របៀបរៀបសែន

—o—

## — ដែនទីរៀបសែន —




(មានសេចក្ដីពន្យល់នៅខាងក្រោយ)

ត្រូវមានពាន ១, សប-ស្លាបព្រា ១, កាំបិតស្នា ១, កន្សែងជូតដៃ ១ (សំរាប់ជាប់សំពែពាន ទាំងពីរប្រដាប់) ។

ត្រូវយកស្រាពីពាន ឬ ពីអ្នកមហា មកគ្រួចដាក់[illegible]សែនដែលជាប់ដាក់[illegible]នោះ ។

# រណ្ដាប់រៀបសែនតាមគំរូដែលទីខាងលើ

១– ផ្តិលទឹកម្ខាង ១, ពានស្លាបារីម្ខាង ១

២– បង្អែមឆ្វេង - ស្ដាំ

៣– បំអាបឆ្វេង - ស្ដាំ

៤– ចានបាយធំឆ្វេង - ស្ដាំ

៥– មាន់ស្ងោរឆ្វេង - ស្ដាំ

៦– ក្បាលជ្រូកស្ងោរឆ្វេង - ស្ដាំ

រៀបដាក់ពីមុខ :

៧- ផ្តិលទឹកសំបូរ

៨- ទៀប ១ គូ

៩– ជង់រង់តាំងពីរ

១០– អាចារ្យ

១១– អ្នកផ្ទះ

១២– អ្នកមហា

រៀបដាក់ពីក្រោយ :

១៣– អ្នកកំដរ

១៤– ញាតិជុំវិញ :

សាម័ន្ធកណ្ដាល

# ជរទ្វីមរស់ប្រចាំថ្ងៃ

| | | |
|---|---|---|
| អាទិត្យ | នៅទិស | ឧត្តរ |
| ចន្ទ | នៅទិស | និរតី |
| អង្គារ - ពុធ | នៅទិស | ឦសាន |
| ព្រហស្បតិ៍ | នៅទិស | បូព៌ |
| សុក្រ | នៅទិស | អាគ្នេយ៍ |
| សៅរ៍ | នៅទិស | ទក្សិណ |

## ខ ១៣- ដាវខាន់ស្លា

រណ្តាប់:

១- គ្រឿងសំអាងយ៉ាងល្អ ១ ប្រដាប់ រៀបដាក់លើតោក ១ ឬ ពានប្រាក់-មាស ១ (តាមមាន) គឺម្សៅរមៀត ទឹកអប់ ប្រេង ។ល។

២- កញ្ចក់ឆ្លុះមុខ ១ មានជើង ។

៣- ក្រាស់សិតសក់ ១ ឬ ២ តម្កល់លើក្អួតតុមាស ឬ ប្រាក់ ។

៤- ខ្សែគ្រលួតពណ៌ក្រហម ១ តម្កល់លើតោក ឬ តុប្រាក់ ។

៥– បេកមាសពីរស្នូត ទំងន់តែលាវ ២ ពាន ដែលគេជូនពីព្រឹក ជាមួយពេលា ។

៦– ជូនថ្លៃ ១ ចិតទៀតឲ្យល្អ តម្លល់លើពាន ១ ព្រមទាំងកូនស្លាបព្រាតូច ១ ផង ។

៧– ចង់រង ១

៨– ទឹក ១ ផ្តិល

៩– ម្តាយ

១០– ឪពុក

១១– កូនស្រី

១២– អ្នកជូរ

១៣– អ្នកមហា

## — រណ្តាប់ផាវខាន់ស្លារៀបតាមដែនទីខាងក្រោមនេះ —




ភ្លេង:

ប៉ីពក ១

ទ្រ ១

អ្នកច្រៀង ១

# របៀបរៀបជាវខាន់ស្លា

រណ្ដាប់ទាំងឡាយត្រូវរៀបចំដូចមានផែនទីជូនជាប់ខាងលើនេះ ។

យកកន្ទេលថ្មី ១ ឬ ព្រំយ៉ាងល្អ ១ ទៅក្រាលនៅល្វែងបន្ទប់ (កន្លែងដែលកូនស្រីអង្គុយស្ដាប់លោកសូត្រព្រះពុទ្ធមន្ត) ។ រៀបគ្រឿងសំអាង (កញ្ចក់ធ្មុះ), ក្រាស់សិតសក់ នៅលើជើងម៉ា ១ យ៉ាងល្អ ឬក្រាលកំរាលយ៉ាងល្អ ។ ឆ័ត្រដាក់ខាងត្បូង ។ ចេកមាស នំតៃលាវ ដូងខ្ចី និងថង់ផេអ្នកជួរ និងអ្នកមហា ទៅខាងស្ដាំ ។ ឪពុកម្ដាយកូនស្រីអង្គុយទន្ទឹមគ្នាក្រោយជើងម៉ា ។ កូនស្រីដែលរៀបការ អង្គុយក្រោយឪពុក-ម្ដាយ បាំងឆ័ត្រជូន ។

ភ្លេងត្រូវលេងបទ អង្គររាជ, ខ្លាង៉ំ, បណ្ដាគកោងស្រាយ ហើយច្រៀងទំនុករៀបរាប់កាត់តម្លៃកូនស្រី ដែលលើកឲ្យមានប្ដី ។

អ្នកមហា និងអ្នកជួរត្រូវយកផ្លែចេកមាស និងនំតៃលាវ ទឹកដូងជូនឪពុកម្ដាយកូនស្រីពិសា ហើយជំរាបថា “ខ្ញុំជាអ្នកជួរ និងអ្នកមហា សូមប្រណិប័តន៍អញ្ជើញលោកសាមីដើមការ ជាមាតាបិតាកូនស្រី ពិសាកំសាន្តនូវផ្លែចេកមាស ដីផ្អែម ទឹកផ្អែម ដើម្បីជាវខាន់ស្លាបំពេនសិរីជ័យមង្គលមហាប្រសើរឲ្យកូនស្រីលោក-អ្នក ដែលលោក-អ្នក រៀប

អាពាហ៍ពិពាហ៍ ទុកដាក់ឲ្យមានប្តីក្នុងថ្ងៃនេះ ជាថ្ងៃនក្ខត្តឫក្សល្អពទឹក មហិមា . . . . .” ។

បើលោក-អ្នកពិសារួចហើយកាលណា សូមអញ្ជើញគាត់តែងកាយាដោយគ្រឿងគន្ធពិដោរ មានម្សៅ និង ទឹកអប់ជាដើម ហើយឆ្លុះកញ្ចក់ សិតសក់ បំពេញកិច្ចប្រសិទ្ធិការ ប្រកបដោយលក្ខណៈប្រិមប្រិយ៍ ជាទីកេកយឲ្យកូនស្រីរបស់លោក-អ្នក!

⁂

## ខ ១៤–ជុំពេលា

ត្រូវយកគ្រឿងប្រដាប់ដែលជាខាន់ស្លាប្រើការ ជំរាបមេបា សុំជុំពេលាឲ្យកូនប្រុសសំពះស្លាព្រះពរ គោរពលោកមេបា ត្រកូល រៀមច្បង និងសុំកូនស្រីលោកមេបា ប្រដាប់ប្រដាតែងកាយចេញមក ផ្ទឹមនិងកូនប្រុស តាមពេលដែលហោរាចារ្យគន់គូជូនមកសព្វគ្រប់ក្នុងទំព័រ ពេលាបេកមាស ។

⁂

## ខ ១៥–ដោតផ្កាស្លា

គ្រឿងប្រដាប់មានដូចតទៅៈ

១– កូនតុ ៣ (ស្ពាន់ ឬ ប្រាក់ ឬ មាស) តូច-ធំជាន់គ្នាបន្តិចបន្តួច

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

២– ពានប្រាក់ ឬមាស ឬកែវជើង ៣

៣– ម្លូ ៤៨ សន្លឹក

៤- ផ្លែស្លាខ្ចីតូចៗ ឬ ស្លាស្ងួត ៤៨

៥– អម្បោះឆៅសំពប់ចង

៦– ទៀនក្រមួនឃ្មុំ ៣ (កងក្រើសបត្តិប)

៧ ប្រាក់ខាន់ស្លា ១ ណែន ឬ ១៦ រៀល (ជាសាច់ប្រាក់) ។

— ផែនទីជើងផ្កាស្លា —



កូនតុ — ពាន ឬ កែវជើង — ចង់ពាន តម្រួតគ្នា — ផ្កាស្លា ដោត ហើយ

ក្បួនខ្លះយកម្លូ-ស្លាត្រឹម ៩-៧-៥ ជាកំណត់ គឺ:

ផ្កាស្លាច្បង: ម្លូ ៩, ស្លា ។

ផ្កាស្លាប្អូន : ម្លូ ៧, ស្លា ៧ ។

ផ្កាស្លាពៅ: ម្លូ ៥, ស្លា ៥ ។

យ៉ាងនេះគេកប់តាមស័ក្តិ ហៅថា "អំបូរឧត្តមស័ក្តិ-អំបូរមធ្យមស័ក្តិ អំបូរសាធារណស័ក្តិ" ឯចុងផ្កាស្លា ដោតឲ្យស្មើចុងក៏បាន សំយាកចុងក៏បាន ។

ពេលដោតផ្កាស្លាត្រូវឲ្យអុជទៀន ១ និងធូប ៣ សរសៃ សុំឲ្យសាមីខ្លួនបានសុខបានចំរើន ។

ឲ្យលេងភ្លេង តាជាង់-សារាយអណ្តែត-សារាយ-ណែងណង ។

x x
x

## ខ ១៦ - រង់ចាំពេលា

ដល់ពេលចាំពេលាត្រូវយកផ្កាស្លាទាំង ៣ ទៅតម្កល់នៅកនទេវតា ។

ពេលកំពុងអង្គុយចាំពេលា :

- លេងភ្លេង ជារី-ស្តេចដើរ ។
- តុ ១ នៅពីមុខកនទេវតា គេតម្កល់បង់រង-ពានអង្ករជ័យ និងពពិល, ពានម្លូជ័យ-ស្លាជ័យ-ទៀន-ផ្កាស្លា ។

ផែនទីរៀបចំភ័ស្តុភារតម្កល់លើតុ
មុខ រានទេវតា



## របៀបរៀបចំដាក់លើតុម្ហូបពិធីភ្ជាប់ពាក្យ

## តាមដែលឃើញខាងលើ

១ } ២ } ចានឆ្នាំង

៣– អង្ករដំណើរ គេច្រើនដាក់ក្នុងផ្តិលសំរិទ្ធ

៤– ស្លាដំណើរ - ម្លូដំណើរ

៥ } ៦ } ទៀន

៧ } ៨ } ៩ } ផ្កាស្លា

១០– កូនប្រុស

១១– អាចារ្យ × ×

×

ខ ១៧–

# ថ្ងៃទី៣– សំពះផ្ទឹមជាកិច្ចបញ្ចប់មង្គលការ

កាលណាពេលាបានហើយ អាចារ្យបង្គាប់ឲ្យវាយឈ្មោះ ៣ បទ

សាមីខ្លួនកូនប្រុស-ស្រី ត្រូវលើកដៃសំពះ ។

## ក្បួនហែកូនប្រុសឡើងទៅសំពះផ្ទឹម :

អាចារ្យលីផាវដើរមុខ

១– អ្នកផ្លុំ ..... អ្នកមហា

ថង់រង ថង់រង

២– ពានអក្ករជ័យ - ស្លាជ័យ (១ នាក់)

៣– ពានម្លូជ័យ - ស្លាជ័យ (១ នាក់)

៤– ទៀបបើកបាយស្រី (២ នាក់)

៥– ផ្កាស្លាច្បង

៦– ផ្កាស្លាកណ្តាល

៧– ផ្កាស្លាពៅ

៨– សាមីខ្លួន

អ្នកភ្លេងត្រូវនៅលើផ្ទះ ជិតកន្លែងផ្ទឹម ដើម្បីងាយហៅប្រើឲ្យកំបើកវាំងនន កំបើកបាយស្រី, កំសាកខ្លួល ៗ

– សំពះផ្កាស្លា លេងភ្លេងព្រះថោង ៗ

– បើកវាំងនន លេងភ្លេង អន - សសរកញ្ចោង ៗ

– កូនស្រីចេញមក លេងភ្លេងជាងជាត ៗ

– ផ្ទឹម លេងភ្លេងជាតព័ទ្ធ ៗ

- បង្វិលពពិល លេងភ្លេង ជុំគ្រែ ។

- បង់ដៃ លេងភ្លេង ចាយខុង ។

- ចូលទៅក្នុង លេងភ្លេង លោមពាជ់ - ចាយខុងតូ - ចាយខុងជៀវ - ឆប់ឆឹកា ។

× ×
×

## ផែនទីសំពះផ្ទឹម


អាសនៈព្រះ
១១ អាចារ្យ
១២ អ្នកជូន
១៣ អ្នកមហា
អង្ករជ័យ ផ្តិលចំណងដៃ
ជើងរង
១
៣
៥
៦
៤
២
ជើងរង
ទៀប
ទៀប
កែបសំពះ
៧
១៤ ផ្កាស្លាច្បង
១០ កូនស្រី
៩ កូនប្រុស
១៥ ផ្កាស្លាកណ្តាល
៨ កម្រាលសំពត់សារបាប់
១៦ ផ្កាស្លាពៅ
បង្វិលពពិលទៅទក្ខិណាវត្ត
កម្រាលត្រៃ
កន្ទេល

## រណ្ដាប់រៀបសំពះដ្ហឹមតាមគំរូដែលមានខាងលើ

## រាយតាមមនុស្សនិងរណ្ដាប់

១ }<br>
 . . . ថង់រង<br>
២ }

៣ }<br>
 . . . ទៀប<br>
៤ }

៥– អង្ករង័យ - ពពិលមួ - ទៀនពពិល

៦– ផ្តិលទឹកបំណាន់ដៃ - ទៀនពេលា

៧– កែបសំពះ

៨– កំភលធ្វើអំពីសំពត់សារបាប់ - ឬ - ផ្កាមាស ឬ - ល្បើក

៩– កូនប្រុស

១០– កូនស្រី

១១– អាចារ្យ

១២– អ្នកផ្ទូរស្រី

១៣– អ្នកមហា

១៤– ផ្កាស្លាព្យង់

១៥– ផ្កាស្លាកណ្ដាល

១៦– ផ្កាស្លាប្អូន

កាឆ្ងែដសិតះដ្ឋឹម

*ត្រូវក្រាលកន្ទេលឈមទៅរកដង្ហើមរស់*

*(អាហារជាអ្នកបង្កុលបញ្ហាញ ទិងជាអ្នកតាក់តែងទាំងអស់ ក្នុងពេលដ្ឋឹម)*

## ត្រូវរើសអាហារបន្តិច កុំយកអាហារផ្សំស៊ី

× ×
×

# គំរូទៀន



ក ខ គ ឃ

កុំភ្លេច– ទៀនដែលប្រើប្រាស់ក្នុងឱកាសមង្គលការ ត្រូវប្រើទៀនក្រមួនឃ្មុំតាំងអស់ មានធំ មានតូច ដូចតទៅ :

ក– ទៀនបំរើ · តូចល្មមតាមជម្មតា

ខ– ទៀនជជ័រជ · ក្រើសបន្តិច វែងប្រហែល១ម៉ែត្រ តែគេមូរចុងម្ខាង

គ– ទៀនពពិល · ក្រើសជាងទៀនជជ័រជ វែងប្រហែល ៣០ សង្ទីម៉ែត្រ តែគេបត់ជាពីរ

ឃ– ទៀនពេលា · មួយគូ, ទម្ងន់ក្រមួន ១ ដំឡឹង ប្រវែង ១ ជុំក្បាលកូនស្រី ១, មួយជុំក្បាលកូនប្រុស ១. រកក្រមួនឲ្យបានសុទ្ធល្អ ៗ អ្នកលញ់ទៀននេះ ត្រូវពឹងពាក់អ្នកដែលមានគូស្រករល្អមិនដែលអក់ព ។

x x
x

# បើកបាយស្រី

កូនស្រីចេញមកអង្គុយក្រាបទន្ទឹមនឹងប្ដី ដាក់ដៃទាំងពីរទន្ទឹមគ្នានៅលើកែប ។

អ្នកភ្លេងម្នាក់ដែលចេះរាំ-ច្រៀង ចូលមករាំបើកបាយស្រី ៣ បទ ៗ ដំបូងច្រៀងរាំបន្តិចហើយក៏ចាប់ដងដាវកាន់ឡើងស្រែកថា :

ជ័យហោង ? (អ្នកទាំងពួងឆ្លើយថា) ជ័យ !

សួស្ដីហោង ? (អ្នកទាំងពួងឆ្លើយថា) សួស្ដី !

សុខហោង ? (អ្នកទាំងពួងឆ្លើយថា) សុខ !

ហើយហូតដាវចេញពីស្រោម រាំ-ច្រៀងបទកិន្នរប្ដូរបទបណ្ដាយ យាដយាស ដូចមានទំនុកតទៅនេះថា :

ដាវអើយដាវដែក ដាវល្អបំឡែក បានពីសួគ៌ឆាយ ផ្លែជាឪពុក ស្រោមសោតជាម្ដាយ បានពីសួគ៌ឆាយ កម្រាបសត្រូវ ។

– ច្រៀង៣ដងហើយឡើងស្រែកថា "ជ័យហោង!, សួស្ដីហោង!, សុខហោង! ៣ដងទៀតដូចមុន រួចយកចុងដាវទៅចាក់សំពត់សប្ដស្បៃ ដែលគ្របទៀបមកបង់ករ រួចសកដាវទៅក្នុងស្រោមវិញ

ដាក់ទៅលើដៃសាមីខ្លួនអ្នកការ ដង់ទៅខាងកូនប្រុស ។ ហើយកំ-ច្រៀងតទៅថា :

ឱស្បៃកាសា បានពីទេវតា លោកដាក់មកឲ្យ រាំយកស្បៃ
រូប ចាប់ទៀបជាក្រោយ លោកដាក់មកឲ្យ បានសុខសួស្តី ។

ច្រៀង៣ បទ ហើយលូកដៃខ្លួនគ្នាចាប់គ្របទៀបទាំងពីរស្រែកថា :

ជ័យហោង!, សួស្តីហោង!, សុខហោង! រួចបើកគ្របទៀបឡើងកំ-ច្រៀងថា :

ឱទៀបទាំងគូ ត្រឹមត្រូវលក្ខណា បានពីទេវតា ឲ្យពរ
ឆាងអ្នក ៣ ដងទៀតសឹមគ្របទៅវិញ ។

× ×
×

## បង្វិលពពិល

អាចារ្យបិតទៀនទិនពពិលទាំង៣ ហើយអុចហុចមកខាងឆ្វេងដៃ, ហៅថាទក្ខិណាព័ណ៌ ហើយសូត្រ "ជយន្តោ" ដូចតទៅ ៖

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ អបរា-ជិតបល្លង្កេ សីសេ បថវិបោក្ខរេ អភិសេកេ សព្វ-

ពុទ្ធានំ អគ្គប្បត្តោ បមោទតិ ។ សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារីសុ បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។

ត្រូវសូត្រឲ្យព្រម ៗ គ្នា លុះត្រាតែគ្រប់កំណត់តាមអាចារ្យសូត្រ ។ លេងភ្លេងជុំក្រែ ។

⁂

បង្វិលពពិល គេត្រូវរើសយកប្រុស ៥ នាក់, ស្រី ៤ នាក់ រួមជា ៩ នាក់, បើរួមទាំងអ្នកជូន, អ្នកាមហា ទិង អាចារ្យផង ត្រូវជា ១២ នាក់ (អ្នកបង្វិលពពិលត្រូវរើសយកមនុស្សកុំឲ្យអភ័ព្វគួ) ។

សាមីខ្លួនប្រុសត្រូវហូតដៃតាមបង្គាប់អាចារ្យ ៣ ដង រួចទទួលយកផ្កាស្លាច្បង ហើយហុចជូនទៅមាតាបិតា ឬ ញាតិសាច់សាលោហិតណាមួយ ឲ្យយកទៅតម្កល់ទុកលើអាសនៈព្រះ ។ ឯផ្កាស្លាកណ្ដាល ទិងផ្កាស្លាពៅ ក៏ត្រូវហូតដៃទទួលដូចគ្នា រួចឲ្យយកទៅតម្កល់ទុកនៅចំពោះមុខសាមីខ្លួន ដែលកំពុងក្រាបផ្ទឹម ។

លុះផ្ទឹមរួច, ផ្កាស្លាច្បងគេត្រូវទុកយកទៅប្រគេនព្រះសង្ឃឯវត្ត ។

ឯផ្កាស្លាកណ្ដាល និងទៀត គេត្រូវស្រាយចែកញាតិក្នុងពេលផ្ទឹមរួច ក្លាម បូតបាចសាចឲ្យពរស័ព្ទសាធុការ ដល់សាម៉ីខ្លួនទាំងពីរ ជាកិច្ចបញ្ចប់ពិធីមង្គលការ ។

## ដំណើរពពិល

ពពិលទាំង ៣ ត្រូវចេញ ១ ម្ដង ៗ ពីដៃអាចារ្យ មកអ្នក ម បា, បន្តៗគ្នា ជាលំដាប់ ប្រទក្សិណជុំវិញអ្នកសាម៉ីខ្លួនទាំងពីរ ។ ដំណើរដែលមិនហុចគ្នា និងទទួលគ្នា ត្រូវធ្វើឲ្យដូចមានអធិប្បាយជូនតទៅ ៖

= ហុចទៅនិងដៃឆ្វេង

= ទទួលត (ទទួលនិងដៃឆ្វេង)

= ទទួលមកហើយ (កាន់ឲ្យបំពីមុខ)

= យកដៃស្ដាំមកកាន់ទៀត

= ហើយលើកឲ្យខ្ពស់ឡើង

= ដាក់ទាបបន្តិចមក

= យកដៃស្ដាំបក់អណ្ដាតភ្លើងទៀត

= បញ្ចូលក្លិនក្រមួនក្រអូប ទៅឲ្យអ្នកសាម៉ីខ្លួនទាំងពីរ

= រួចទើបហុចតទៅអ្នកនៅខាងឆ្វេងដៃ

= ធ្វើយ៉ាងនេះ ដរាបលុះត្រាតែលោកអាចារ្យឲ្យឈប់

គំរូសទ្ធឹកពពិល



# សេចក្ដីពន្យល់អំពីរបៀបប្រើស្លឹកពពិល

(ពិធីបង្វិលពពិលនេះ ជាប្រពៃណីរបស់ព្រហ្មញ្ញសាសនា ព្រោះគេជឿថាជាកិច្ចមួយសំខាន់ណាស់ ក្នុងការឲ្យពរសព្ទសាធុការដល់សាមីខ្លួនដែលត្រូវទទួលតាមរបៀបព្រាហ្មណ៍) ។

នៅស្លឹកពពិលនិមួយ ៗ គេមានឆ្លាក់រូបនាងធរណី ដែលគេជឿថា នាងធរណី ជាប្រពន្ធព្រះឥសូរ នាងបង្កើតមនុស្សទាំងអស់ក្នុងលោកណ្ដាល ។

ស្លឹកពពិលខ្លះ មានឆ្លាក់រូបនាង ធរណី ៣

ស្លឹកពពិលខ្លះ មានឆ្លាក់រូបនាង ធរណី តែ ២

ស្លឹកពពិលខ្លះ មានឆ្លាក់រូបនាង ធរណី តែ ១

ដោយគេចាត់របៀបប្រើតាមឋានន្តរស័ក្តិបុគ្គល និងតាមទំហំពិធីនោះ ៗ ។

ស្លឹកមានរូប ៣ (គំរូលេខ ១) សំរាប់តែថ្វាយព្រះមហាក្សត្រិយ៍ នៅវេលាអភិសេក គឺគេបង្វិលពពិលថ្វាយជាមង្គល រួមនិងស្លឹកឯទៀតផង ដូចមានតទៅគឺ ៖

ស្លឹកមានរូប ៣ – ១

ស្លឹកមានរូប ២ – ១

ស្លឹកមានរូប ១ – ៧

រួមជា – ៩ ស្លឹក

ចុះបើជាពិធីថ្វាយត្រឹមតែព្រះរាជបុត្រា - បុត្រីនៃអម្ចាស់ជីវិតផែនដី នោះគេពុំហ៊ានយកសន្ទឹកមានរូប ៣ មកប្រើឡើយ គេប្រើតែសន្ទឹករូប ២ និងរូប ១ គឺ ៖

សន្ទឹកមានរូប ២ — ១

សន្ទឹកមានរូប ១ — ៦

រួមជា ៨

គឺគេប្រើតែត្រឹម ៨ សន្ទឹកប៉ុណ្ណោះ ។

## ឧទាហរណ៍ ៖ ក្នុងមង្គលអាពាហ៍ពិពាហ៍

ចុះបើជាព្រះរាជពិធី ដែលព្រះមហាក្សត្រិយ៍ទ្រង់ប្រោសព្រះរាជទានមង្គលការដល់សាមញ្ញជន ដូចព្រះរាជពិធីខ្ជាន់ខាត ដែលទ្រង់ព្រះមេត្តាដល់ពលរដ្ឋព្រះអង្គ នោះបារគូបុរោហិត លោកប្រើតែសន្ទឹកមានរូបតែ ១, តែ ៥ សន្ទឹក ។

ចំណែកយើងជាសាមញ្ញជន ត្រូវប្រើតែសន្ទឹកមានរូបតែ ១, ត្រឹមតែ ៣ សន្ទឹកជាដាច់ខាត ដូចយើងធ្លាប់បានធ្វើបានឃើញជារឿយៗ មកហើយ នៅពេលសំពះផ្ទឹមដែលយើងរៀបអាពាហ៍ពិពាហ៍កូនចៅ ។

⁂

## ចងដៃ

បង្វិលពពិលហើយ ត្រូវចងដៃឲ្យពរស័ព្ទសាធុការ កូនប្រុស-ស្រី ។ លោកអាចារ្យចងមុន តមកមាតាបិតាទាំងសងខាង ទាំងញាតិសន្ដានសាច់សាលោហិត ជាលំដាប់តៗគ្នាទៅ (លេងភ្លេងជាយខុង) ។

× ×
×

## បាចផ្កាស្លា

បង្វិលពពិលហើយ ត្រូវស្រាយផ្កាស្លាកណ្ដាល និងពៅបែកគ្នា បាចឲ្យពរស័ព្ទសាធុការគ្រប់ៗ ខាត់ទាំងអស់គ្នា ដល់សាមីខ្លួនទាំងគូជាកិច្ចបញ្ចប់ពិធីមង្គលការ ។

ឯផ្កាស្លាបន្ទន់តម្កល់ទុកនៅក្បាលដំណេក ៣ ថ្ងៃ ទុកឲ្យសាមីខ្លួនទាំងពីរ នាំយកទៅប្រគេនលោកគ្រូព្រះឧបជ្ឈាយ៍របស់កូនប្រុស ដែលខ្លួនធ្លាប់បានបួសរៀននិងលោក ឬព្រះសង្ឃអង្គណាដែលយើងធ្លាប់គោរពប្រណិប័តន៍លោកទុកដូចជាគ្រូបាធ្យាយរបស់យើង ។ បើសាមីខ្លួនមិនបានបួសទេ យើងចង់នាំយកទៅប្រគេនលោកគ្រូសង្ឃរាជវត្តណា ឬព្រះសង្ឃអង្គណាមួយក៏បាន ។ ពីបុរាណកាល កូនប្រុសតែអាយុ ២១ ឆ្នាំ ឬ ជាង ១០ ឆ្នា ហើយ មាតាបិតាត្រូវចាត់ការឲ្យរៀនធម៌បួសជាសាមណេរ

បុជាភិក្ខុ ព្រោះបើមិនបានបួស គេមិនរាប់ថាជាអ្នកចេះដឹងទេ ដណ្ដឹងកូនស្រីគេធ្វើជាប្រពន្ធ គេមិនឲ្យទេ, ម្ល៉ោះហើយយើងរមែងមានប្រពន្ធផ្ដេសផ្ដាសតាមចិត្តយើង ៗ ដល់យើងមានកូនៗ នោះគេហៅថា "ក្មួង ឥតខាន់ស្លា". រូបយើងទៀត គេក៏ពុំរាប់បញ្ចូលក្នុងជនជាន់ខ្ពស់ទេ គឺគេមិនយកធ្វើជាៈ មេឃា ជា អ្នកភាដូវ, ជា ចៅមហាទេ សូម្បីតែដោតផ្កាស្លា ឬ បង្វិលពពិល ក៏គេមិនយកជាការមង្គលទាំងអស់ ៗ រហូតដល់ស្រីដែលប្រពន្ធចុង, ពីដើមគេហៅថា "មេខា" ដែលគេយកគ្នាឥតរៀបការក្រយាសំពះ. ទោះជាប្ដីនោះ មានបុណ្យ មានស័ក្ដិយសខ្ពស់យ៉ាងណាក៏ដោយ ក៏គេលើកទុកគោរព ១ អន្ទើតាមសេចក្ដីគួរសម គ្រាន់ថាឲ្យគេរាប់យកមកជាមង្គលសិរីៈនោះគេពុំរាប់ផងទេ ។ មិនតែប៉ុណ្ណោះ ក្នុងរាជការនៃព្រះបរមរាជវាំង ក៏គេពុំអាចឲ្យចេញមុខ ឡើងក្រាបបង្គំគាល់ព្រះមហាក្សត្រជាអម្ចាស់ផែនដី ក្នុងព្រះរាជពិធីណាមួយបានឡើយ ។

ត្រង់រឿងប្រពន្ធនេះ ខ្ញុំសូមអធិប្បាយឲ្យពិស្ដារបន្តិច "ប្រពន្ធ" ប្រែថា "ចំណងរឹតរួត" ។ ដូច្នេះហើយបានជាអ្នកមានប្រពន្ធ ត្រូវមានបន្ទុក ១ ថែមមកលើរូបខ្លួនទៀត ជាធម្មន់ ១ ក្នុងការបីបាច់ថែរក្សា ចិញ្ចឹមព្យាបាល ។ តែពុំអាចថឹងខ្លួនថាជាចំណងរឹតរួតខ្លួនទេ និងពុំអាចដឹងថាជាបន្ទុកធ្ងន់លើស្មាខ្លួនទេ យើងទាំងអស់គ្នាជាបុរសរមែងយល់ថាជា

វាសនា ជាការសប្បាយទៅវិញ ដែលយើងមានប្រពន្ធនោះ។ ម៉្លោះហើយ ប្រពន្ធ ១ពុំសុខចិត្ត ត្រូវមានឲ្យច្រើន, ខ្វះមាន ១ ហើយត្រូវយក ១ទៀត ជា ២, ខ្វះមាន ២ ហើយត្រូវយក ១ ទៀតជា៣ ។ល។ យ៉ាងនេះហើយ បានជាច្បាប់លោកញែកឲ្យហៅថា "ប្រពន្ធដើម, ប្រពន្ធចុង, ប្រពន្ធមុន, ប្រពន្ធក្រោយ, ប្រពន្ធលួចលាក់, មេខា... ។ល។, ឲ្យឈ្មោះហូតដល់ទៅកូនប្រុស-ស្រីទៀត, ហៅថា "ក្មួនដើម, ក្មួនចុង, ក្មួនមុន, ក្មួនក្រោយ, ក្មួនលួចលាក់, ក្មួនមេខា, ក្មួនឥតខាន់ស្លា ។

ប្រពន្ធដើម - គឺប្រពន្ធដែលបានរៀបការក្រយាសំពះ ពីក្រមុំ, កម្លោះ ឬ ជាបានគ្នាជាភរិយា-ស្វាមី មុនដំបូងបង្អស់ ។ តាមរបៀបច្បាប់, បានចុះអត្រានុកូលដ្ឋានជាទី ១ ។ កូនហៅថា "ក្មួនដើម" ។

ប្រពន្ធចុង - គឺប្រពន្ធដែលយើងយកបន្ទាប់ពីប្រពន្ធដើម "ប្រពន្ធដើមនៅរស់ ពុំបានលែងលះគ្នាទេ" ចុះបញ្ជីអាពាហ៍ពិពាហ៍ជាប្រពន្ធទី ២ ឬ ទី ៣ ... ។ កូនហៅថា "ក្មួនចុង" ។

ប្រពន្ធមុន - គឺប្រពន្ធដើមដែលស្លាប់ទៅ ឬ ដែលលែងលះគ្នា ។ កូនហៅថា "ក្មួនមុន" ។

ប្រពន្ធក្រោយ - គឺកាលប្រពន្ធដើមស្លាប់ទៅ ឬបែកបាក់គ្នាទៅ ប្ដីយកប្រពន្ធទៀត ចុះបញ្ជីអាពាហ៍ពិពាហ៍ជាប្រពន្ធទី១ទៀត។ ប្រពន្ធនេះ

គេហៅថា "ប្រពន្ធក្រោយ" គេពុំហៅថា "ប្រពន្ធចុង" ទេ ។ កូនហៅថា "ក្មួនក្រោយ" ។

ប្រពន្ធលួចលាក់ គឺប្រពន្ធដែលប្តីពុំឲ្យបេញមុខ ទុកបំបិតបំបាំងគ្មានរៀបការក្រយាសំពះ - គ្មានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ កូនហៅថា "ក្មួនលួចលាក់" ។

មេផា - គឺប្រពន្ធដែលជាអ្នកបំរើក្នុងផ្ទះ ។ កូនហៅថា ក្មួនមេផា ឬ ក្មួនម្ចាស់ឆ្ពាយ ។

★

# វត្ថុការដែលនៅក្នុងធៀបទាំងពីរ

ធៀបទី ១ គេដាក់មាន់ស្ងោរ ១ ឬ សាច់ជ្រូកស្ងោរ ១ ដុំធំ ។

ធៀបទី ២ ទៀត គេដាក់នំអន្សម, នំគម, នំបទ ឲ្យល្មមសមគួរ ។

របស់ទាំងនេះត្រូវបានទៅអ្នកក្មេងដែលរាំប្រៀនបើកបាយស្រី ។

ឯសំពត់ ឬ ស្បៃស្បដែលអ្នកក្មេងគាត់យកពីលើធៀបទៅក្រកតបង្អែននោះ អ្នកសាមីដើមការខាងប្រុស ត្រូវសុំលោះពីអ្នកក្មេងយកមកវិញជាប្រាក់តាមគួរសម ។

★

# សែនក្បាលដណ្ដើរ

សែនក្បាលដណ្ដើរត្រូវរៀបរណ្ដាប់ មានម្ហូបចំណី ១ ជាស, មាន់ស្ងោរ ១ ឬ សាច់ជ្រូកស្ងោរ ១ ដុំ រៀបដាក់ទៅក្បាលដណ្ដើរអុជទៀន ១ ធូប ៣ សរសៃ, ទឹក ១ ផ្តិល ទិញអម្បោះចងក្បាលដណ្ដើរ, សែនមុនកូនប្រុសមកដល់ ។

អ្នកដែលសែននោះ ត្រូវនិយាយសំបូងសង្រ្វឹងថា "សូមប្រកាសជូលទេវតាដែលរក្សាភូមិនេះ-ផ្ទះនេះ, ឥឡូវនេះ យើងខ្ញុំសូមផ្លូវដើរដណ្ដើរឡើង នាំកូនប្រុសមករៀបសំពះផ្ទឹមនឹងកូនស្រី ជាគូកិរិយាស្វាមី, សូមទេវតាជួយឲ្យពរស័ព្ទសាធុការដល់គូស្រករថ្មីនេះ ឲ្យបានសុខ ឲ្យបានចំរើនតរៀងទៅ ។" ។

(បើលោកអ្នកចេះឲ្យពរយ៉ាងវែង ហើយបានពិរោះជាងនេះទៅទៀត ក៏សូមអញ្ជើញឲ្យតាមមេត្តា ) ។

## ទៅវត្ត

ក្រោយការហើយ ៣ ថ្ងៃ ម្ដាយឪពុកទាំងសងខាង ត្រូវរៀបចំជូនគូភរិយាស្វាមីថ្មីនេះ ទៅសូមពរអំពីព្រះសង្ឃ ដែលជាគ្រូបាធ្យាយឯវត្ត ។ ត្រូវយកផ្កាស្លាម្លូ និងចំអាប ១ ថាស, បង្អែម ១ ថាស, ស្លាបារី ទៅប្រគេនលោកផង ។

លោកគ្រូកាលបើបានទទួលផ្កាស្លា ព្រមទាំងចង្ហាន់ជាបរិវាររួចហើយ លោកគ្រូត្រូវស្រាយផ្កាស្លានោះបាច ហើយសូត្រធម៌ឲ្យពរសព្ទសាធុការដល់គូភរិយាស្វាមីទាំងពីរនេះ ។

បើកូនប្រុសនោះពុំបាននៅវត្ត, ពុំបានបួសរៀននៅវត្ត យើងត្រូវទៅរកលោកគ្រូចៅអធិការវត្តណា ១ ដែលនៅជិតផ្ទះ ឬ ដែលយើងធ្លាប់ទៅធ្វើទាននឹងលោកក៏បាន (តែត្រូវចូលលោកឲ្យបានជ្រាបមុន ១ ថ្ងៃសិន) ។

(មានប្រាប់នៅក្នុងពិធីបាចផ្កាស្លារួចម្ដងហើយ)

⌘

⌘ ⌘

## អត្រានុកូលដ្ឋាន

ច្បាប់ចាស់ពីបុរាណ តែរៀបការហើយ អ្នកទាំងពីរបានឈ្មោះថាជាគូស្វាមីភរិយាពេញលក្ខណៈច្បាប់ ។ សម័យឥឡូវនេះ ត្រូវឲ្យឪពុកម្ដាយ

ទាំងសងខាងនាំកូនប្រុស-ស្រី ទៅចុះបញ្ជីអាពាហ៍ពិពាហ៍ ឯផ្ទះមេឃុំទៀត ក្នុងរវាង៣ថ្ងៃក្រោយការ ហៅថាចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ៗ សាមីខ្លួនទាំងពីរ បើមានសំបុត្រជាតិ ត្រូវយកសំបុត្រជាតិខ្លួនទៅជាមួយផង ។ ព្រមទាំងហៅញាតិដែលមានអាយុច្រើនជាងខ្លួនឲ្យទៅជាមួយផង ទៅធ្វើសាក្សី ។ ចំណែកមាតាបិតាទាំងសងខាងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ខ្លួនទៅជាមួយផង ។

ចប់ភាគ ៣

# ភាគទី៤

## គំរូលិខិតផ្សេងៗ

# ពិធីឡើងផ្ទះថ្មី

ត្រូវគេហោរាចារ្យព្រាហ្មណ៍ព្រឹទ្ធគន់គូររើសឫក្សពេលល្អ នឹងរៀបពិធីឡើងផ្ទះថ្មី ដើម្បីសូមសិរីជ័យមង្គល សុខក្សេមក្សាន្តតទៅ "បើយើងជឿហោរ" ។ (បើយើងជាឧបាសក-ឧបាសិកា ដល់ហើយនូវព្រះត្រៃសរណគមជាទីពឹងទុកស្មើជីវិត ជឿផលនៃកម្ម នោះពុំបាច់រើសពេលឫក្សពារល្អមិនល្អទេ ស្រេចតែថ្ងៃណាទំនេរ និមន្តព្រះសង្ឃមកចំរើនព្រះបរិត្តសូមពរហើយឡើងទៅនៅក៏ជាកិច្ចអស់ការ) ។

ត្រង់ទីនេះ ខ្ញុំយកបុរាណប្រវេណីមកដំណាលជូនញាតិមិត្រ ស្តាប់ក្រែងមានលោក-អ្នកចង់ដឹងអំពីរបៀបឡើងផ្ទះថ្មី តើចាស់ទុំពីដូនជីតា ទួត-លួត ណា យើងកាន់គ្នា ពីដើមគេធ្វើម្ដេចខ្លះ ព្រោះយើងទាំងអស់គ្នាមានប្រាថ្នាចង់បានសុខ-បានចំរើន សូម្បីតែអម្ចាស់ផែនដីពីអតីតកាលមក ព្រះអង្គក៏ពុំបោះបង់ប្រវេណីព្រះមហាក្សត្រមុនៗដែរ ដូចខ្ញុំបានយកមកត្រដាងជូនមើលខាងដើមហើយ នូវព្រះរាជពិធីឡើងព្រះរាជដំណាក់ព្រះមហាមន្ទីរជាដើម ។

★

# របៀបចាត់ការឡើងផ្ទះថ្មី

ផ្ទះយើងសង់រួចហើយ យើងកំណត់ថាឡើងនៅថ្ងៃណា ៗ នោះយើងត្រូវរកវត្ថុផ្សេង ៗ ដូចមានខាងក្រោមនេះ សំរាប់កាន់ឡើងផ្ទះថ្មី:

១– អាចារ្យ ឬ ចាស់ទុំម្នាក់ដើរមុខ

២– ក្អមដី ឬ ឆ្នាំង (ជើរកបាន)

៣– គ្រឿងមាសពេជ្រ

៤– សំពត់អាវ

៥– ប្រាក់កាស (បើមានសាច់ប្រាក់ចាស់ល្អ រៀល ឬ ណែន)

៦– ថប់មាស

៧– ដួងចិត្តមាស

៨– ត្រឡាចចិត្តមាស

៩– ល័ក្តជុំកន្ទង់

១០– ស្រូវគង់

១១– ធ្នាញ៊ីសម្បុរ ៣ "ពាក់ដីវដាំត្បូង ឬ ចង្រ្កានមាស" (ធ្នាញ៊ីនេះត្រូវពីងពារកស្រ្តីមានគភ៌ឲ្យបី)

១២– កន្ទេល ១ ខ្នើយ ១

របស់ទាំងនេះ ត្រូវរៀបជារបៀបមុនក្រោយ ដូចខាងលើនេះ ដើរព័ទ្ធជុំវិញផ្ទះ ៣ ជុំ ។ មួយជុំមកឈប់នៅជើងជណ្ដើរខាងមុខមួង ស្រែកហៅម្ចាស់ផ្ទះថា :

អឺ, លោកអ្នកម្ចាស់ផ្ទះ ?

មួងគេមិនឆ្លើយទេ ។

ក្បួនក៏តាំងដើរព័ទ្ធផ្ទះមួយជុំទៀត មកដល់ជើងជណ្ដើរដដែលស្រែកហៅទៀត ក៏ឥតមាននរណាឆ្លើយ ។ លុះដល់គំរប់ ៣ ជុំ ទើបអ្នកផ្ទះឆ្លើយថា :

- ចុះលោកណា - អ្នកណា ?

អញ្ជើញទៅណា មកណា ?

ក៏នាំគ្នាមកស្រែកឡូឡាយ៉ាងនេះ ?

អ្នកខាងក្រោម ឆ្លើយថា :

- យើងខ្ញុំមកពីឆ្ងាយណាស់

សួរទៀតថា - ពីឆ្ងាយណាស់ - តើមកពីប្រទេសណា ?

ឆ្លើយថា : - មកពីនគរពេជ្រគ្រីសហ៍ ។

សួរទៀត - ចុះមានការអ្វី ?

ឆ្លើយថា - យើងខ្ញុំបានឮដំណឹងច្បាស់ណាស់

ថា លោក . . ; . . . . . អ្នក . . . នឹងរៀបរាប់មង្គលការកូនស្រី ឲ្យមានប្តី ក្នុងពេលឆាប់ៗនេះ ហើយបានសង់ផ្ទះថ្មី ១ ខ្នងឲ្យ មែនឬទេ?

អ្នកផ្ទះឆ្លើយថា - មែន - អ្នកមានដំណើរយ៉ាងណា ?

អ្នកដំណើរឆ្លើយថា - យើងនាំយកគ្រឿងគ្រជាក់គ្រជុំបំរើនសិរីជ័យមង្គលមកជូន ។

អ្នកផ្ទះសួរថា - អ្វីខ្លះទៅ ?

អ្នកដំណើរឆ្លើយ - យើងមាន :

កុយពុក កុកស្អុយ - មានខមាសប៉ុនដូងទុំ - ប៉ុនផ្លែត្រឡាច មានគ្រឿងមាស - ប្រាក់ - កែវកងពិទូរ្យសូរកាណ មានផ្កាសម្បុរ ៣ ប្រកបដោយលក្ខណៈបរិបូណ៌ . . , . . . . . . ។

បើលោកអ្នកត្រូវការបង់បាន យើងនឹងជូនឥតយកតម្លៃទេ សុំតែបាយ ១ ឆ្អែត នៅពេលនេះ ។

អ្នកផ្ទះតបថា - បាយ ១ ពេល មិនសល់ក្រទេ ឲ្យតែពិតដូចមាត់ថា បើដូច្នោះអញ្ជើញនាំគ្នាឡើងមក ។

នៅពេលនេះ ត្រូវសែនក្បាលជំណើរសិន ដោយមានគ្រឿងប្រដាប់រៀបទុកស្រាប់ជាមុនគឺ : ម្ហូបចំណី ១ ថាស, ក្បាលជ្រូកស្ងោរ ១, ទឹក ១ ផ្តិល, អុជទៀន ១, មានទាំងអម្បោះចំណងដៃផង និងស្លាធម៌ ១ គូ ។

អ្នកសែនត្រូវនិយាយថា “ខ្ញុំសូមប្តឹងដល់ពពួកភូមិទេវតា ព្រមទាំងទេវតារក្សាផ្ទះនេះផង ឥឡូវយើងខ្ញុំរៀបចំឡើងផ្ទះថ្មី ជាលំនៅរបស់យើងខ្ញុំ សូមទេវតា ទេពធិតាទាំងឡាយ ឲ្យនូវសព្ទសាធុការដល់យើងខ្ញុំ សុំឡើងតាមដំណើរនេះមក ឲ្យបានសុខបានចំរើនជារាបតទៅ!” ។

“ឲ្យយកអម្បោះចងក្បាលដំណើរ រួចយកទឹកផ្តិលជ្រួចក្បាលដំណើរនោះ សុំឲ្យគេដាក់គ្រជុំ” ។

អ្នកតាំងនោះឡើងទៅ យកកន្ទេលដែលយកមក ទៅក្រាលឈមមុខទៅរកទិសដើមរស់ - ដាក់ខ្នើយពីលើកន្ទេលនោះ ព្រមតាំងរបស់ទ្រព្យតាំងប៉ុន្មាន ដែលយកមកជាភ័ស្តុតាងថា ជាគ្រឿងគេដាក់គ្រជុំចំរើនសិរីសួស្តី រៀបពីខាងមុខខ្នើយ ហើយអញ្ជើញគូនស្រីចេញមកអង្គុយលើកន្ទេលនោះ ។ អ្នកម្ចាស់របស់លើករបស់តាំងទុំះជូនទៅ ហើយចងដៃឲ្យពរឲ្យបានសុខបានចំរើនដកបអស់យាវជីវ ។

រួចពិធីនេះទៅ ត្រូវនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ឬ លៀងក្រយា-ហារភ្ញៀវ តាមការគួរចង់ធ្វើណាមុនក៏បាន ។

របស់គ្រជាក់គ្រជុំទាំងប៉ុន្មាន ត្រូវយកមកតាំងក្នុងពេលសូត្រព្រះពុទ្ធមន្ត ។

### ពិធីឡើងផ្ទះថ្មីចប់

បើម្ចាស់ផ្ទះចាស់ៗអស់ទៅហើយ ត្រូវអញ្ជើញចេញមកទាំងពីរនាក់អង្គុយទន្ទឹមគ្នាឲ្យគេចងដៃជូនពរ ។

⁂

# សេចក្ដីរំឭក

លោក-អ្នកឃើញហើយ នូវរបៀបឡើងផ្ទះថ្មី ឬ សម្ពោធវិហារថ្មី ដូចជា ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យត្រាស់បង្គាប់រាជសេវកាមាត្យ ឲ្យរៀបព្រះរាជពិធីឡើងព្រះដំណាក់ព្រះមហាមន្ទីរ ដែលខ្ញុំបាននាំយកកម្មវិធី មកចុះក្នុងសៀវភៅនេះទុកជូនឲ្យបានជ្រាបស្រាប់ហើយ គឺត្រូវធ្វើពិធីសម្ពោធ ឬឡើងផ្ទះថ្មី នោះ ឲ្យរួច ១ ពេលមុនសិន ទើបនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្តឲ្យពរជ័យជាខាងក្រោយ ។

ឧទាហរណ៍: ដូចជាយើងឡើងផ្ទះថ្មី ពីព្រឹក ឬ-រសៀល-ល្ងាច (យប់) ទើបយើងនិមន្តព្រះសង្ឃមកចំរើនព្រះពុទ្ធមន្ត រួចលៀងភ្ញៀវ ។

ដែលខ្ញុំជូនសេចក្ដីរំឭកនេះ មកពីខ្ញុំបានឃើញលោក-អ្នកខ្លះធ្វើខុសនិងប្រវេណីខ្លាំងពេក ។ ដូចជាមានវត្តខ្លះ មានកិច្ចសម្ពោធព្រះវិហារ ហើយប្រារព្ធអញ្ជើញស្ដេច សម្ដេចព្រះប្រមុខរដ្ឋ ជាព្រះបិតាជាតិ ស្ដេចយាងជាព្រះរាជាធិបតី កាត់ចំណងបូរ ដែលជានិមិត្តរូប សំរាប់សំគាល់ថា: "ព្រះវិហារនេះសម្ពោធរួចហើយ" ការគិតនេះ ល្អណាស់, ត្រូវណាស់, ប្រសើរណាស់ តែត្រូវអញ្ជើញស្ដេច

ព្រះអង្គព្រះរាជទានសិរីមង្គលនេះមុនគេបង្អស់ មិនមែនលោក-អ្នកលក់គ្នាទៅនាំគ្នានិមន្តលោកសូត្រព្រះពុទ្ធមន្ត, ទេសនា. ជា, ឆាន់ ២-៣ថ្ងៃ រួចទៅហើយ ។ បានអញ្ជើញស្ដេច ព្រះអង្គ សម្ពោធ ជាខាងក្រោយគេទេ ។ ត្រូវសូមព្រះរាជទាន កាត់ចំណងបូរ បើកទ្វារជាមុន ហើយលក់គ្នាបំពេញកិច្ចផ្សេងៗ ជាខាងក្រោយ, ធ្វើយ៉ាងនេះ ទើបត្រឹមត្រូវពេញតាមលក្ខណៈ ហៅថា ដើរតាមក្រោយសម្ដេច ឪ ដើរតាមក្រោយព្រះប្រិយមហាក្សត្រិយ៍របស់ខ្លួន ។

ខ្ញុំពោលរៀបរាប់មកនេះ លោក-អ្នក កុំច្រឡំមិនកាត់ឫសសីមាឲ្យសោះ, ព្រោះបុណ្យ "បញ្ចុះសីមា, កាត់ឫសសីមា" ជាបុណ្យមួយដ៏មហោឡារិក ក្នុងព្រះពុទ្ធសាសនា ។ បុរាណាចារ្យមែងតែងតែទុកសីមាកាល ថ្វាយព្រះមហាក្សត្រិយ៍កាត់ ឬ ទុកជូនវរជនណាមួយ ដែលគេគោរពដំកើងជាជាងជនសាមញ្ញទូទៅ ។

ដូចជាបុណ្យឈាបនកិច្ចនេះសោតទៀត បើព្រះមហាក្សត្រិយ៍ ស្ដេចយាងព្រះរាជទានភ្លើង ដល់សពបុគ្គលណាមួយនោះៗ បណ្ដាញាតិមិត្រនៃសព មិនត្រូវដាក់ផ្កាស្លាលាទោសមុនព្រះមហាក្សត្រិយ៍ទេ ត្រូវតែរង់ចាំតាមហែពីខាងក្រោយជាដរាប ។ ចុះបើជាព្រះរាជាគណៈវិញ នោះក៏ត្រូវធ្វើដូចគ្នាដែរ ។

* *
*

# គំរូសំបុត្រអញ្ជើញភ្ញៀវ

របៀបការខាងផ្ទះកូនស្រី សម្រាប់វង្សដែលមានឋានន្តរសក្តិ

## អាពាហមង្គល (១)

(២)

**ឧកញ៉ាមហាមន្ត្រី ញឹក-នូវ ឧកញ៉ា (ងារ) និង (នាម)**

និងភរិយា(៣) និងភរិយា

ចាងហ្វាងក្រុមព្រះរាជមន្ទីរ(៤) នាយការិយាល័យ ក្រសួង

**ទូលបង្គំ - ខ្ញុំបាទ**

ព្រមទាំងភរិយា

នឹងរៀបមង្គលការ

កូនប្រុសឈ្មោះ ... – ជាគូនឹង – កូនស្រីឈ្មោះ ...

កំណត់ចំរើនព្រះបរិត្ត នៅថ្ងៃទី ... ខែ ... ឆ្នាំ ... នេះ, ព្រឹកឡើងសំពះទទួលស្លាធរជាស្រេច ។

(៥)

សូមអញ្ជើញស្ដេច-ទ្រង់, អញ្ជើញឯកឧត្ដម-លោក-អ្នក មេត្តាជាកិត្តិយស ចំរើនសិរីជ័យមង្គលដល់សាមីខ្លួនការថ្មីទាំងពីរ និងសោយ-ពិសាលៀងក្រយាហារ(៦) នៅគេហស្ថានខាងស្រី ផ្ទះលេខ ... ផ្លូវ ... ក្រុងភ្នំពេញ នៅថ្ងៃទី ... ខែ ... គ.ស. ១៩៦៥ វេលាម៉ោង១៩ ។

# សូមមើលសេចក្ដីពន្យល់ខាងក្រោម

ខ្ញុំមិនសមបើនឹងធ្វើគំរូសំបុត្រអញ្ជើញភ្ញៀវនេះសោះ តែមកពីបានទទួលសំបុត្រអញ្ជើញពីអស់លោក អ្នកទាំងឡាយខ្លះ មានសេចក្ដីនិងពាក្យឆ្គងជាច្រើនកន្លែង បានជាខ្ញុំកែឡើង,

(១) ពាក្យថា " អាវាហមង្គល " ត្រូវប្រើតែកាលណាយើងរៀបមង្គលការ នៅផ្ទះខាងស្រី ។

## សេចក្ដីពន្យល់

ការនាំកូនប្រុសទៅការខាងលំនៅកូនស្រី ហៅថា : " អាវាហៈ ឬ អាពាហ៍ " ។

ការនាំកូនស្រីទៅការខាងលំនៅកូនប្រុស ហៅថា : " វិវាហៈ ឬ ពិពាហ៍ " ។

បើគេធ្វើនៅទីណា ១ ក្រៅពីលំនៅកូនស្រី-ប្រុស ហៅថា : " អាវាហវិវាហ ឬថា អាពាហ៍ពិពាហ៍ " ។

(២) ពាក្យថា " លោក " ភាសាខ្មែរគេមិនដែលប្រើហៅខ្លួនឯងថាលោកទេ ពាក្យនេះសំរាប់ហៅតែអ្នកដទៃឯទៀត ។ បើសំរាប់ខ្លួន គេប្រើ " ងារ " ថា " ម៉ឺន . . . ឃុន . . . ហ្លួង . ព្រះ . . . ឧកញ៉ា . . . ។ បើពុំចង់ប្រើងារការទេ គេថា, ដូចឧទាហរណ៍តទៅ :

ឧកញ៉ាមហាមន្ត្រីញ៉ិកា-ធូរ ឬថា ញ៉ិកា-ធូរ តែម្តងក៏បាន ។

(៣) ចំណែកប្រពន្ធទៀត មិនត្រូវសរសេរថាលោកស្រីទេ, ត្រូវថា " ភរិយា " ជាការគួរ ហើយពីរោះស្តាប់ផង ។

(៤) គួរតែដាក់មុខក្រសួង ឬ អាសយដ្ឋានរបស់ខ្លួនឲ្យច្បាស់លាស់ ព្រោះជាប្រយោជន៍ដល់ភ្ញៀវដែលមានធុរៈឆ្ងាយឆ្លើយមក ឬ ផ្ញើចំណងដៃមក ។

(៥) ត្រូវប្រើថា " អញ្ជើញទៅជាកិត្តិយស " មិនត្រូវថា អញ្ជើញទៅជា " អធិបតី " ទេ ព្រោះពាក្យថា " អធិបតី " នេះ គេសំរាប់ជូនទៅបុគ្គលតែ " ម្នាក់ " ទេ, គេមិនដែលអញ្ជើញភ្ញៀវរាប់រយនាក់ ឲ្យទៅធ្វើជា " អធិបតី " ទាំងអស់គ្នាទេ ។ បើអញ្ជើញទៅជា " កិត្តិយស " នោះ សមណាស់ ហើយត្រឹមត្រូវផង ។

(៦) ថា " ពិសាលៀងក្រយាហារ " យ៉ាងនេះ ទើបត្រូវ ។ មានសំបុត្រខ្លះ, សរសេរថា " អញ្ជើញទៅជាកិត្តិយស ក្នុងឱកាសលៀងក្រយាហារ " យ៉ាងនេះ, បានសេចក្តីថា : „គេឥតហៅយើងឲ្យទៅចូលលៀងទេ" គេលៀងភ្ញៀវឯទៀតទេតើ ។ ចំណែកខាងយើង „គេគ្រាន់តែអញ្ជើញទៅជាកិត្តិយស ឲ្យអង្គុយមើលមាត់គេតែប៉ុណ្ណោះទេ" នេះបើគិតយកតាមន័យសេចក្តីដែលគេសរសេរនោះ ។

X X X

## គំរូសំបុត្រជូនដំណឹងមង្គលការ សម្រាប់សាមញ្ញជន

### អាវាហមង្គលការ

នួន ប៊ុត និង ភរិយា | នួន ផល និង ភរិយា

ផ្ទះលេខ ១៧៦ វិថីខេមរភូមិន្ទ ភ្នំពេញ | ភូមិអម្ពិល ឃុំកេនដ៏រ ស្រុកបាភ្នំ (ព្រៃវែង)

**ទូលព្រះបង្គំ-យើងខ្ញុំ**

**នឹងរៀបមង្គលការ**

បុត្រី នាម **នួន-ភូរិន្ទី** – ជាគូនិង – បុត្រា នាម **នួន-ផលព្រឹក្ស**

កំណត់បំរើនព្រះបរិត្ត នៅថ្ងៃ . . . ខែ . . . ឆ្នាំ . . . ព. ស. . . . ត្រូវនឹងថ្ងៃទី . . . ខែ . . . ឆ្នាំ . . . នៅគេហដ្ឋានខាងស្រី ផ្ទះលេខ . . . ផ្លូវ . . . . . . . . . ។ ព្រឹកឡើងសំគះទទួលស្វាគមន៍ជាសួរបេចមង្គលការ ។

## សូមអញ្ជើញ

សម្តេច ទ្រង់, ឯកឧត្តម លោក-អ្នក ទៅជាកិត្តិយស
និងសោយ-ពិសា ខាទនិយភោជនិយាហារ នៅថ្ងៃទី...
ខែ . . . ឆ្នាំ . . . វេលាម៉ោង . . . នៅគេហដ្ឋាន...
ឬ ភោជនីយដ្ឋាន . . . ដោយមេត្រីភាព ។

*គំរូសំបុត្រ « អញ្ជើញភ្ញៀវពិសាលៀង » គូបនេះ គេសម្រាប់យកទៅចងភ្ជាប់នឹងក្បាលសំបុត្រអាពាហមង្គលការ ខាងលើនេះ ។*

⁂

# ពេលាមង្គលការ

## គំរូសេចក្តីសម្រាប់សរសេរដាក់ក្នុងពេលារាសី

សុភមស្តុ វរមង្គលា ជយាតិរេក ជាឯកឧត្តមសមគួរ ជាគួរនឹងគាប់ផ្គសន្យា ប្រកបហត្ថី អស្ស គោណា មហិង្សា មានតូច-ធំ តាំងតាស៊ីតាសា ជាយសបរិវារ មីរមកជួបជុំ សមជាពេលារាសី បេកមាស ទុកាស ត្រសាយត្រសុំ សមល្អប្រពៃ ។

ថ្ងៃ ១ ៗ/១១ ៤ ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ៤ ខែមេសា គ.ស. ១៩៤៨ ។

អ្នកឧកញ៉ា "ង៉ារ" .. (ឈាម នឹង គោត្រ) និងអ្នកស្រី "ឈាម នឹង គោត្រ" ទីលំនៅៗ សង្កាត់លេខ . . . ក្រុងភ្នំពេញ ។

សូមធ្វើជាពេលាបេកមាស បុត្រប្រុស-ស្រី ជំរាបជូនអ្នកឧកញ៉ា "ង៉ារ" . . . ឈាម នឹង គោត្រ "នាយមន្ទីរក្រសួង . . . និងអ្នកស្រី "ឈាម នឹង គោត្រ" នូវលោកមេបា ឧកញ៉ា ពញា ព្រះ ត្រកូលរៀមច្បង បុត្រប្រុស-ស្រី តាំងប៉ុន្មាន សូមបានជ្រាបៗ

ដ្បិតខ្ញុំបានរកអាចារ្យ គន់គូរឫក្សពារពេសីបេកមាស ឆាយ . . . „ឆាយ ទិន គោត្រ” ជាកូនខ្ញុំ កើតឆ្នាំកុរ អាយុ ២៥ ឆ្នាំហើយ ។ បេកមាសឆ្នាំបើកនៅថ្ងៃអាទិត្យ, ខែបើកនៅពុធ, ថ្ងៃបើកនៅអាទិត្យ ។

ឯកូនស្រីលោក មេធា ឈ្មោះ ឆាង . . . (ជាម ទិន គោត្រ) កើតឆ្នាំមមែ អាយុ ១៧ ឆ្នាំ ។ បេកមាសឆ្នាំបើកនៅអាទិត្យ, ខែបើកនៅសុក្រ, ថ្ងៃបើកនៅព្រហស្បតិ៍ ។

ក្នុងខែផល្គុន ត្បូងនាគនៅទិសបស្ចិម, កន្ទុយនៅទិសបូពិ, ផ្ទៃនៅទិសឧត្តរ, ខ្នងនៅទិសទក្សិណ, ពិសនៅទិសពាយ័ព្យ ។

ថ្ងៃអាទិត្យដង្ហើមរស់នៅទិសឧត្តរ, ដង្ហើមស្លាប់ នៅទិសទក្សិណ, ទេវតានៅទិសបូពិ, សូលម្រិត្យុនៅទិសបស្ចិម - អាគ្នេយ៍ ចាក់ទៅទិសពាយ័ព្យ ។

ត្បូងនាគនៅទិសឦសាន, រំឡីព្រះឥន្ទ្រពីទិសបូពិ មានកាលលុទ័យ ១ ជាន់ ឯរសៀល, សង់ពេនគម្ពល់ផ្កាស្លានៅទិសបស្ចិម ដីគគុកបង្ក្រាននៅទិសឧត្តរ, ក្រាលកន្ទេលសំពះទទួលពេលា ត្រូវឲ្យឈមមុខទៅទិសអាគ្នេយ៍, រៀបអង្គុយពីទិសទក្សិណ. ពេលាល្អបើកបាននៅម៉ោង ៧ ទិង ១៨ នាទីព្រឹក ។

សូមអញ្ជើញអស់លោកមេបា ក្ដីញាតិឲ្យពរបងដៃបុត្រប្រុស-ស្រី

ជាសិរីសួស្ដីជ័យមង្គលមហាប្រសើរជាសួរេចបរិបូណ៌ហោង ।

គួរពុំគួរសូមជាស្ពានមេត្រីតរៀងទៅ

ពេលាអាពាហមង្គលការជ័យសួស្ដី ចប់តែប៉ុណ្ណេះ

⁂

ក្រដាសសរសេរពេលា គេត្រូវប្រើក្រដាស ក្រហមតែមួយសន្លឹក សរសេរឲ្យបានចប់សេចក្ដីនៅលើទំព័រតែ ១ ( ក្រដាសទំហំ ៣៥ ស. ម. × ២៨ ស. ម. ) ល្មមសរសេរអក្សរឲ្យបានទ្រើសបន្តិច ឲ្យមនុស្សចាស់ងាយមើលឃើញផង ។

# គំរូពរចងដៃ ក្នុងវេលាសែន

## បទកាកគតិ

ថ្ងៃនេះថ្ងៃជា មេបាគ្រប់គ្នា ចូលមកត្រៀបត្រា ជាអធិបតី ក្នុង
មង្គលការ ឲ្យបានសុខា ដល់បុត្រជៀងជាក់ ៗ លោកអើយពាក្យពរ
ពីរោះសារទរ រុងរឿងសិទ្ធិសក្តិ ខ្ញុំទឹងថ្វាថ្លែង ជារបែងដោយថ្នាក់ ដោយ
បទជៀងជាក់ ជួបចប់វាចារ ៗ អម្បោះសសម គួរគាប់ឧត្តម ដូចលួស
សុវណ្ណា កកាទ់លើកឡើង ជូលជើនថ្ងៃជា ចូលបង់ហត្ថា ឲ្យអ្នកសុខ-
សាន្ត ៗ ឲ្យអ្នកបានទី ខ្ពង់ខ្ពស់បុទ្ធី បរិបូណ៌ជើងក្ក អាយុយឺនយូរ
កបគ្គុបុកណា មួយរយឆ្នាំបាន ចៀសចាកពេគា ៗ នីរទុក្ខ ទោម-
នស្សំ ទុបទ្ទា ឪរសោកេ កេតេពាធា ស្វាមីភរិយា ហោន្តុសុខំ ៗ
ធនធា ទាសីទាសា ធនធំ អស្សធនោ គោគោឧត្តម បរិសុទ្ធ
ពហុយសា ៗ ព្រះបាលី ខ្ញុំទឹងស្រដី សរសើរពរ ចៀសចាកទុក្ខ
សោក ចង្រៃនានា អស់ទាំងពេគា កុំបីដិតដល់ ៗ កើតសេះដំរី កើតខ្ញុំ
ប្រុសស្រី ទ្រព្យធនស្កុបស្កល់ កើតយសសក្តិសែង ចង្រៃសោតសល់
មានតាំងរហ៍ពល បំរើសព្វថ្ងៃ ៗ អស់លោកបាស់ទុំ អញ្ជើញមកជុំ
ចូលមកឲ្យជ័យ កូនចៅដោយស្ម័គ្រ ប្រញាប់ដៃ ៗ រួបរួមចងដៃ ស្ងួរបេ

ហើយហោង ៗ លោកអើយពាក្យពរ ពីរោះសាទរ ប្រសើរគន្ធង

ដូចទឹកដាក គង្គាថ្វារង ឲ្យអ្នកនាងត្រង លុបលាបកគ្រា ៗ បំបាត់

ចង្រៃ បំបាត់ទុក្ខភ័យ ជម្ងឺរោគា ត្រជាក់ត្រជុំ សុខសមផង្គា ដូច-

ពាក្យពណ៌នា យើងខ្ញុំសូមជ័យ,

ជ័យ ហោង "ជ័យ"

សួស្តី ហោង "សួស្តី"

សុខ ហោង "សុខ"

សុខពិតប្រាកដ ដូចមាត់ខ្ញុំថា មែន ហោង "មែន"

យកអ្វីជាបន្ទាល់ យកគេហៅៗ ។ (ភយ ឈ្មោះ)

---

ពរនេះជាពាក្យចាស់បុរាណ – ខកញ៉ាភជភក្តី សុខ - ជិម តាមផ្ទែកធំរឺព្រះកដច្រូញ ចេះចាំឡូយក ។

※ ※
※

# កំរូពរបង់ដៃកូនស្រី–ប្រុសវេលាផ្ទឹម

## បទកាកគតិ

សូមពរតេជៈ ព្រះអាទិត្យរឿងរះ ពីបូព៌ទិសា រស្មីផ្ទះឡើង រុងរឿងលក្ខណា អស់ចាំងមេឃា ត្រកូលរៀមច្បង ៗ រៀបការកូនចៅ អញ្ជើញញាតិផៅ ជួបជុំមកបង់ ដៃមាត់ឲ្យពរ សាទរអឹងកង ក្មេងក្មាត់រំពង អញ្ជើញទេវតា ៗ ឥន្ទ្រព្រហ្មយមកាល ចតុលោកបាល នៅអស់អ្នកតា ព្រះភូមិព្រះស្រុក អារក្ខទេវា សូមលោកជួយជា បន្ទាល់សាក្សី ៗ ដ្បិតអស់យើងខ្ញុំ អញ្ជើញគៀវជុំ ការកូនប្រុសស្រី ឲ្យសា-ធុការ ពរជ័យសួស្តី ពេលាពិសី ល្អល្អះជ្រះថ្លា ៗ ពេលាបើកហោង អ្នកនាងត្រេកត្រង់ ខុនអង្គផ្ទឹមគ្នា លើកហត្ថប្រណម្យ បង្គំវន្ទា ជួញដិតសិរសា សំពះសូមពរ ៗ ព្រះពុទ្ធរក្សា ព្រះធម៌ជាទា ព្រះសង្ឃសាទរ ព្រះឥន្ទ្រឲ្យជ័យ ព្រហ្មថ្វៃឲ្យពរ អស់ទេពទិករ អវឲ្យសួស្តី ៗ បវិត្រសន្តាន ញាតិសាច់ពៀងលាន ចាំងប៉ុន្មានក្តី សូមជួយឲ្យពរដល់កូនប្រុសស្រី ពរនេះប្រពៃ ល្អល្អះស្រួចស្រស់ ៗ ទោះចាំងមេឃា ក្មេងចាស់កញ្ញា ក្រមុំកម្លោះ ទោះទាំងពៀងលាន សន្តានក្រៅស្មោះជួយចាប់អញ្ជោះ ឲ្យពរបង់ដៃ ៗ សូមបុណ្យតេជៈ អម្បោះឲ្យឈ្នះ

តែមួយសរសៃ ទុកស្នើល្មួសមាស គ្រាប់សរំពៃ បណ្ដាញជាត្រៃ មារ-មានចេញទៅ ៗ ឲ្យមានសួស្ដី ដល់កូនប្រុសស្រី ទាំងពីរអ្នកនៅ យើងឲ្យពរអ្នក ដាក់អម្បោះទៅ មាសទាំងសំពៅ ចូលមកចង់ដៃ ៗ ឲ្យអ្នកទាំងពីរ សុខសមរិទ្ធី អាយុយឺនយូរ មូលនៅកូនចៅ ញាតិផៅមេត្រី ចេញចូលច្រើនក្រៃ បរិបូណ៌សុខា ៗ ចំរើនយសសក្តិ៍ ចំរើនមាសប្រាក់ គោតទ្រព្យនានា មានទ្រុំកំដរ ចិត្តព្រសោភា បានសុខ-សាមគ្គា មានជ័យសួស្ដី !

(សួរ) ជ័យហោង (ឆ្លើយ) ជ័យ ៗ

(សួរ) សួស្តិ៍ហោង (ឆ្លើយ) សួស្តិ៍ ៗ

(សួរ) សុខហោង (ឆ្លើយ) សុខ ៗ

(សួរ) ធានអ្វីឆ្លើយភ្លាស់ (ឆ្លើយ) យសាហោ

(រាយហ្នោះ) ៗ

---

នេះជាពាក្យចាស់បុរាណ - ទកញ៉ាកផកក្ដី សុខ - ជិម ចាយផ្ញើកជំរាំព្រះកនទ្រព្យ ចេះចាំឡូមក ។

# នំខ្មែរបុរាណ

ពីបុរាណកាល នៅឱកាសរៀបចំឲ្យគូទប្រុសស្រីមានប្ដីប្រពន្ធ តាំងតែពីនិយាយបៃចូវ រហូតទៅដល់គ្នាទឹងសំពះស្លាបង្ហើយកិច្ច គេនាំគ្នាធ្វើនំដូចមានតទៅនេះ ៖

១– នំអន្សម

២– នំគប

៣– នំបត់ ឬ នំកាឡែង

៤– នំកាគ្រំ

៥– នំខ្ញី

៦– នំកាដ់ខ្វៀង

៧– នំផ្កាក្រាភញ

៨– នំឃ្មោះ

៩– នំលំអង់រំចេក

១០– នំសំបុកចាប

១១– នំគំដ

ប្រើជាចំនួសក័ស្ដុការបណ្ណាការ ក្នុងពេលបៃចូវ - ទទួលអំណោរ លើកស្លា - ស៊ីស្លាកំណត់ . . . ។

X X X



នំអន្សម



នំគម



នំបត់
ឬនំកន្សៀង



នំកន្ត្រំ



នំខ្ញី



នំកង់ខ្សៀន



នំផ្កាក្រវាញ



នំឃ្មោះ



នំលំអងរំចេក



នំសំបុកចាប



នំភីង

ក្រៅអំពីនំទាំងនេះគេប្រើបេកចុំចូលផងជាដកបត់ដែលមាន ។ នៅពេលលើកស្លា និងស៊ីកំណាត់ មានផ្លែឈើខ្លះ, បន្លែខ្លះ, សាច់ជ្រូក និងមាន់ទាខ្លះទៀតផង ។

# សីលធម៌

## ធម៌ដែលស្វាមីភរិយាត្រូវតែចេះចាំគ្រប់គ្នា

## ស្វាមីត្រូវសង្គ្រោះភរិយាដោយស្ថាន៥យ៉ាង

១– រាប់អានភរិយា ដោយប្រើសំដីទន់ផ្អែមទៅកាន់ភរិយា (មិនត្រូវប្រើពាក្យគំរោះគំរើយទៅកាន់ភរិយាឡើយ) ។

២– មិនបៀតបៀន និងមិនមើលងាយភរិយាដូចទាសីទាសា ។

៣– មិនប្រព្រឹត្តកន្លងចិត្តភរិយា (គឺថាមិនក្បត់ចិត្តភរិយា) ។

៤– ប្រគល់ឥស្សរិយយស គឺកិច្ចការសព្វយ៉ាងនៅក្នុងផ្ទះ ឲ្យទៅភរិយាកាន់កាប់ ។

៥– ផ្តល់ផ្គង់គ្រឿងសំលៀកបំពាក់ · គ្រឿងអលង្ការ តាមកម្លាំងធនធានដែលខ្លួនរកបាន ឲ្យបានសមគួរដល់ភរិយា ។

# ភរិយាត្រូវប្រតិបត្តិចំពោះស្វាមីវិញ
# ដោយស្ថាន ៥ យ៉ាងគឺ៖

១– ចាត់ចែងការងារក្នុងផ្ទះ–ក្រៅផ្ទះ មានបាយទឹកជាដើមដោយផ្ចិតផ្ចង់ ឲ្យបានទៀងទាត់តាមពេលវេលា ។

២– សង្គ្រោះដល់ញាតិខាងស្វាមីនិងញាតិខាងខ្លួន ឲ្យបានស្មើមុខគ្នា ( កុំឲ្យធ្ងន់ស្រាលប្លាង ៗ ) ។

៣– ចេះថែទាំទុកដាក់ទ្រព្យសម្បត្តិ ដែលស្វាមីរកបានមក ។

៤ មិនប្រព្រឹត្តកន្លងចិត្តស្វាមី ( គឺថាមិនក្បត់ចិត្តស្វាមី ) ។

៥– ឈ្លាសវៃ , មិនខ្ជិលច្រអូសក្នុងកិច្ចគ្រប់យ៉ាង ។

ស្រង់ពីសិង្គាលោវាទសូត្រ

ជួ ឆ - ប៊ុនា

# ពាក្យកែតម្រូវ

១- នៅអារម្ភកថា ខាងដើម ទំព័រទី ២ (ខ) - បន្ទាត់ខាងចុង ត្រង់ពាក្យថា: "មច្ចិមវ័យ" សូមកែថា៖ "បច្ចិមវ័យ" វិញ ។

២- នៅទំព័រ ១៩ - ត្រង់ពាក្យថា "លោកជំទាវ - លោក" សូមកែថា៖ លោកជំទាវ - លោកស្រីវិញ ។

៣- នៅទំព័រ ៩២ - បន្ទាត់ទី ២ - ត្រង់ពាក្យថា: "សំពះទៀនពេលា" សូមកែថា៖ សំពះកនពេលាវិញ ។

៤- នៅទំព័រ ១៥២ - បន្ទាត់ទី ២ និងទី ៣ សូមកែថា៖ ម្លូ ៣៩ សន្ទឹក, ផ្លែស្លា ៣៩ ផ្លែវិញ ។

៥- នៅទំព័រ ១៩៧ - នៅបន្ទាត់ខាងក្រោម - ត្រង់ពាក្យថា: ប្រើជាជំនូសក័ស្តុការបណ្ណាការ សូមកែថា៖ "ប្រើជាជំនូនក័ស្តុការបណ្ណាការ" វិញ ។

# បញ្ជីសៀវភៅរបស់ខ្ញុំដែលមានបោះពុម្ព
# ផ្សាយជូនញាតិមិត្តរួចមកហើយ

១ — ប្រជុំលិខិត — ជាគំរូសំបុត្រចុកហ្លួយគ្រប់បែប ។

២ — ទម្លាប់ទំនៀម — ជាពាក្យខ្ចាទឲ្យដឹងខុសត្រូវ គួរសមនៅពេលប្រជុំជន (មានភាគ ១ និង ភាគ ២) ។

៣ — ច្បាប់ក្រមបរិយាយ — គឺខ្ញុំយកសត្រាច្បាប់ក្រមចាស់ជាសុភាសិតបុរាណបណ្ឌិត មកកែស្រាយជាបរិយាយពន្យល់ឲ្យងាយស្ដាប់ ។

៤ — វេយ្យាករណ៍ខ្មែរ — ជាក្បួនសរសេរអក្សរខ្មែរឲ្យបានត្រឹមត្រូវ ហើយងាយយល់ផង ។

ក្បួនទាំងនេះមានលក់នៅបណ្ណាគារ ប៊ុក-នាង ខាងកើតផ្សារថ្មី ផ្ទះលេខ ១៣៦ វិថីខេមរភូមិន្ទ ក្រុងភ្នំពេញ ។

ខ្ញុំសរសេរក្បួននេះឡើង កុំឲ្យបច្ឆាជនគាជនបន្ទោសថា ចាស់ចោលទៀត ឥតមានយោគមិនសរសេរក្បួនច្បាប់ទុកឲ្យដឹងផង ។

រោងពុម្ពធំនើប លេខ ២១០ មហាវិថីឆាលដឺហ្គោល តម្លៃ ៧៥ រ,